ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២០ លេខ៩៦ ត្រីមាសទី០៤ ឆ្នាំ២០២០

រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា សារាចរ ប្រកាស

ក

មាតិកា

I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

១~ព្រះរាជក្រម

១៤-១១-២០២០ -ព្រះរាជក្រម នស/រកម/១១២០/០២៩ ស្តីពី ការប្រកាសឱ្យប្រើច្បាប់ស្តីពី ការអនុម័តយល់ព្រម លើវិសោធនកម្មពិធីសារម៉ុងរ៉េអាល់ស្តីពី សារធាតុបំផ្លាញស្រទាប់អូហ្សូន ១១៨០៥

២~ព្រះរាជក្រឹត្យ

៣០-១២-២០២០ -ព្រះរាជក្រឹត្យ នស/រកត/១២២០/១៤២៨ ស្តីពី ការតែងតាំង និងផ្តល់ឋានៈជាទីប្រឹក្សា និងជំនួយការរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ៣ រូប ១១៨៩៩

៣០-១២-២០២០ -ព្រះរាជក្រឹត្យ នស/រកត/១២២០/១៤២៩ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ជាកិច្ចបច្ឆាមរណៈ ចំពោះនាយទាហាន ថ្នាក់ឧត្តមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ដែលបានទទួលមរណៈភាព ចំនួន ១២ រូប ១១៩០០

៣០-១២-២០២០ -ព្រះរាជក្រឹត្យ នស/រកត/១២២០/១៤៣០ ស្តីពី ការតាំងស៊ប់ក្នុងក្របខ័ណ្ឌ នៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដល់មន្ត្រីរាជការ ៤៧ រូប ១១៩០២

៣០-១២-២០២០ -ព្រះរាជក្រឹត្យ នស/រកត/១២២០/១៤៣១ ស្តីពី ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់ប្រចាំឆ្នាំ នៅក្រសួងបរិស្ថាន ដល់មន្ត្រីរាជការ ៥៣ រូប ១១៩០៥

៣០-១២-២០២០ -ព្រះរាជក្រឹត្យ នស/រកត/១២២០/១៤៣២ ស្តីពី ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់ប្រចាំឆ្នាំ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដល់មន្ត្រីរាជការ ៤៨០ រូប ១១៩០៨

II~រាជរដ្ឋាភិបាល

អនុក្រឹត្យ

១៦-១២-២០២០ -អនុក្រឹត្យលេខ ១០៥៨ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១១៩២២

១៦-១២-២០២០ -អនុក្រឹត្យលេខ ១០៥៩ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ១១៩២៨

<u>បញ្ជាក់</u> : ព្រះរាជក្រម, ព្រះរាជក្រឹត្យ, អនុក្រឹត្យ, សេចក្តីសម្រេច, សារាចរ, ប្រកាស ឆ្នាំ ២០២០ នឹងមានចុះផ្សាយក្នុងរាជកិច្ច នាដើមឆ្នាំ ២០២១ បន្តទៀត ។

ព្រះរាជក្រម

នស/រកម/១១២០/ ០២៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើវិសោធនកម្មពិធីសារម៉ុងរ៉េអាល់ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៦ ខែតុលា ឆ្នាំ២០២០ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ នាសម័យប្រជុំពេញអង្គលើកទី៦ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *
ព្រះបរមរាជវាំង

ច្បាប់
ស្តីពី
ការអនុម័តយល់ព្រមលើវិសោធនកម្ម
ពិធីសារម៉ុងរ៉េអាល់ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន

មាត្រា១.-

អនុម័តយល់ព្រមលើវិសោធនកម្មពិធីសារម៉ុងរ៉េអាល់ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន ដែលបាន អនុម័តដោយកិច្ចប្រជុំលើកទី២៨ នៃភាគីពិធីសារម៉ុងរ៉េអាល់នៅទីក្រុងគីហ្គាលីនៃប្រទេសរវ៉ាន់ដា នាថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៦ និងបានចូលជាធរមាន នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ ហើយដែលមានអត្ថបទទាំងស្រុង ភ្ជាប់មកជាមួយនេះ។

មាត្រា២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តពិធីសារនេះ។

ថ្ងៃ សៅរ៍ ១៤រោច ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០២០

នស/រកម/១១២០/០២០

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រី ប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងបរិស្ថាន

សាយ សំអាល់

ពិធីសារម៉ុងរ៉េអាល់ ស្ដីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន

បានកែសម្រួល និងបានធ្វើវិសោធនកម្ម ដោយកិច្ចប្រជុំរបស់ភាគីលើកទី២
(ទីក្រុងឡុងដុង ថ្ងៃទី២៧-២៩ មិថុនា ១៩៩០)
និងដោយកិច្ចប្រជុំរបស់ភាគីលើកទី៤
(ទីក្រុងកូបែនហាហ្គេន ថ្ងៃទី២៣-២៥ វិច្ឆិកា ១៩៩២)
និងបានកែសម្រួលបន្ថែម ដោយកិច្ចប្រជុំរបស់ភាគីលើកទី៧
(ទីក្រុងវីយែន ថ្ងៃទី៥-៧ ធ្នូ ១៩៩៥)
និងបានកែសម្រួល និងបានធ្វើវិសោធនកម្មបន្ថែម ដោយកិច្ចប្រជុំរបស់ភាគីលើកទី៩
(ទីក្រុងម៉ុងរ៉េអាល់ ថ្ងៃទី១៥-១៧ កញ្ញា ១៩៩៧)
និងដោយកិច្ចប្រជុំរបស់ភាគីលើកទី១១
(ទីក្រុងប៉េកាំង ថ្ងៃទី២៩ វិច្ឆិកា-ថ្ងៃទី៣ ធ្នូ ១៩៩៩)
និងបានកែសម្រួល និង ដោយកិច្ចប្រជុំរបស់ភាគីលើកទី១៩
(ទីក្រុងម៉ុងរ៉េអាល់ ថ្ងៃទី១៧-២១ ធ្នូ ២០០៧)
និងបានធ្វើវិសោធនកម្ម ដោយកិច្ចប្រជុំរបស់ភាគីលើកទី២៨
(ទីក្រុងគីហ្កាលី ថ្ងៃទី១០-១៥ តុលា ឆ្នាំ២០១៦)

បុព្វកថា

ជាភាគីនៃពិធីសារនេះ

ត្រូវជាភាគីនៃអនុសញ្ញាទីក្រុងវីយែន ស្ដីពីកិច្ចការពារស្រទាប់អូហ្សូន

ស្ថិតនៅក្រោមអនុសញ្ញានេះ ភាគីជាសមាជិកត្រូវយល់ដឹងអំពីកាតព្វកិច្ចរបស់ខ្លួន ក្នុងការអនុវត្តវិធានការសមស្របសំដៅការពារសុខភាពមនុស្ស និងបរិស្ថានប្រឆាំងផលប៉ះពាល់ផ្សេងៗ បណ្ដាលមកពីសកម្មភាពមនុស្សបង្កឱ្យមានការផ្លាស់ប្ដូរឬមាននិន្នាការផ្លាស់ប្ដូរស្រទាប់អូហ្សូន។

គួរយល់ដឹង ចំពោះការបញ្ចេញទៅក្នុងបរិយាកាសនូវសារធាតុបំផ្លាញស្រទាប់អូហ្សូនក្នុងកម្រិតមួយដែលមានឥទ្ធិពលអាក្រក់ដល់សុខភាពមនុស្សនិងបរិស្ថាន។

កត់សម្គាល់ ពីឥទ្ធិពលប៉ះពាល់អាក្រក់ដល់អាកាសធាតុ ដែលបណ្ដាលមកពីការបញ្ចេញសារធាតុនេះទៅក្នុងបរិយាកាស។

យល់ដឹង ពីវិធានការការពារស្រទាប់អូហ្សូន ប្រឆាំងនឹងសកម្មភាពផ្សេងៗដែលបំផ្លាញស្រទាប់អូហ្សូនដោយផ្អែកទៅលើចំណេះដឹងវិទ្យាសាស្ត្រ ដោយគិតគូរពីផ្នែកបច្ចេកទេសនិងសេដ្ឋកិច្ច ។

8

ការប្តេជ្ញាចិត្ត ក្នុងកិច្ចការពារស្រទាប់អូហ្សូន ដោយរៀបចំវិធានការបង្ការជាមុនសំដៅត្រួតពិនិត្យការបញ្ចេញសារធាតុបំផ្លាញស្រទាប់អូហ្សូនទៅក្នុងបរិយាកាស ក៏ដូចជាកំណត់នូវទិសដៅខ្ពស់ក្នុងការលុបបំបាត់ការបំផ្លាញស្រទាប់អូហ្សូន ដោយផ្អែកទៅលើមូលដ្ឋាននៃការអភិវឌ្ឍផ្នែកចំណេះដឹងវិទ្យាសាស្ត្រ ត្រិះរិះពិចារណាទៅលើបច្ចេកទេសនិងសេដ្ឋកិច្ច និងគិតទៅដល់តម្រូវការអភិវឌ្ឍន៍របស់ប្រទេសកំពុងអភិវឌ្ឍន៍។

ការទទួលស្គាល់ ចំពោះបញ្ញត្តិដែលមានចែងជាពិសេស ឱ្យឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រទេសកំពុងអភិវឌ្ឍន៍ រួមទាំងបញ្ញត្តិអំពីធនធានហិរញ្ញវត្ថុបន្ថែម និងសម្រាប់ប្រើប្រាស់ទៅលើបច្ចេកវិទ្យាការព្យាករណ៍ទៅលើបរិមាណថវិកាចាំបាច់ និងថវិការំពឹងទុកសម្រាប់បង្កើនសមត្ថភាពតាមលក្ខណៈវិទ្យាសាស្ត្រ ដើម្បីកំណត់នូវបញ្ហាបំផ្លាញស្រទាប់អូហ្សូននិងឥទ្ធិពលរបស់វា។

កត់សម្គាល់ ទៅលើវិធានការបង្ការសម្រាប់ត្រួតពិនិត្យការបញ្ចេញសារធាតុក្លរ៉ូហ្វ្លុយអរ៉ូការបូន (Chloroflurocarbons) ដែលត្រូវបានអនុវត្តន៍ដោយថ្នាក់ជាតិនិងថ្នាក់តំបន់រួចហើយ។

ការត្រិះរិះពិចារណា ទៅលើសារៈសំខាន់នៃការពង្រឹងកិច្ចសហការជាលក្ខណៈអន្តរជាតិ ក្នុងការស្រាវជ្រាវ ការអភិវឌ្ឍ និងការផ្លាស់ប្តូរបច្ចេកវិទ្យាដែលទាក់ទងនឹងការត្រួតពិនិត្យ និងការកាត់បន្ថយការបញ្ចេញសារធាតុបំផ្លាញស្រទាប់អូហ្សូន ក៏ដូចជាការគិតទៅលើតម្រូវការចាំបាច់របស់ប្រទេសកំពុងអភិវឌ្ឍន៍។

បានព្រមព្រៀងដូចតទៅ៖

មាត្រា១ និយមន័យ

សម្រាប់គោលបំណង នៃពិធីសារនេះ៖

១- «**អនុសញ្ញា**» សំដៅដល់អនុសញ្ញាវីយែនស្តីពីកិច្ចការពារស្រទាប់អូហ្សូន ដែលបានអនុម័តនៅថ្ងៃទី២២ ខែមីនា ឆ្នាំ១៩៨៥។

២- «**ភាគី**» សំដៅដល់ភាគីជាសមាជិករបស់ពិធីសារនេះ។

៣- «**លេខាធិការដ្ឋាន**» សំដៅដល់លេខាធិការដ្ឋានរបស់អនុសញ្ញានេះ។

៤- «**សារធាតុដែលត្រូវត្រួតពិនិត្យ**» សំដៅដល់សារធាតុដែលមាននៅក្នុងឧបសម្ព័ន្ធA ឧបសម្ព័ន្ធB ឧបសម្ព័ន្ធC ឧបសម្ព័ន្ធE ឬឧបសម្ព័ន្ធF របស់ពិធីសារនេះ ដែលស្ថិតនៅទោលតែឯង ឬស្ថិតក្នុងស្ថានភាពជាល្បាយ។ សារធាតុដែលត្រូវត្រួតពិនិត្យមានទម្រង់ជាសារធាតុអ៊ីសូម៉ែរ លើកលែងតែបានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធ ប៉ុន្តែមិនរាប់បញ្ចូលសារធាតុដែលត្រូវត្រួតពិនិត្យឬល្បាយសារធាតុដែលជាផលិតផលត្រូវបានផលិតឡើង ក៏ដូចជាឧបករណ៍សម្រាប់ផ្ទុកទំនិញដែលប្រើសម្រាប់ដឹកជញ្ជូនឬស្តុកសារធាតុនោះ។

៥- «**ផលិតផល**» សំដៅដល់បរិមាណសារធាតុដែលត្រូវត្រួតពិនិត្យ ដកនឹងបរិមាណសារធាតុដែលត្រូវបំផ្លាញចោលដោយបច្ចេកវិទ្យា ដោយមានការឯកភាពពីភាគីជាសមាជិក និងដកជាមួយបរិមាណសារធាតុសរុបដែលបានប្រើប្រាស់នៅក្នុងការផលិតសារធាតុគីមី។ បរិមាណសារធាតុដែលត្រូវកែច្នៃ ឬត្រូវប្រើប្រាស់ឡើងវិញ ពុំចាត់ទុកជាផលិតផលទេ។

៦- «**ការប្រើប្រាស់**» សំដៅដល់ផលិតផលដែលផលិតបានបូកនឹងបរិមាណសារធាតុដែលត្រូវត្រួតពិនិត្យដែលបាននាំចូល និងដកបរិមាណសារធាតុដែលត្រូវត្រួតពិនិត្យដែលបាននាំចេញ។

៧- «**កម្រិតគណនា**» នៃផលិតផល ការនាំចូល ការនាំចេញ និងការប្រើប្រាស់ សំដៅដល់កម្រិតមួយ ដែលបានកំណត់ ដោយផ្អែកទៅតាមមាត្រា៣។

៨- «**សនិទានកម្មវិស័យឧស្សាហកម្ម**» សំដៅដល់ការផ្ទេរផលិតផលនៃការគណនាមួយផ្នែកឬទាំងស្រុងពីភាគីមួយទៅភាគីមួយទៀត ដែលជាគោលដៅនៃការសម្រេចប្រសិទ្ធិផលខាងផ្នែកសេដ្ឋកិច្ច ឬដើម្បីឆ្លើយតបទៅនឹងការកាត់បន្ថយការផ្គត់ផ្គង់ ដូចដែលបានគ្រោងទុកក្នុងការបិទរោងចក្រ។

មាត្រា២ វិធានការត្រួតពិនិត្យ

១- រួមបញ្ចូលក្នុងមាត្រា២A

២- ជំនួសដោយមាត្រា២B

៣- ជំនួសដោយមាត្រា២A

៤- ជំនួសដោយមាត្រា២A

៥- ចំពោះរយៈពេលត្រួតពិនិត្យម្តងឬច្រើនដង ភាគីទាំងឡាយអាចធ្វើការផ្ទេរផលិតផលដែលបាន គណនាទៅឱ្យភាគីដទៃ ដូចមានចែងនៅក្នុងមាត្រា២A ទៅ២F មាត្រា២H និង២J បង្ហាញថា: បរិមាណផលិតផលសរុប នៃសារធាតុដែលត្រូវត្រួតពិនិត្យរបស់ភាគីពាក់ព័ន្ធមិនត្រូវលើសពីកម្រិតនៃការផលិតដែលមានចែងនៅក្នុងមាត្រាខាងលើ។ ការផ្ទេរផលិតផលនេះនឹងត្រូវជូនដំណឹងទៅលេខាធិការដ្ឋានតាមរយៈភាគីពាក់ព័ន្ធនីមួយៗ ដោយលើកឡើងពីលក្ខខណ្ឌផ្ទេរនិងរយៈពេលអនុវត្ត។

៥ស្ទួន. ចំពោះរយៈពេលត្រួតពិនិត្យម្តងឬច្រើនដង ភាគីមិនស្ថិតក្នុងកថាខណ្ឌ១ នៃមាត្រា៥ អាចផ្ទេរផលិតផល ដែលមានបរិមាណស្ថិតក្នុងផ្នែកមួយនៃការគណនាដូចមានចែងនៅក្នុងមាត្រា២F ថាកម្រិតគណនាលើការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យក្នុងក្រុម១ នៃឧបសម្ព័ន្ធA ដែលត្រូវបញ្ជូនទៅឱ្យភាគីដទៃមិនត្រូវលើស០.២៥ គីឡូក្រាម សម្រាប់មនុស្សម្នាក់ក្នុងឆ្នាំ១៩៨៩ ហើយផលបូកសរុបនៃកម្រិតគណនានៃការប្រើប្រាស់សារធាតុរបស់ភាគីពាក់ព័ន្ធ មិនត្រូវលើសកម្រិតកំណត់លើការប្រើប្រាស់ដូចមានចែងក្នុងមាត្រា២F។ ភាគីពាក់ព័ន្ធនីមួយៗត្រូវផ្តល់ព័ត៌មានទៅលេខាធិការដ្ឋានចំពោះការផ្ទេរសារធាតុប្រើប្រាស់ដោយរៀបរាប់ពីលក្ខខណ្ឌនៃការដឹកជញ្ជូននិងពេលវេលានៃការអនុវត្ត។

៦- ភាគីទាំងឡាយដែលមិនបានស្ថិតនៅក្នុងមាត្រា៥ ដោយសារគ្រឿងបរិក្ខារសម្រាប់ផលិតសារធាតុដែលត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធA ឬ B កំពុងដំណើរការឬកំពុងជាប់កិច្ចព្រមព្រៀង ដែលបានធ្វើឡើងមុនថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៨៧ និងដែលបានអនុញ្ញាតដោយច្បាប់មុនថ្ងៃទី១ ខែមករា ឆ្នាំ១៩៨៧ អាចបន្ថែមគ្រឿងបរិក្ខារទៅលើផលិតផលឆ្នាំ១៩៨៦ របស់ខ្លួនសម្រាប់គោលបំណងនៃការកំណត់កម្រិតគណនាការផលិតសម្រាប់ឆ្នាំ១៩៨៦ ដែលបានចែងថា គ្រឿងបរិក្ខារទាំងនេះត្រូវបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩០ ហើយផលិតផលនេះមិនត្រូវលើស០.៥ គីឡូក្រាម នៃកម្រិតគណនាលើការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យសម្រាប់មនុស្សម្នាក់ៗទេ។

៧- ការផ្ទេរផលិតផលទាក់ទងនឹងកថាខណ្ឌ៥ ឬការបន្ថែមផលិតផលទាក់ទងនឹងកថាខណ្ឌ៦ ត្រូវជូនព័ត៌មានទៅលេខាធិការដ្ឋានឱ្យបានមុនពេលអនុវត្តការផ្ទេរឬការបន្ថែមផលិតផល។

៨(a)- ដូចមានបញ្ជាក់ក្នុងមាត្រា១(៦) នៃអនុសញ្ញា ភាគីទាំងឡាយដែលជាប្រទេសសមាជិកអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ អាចព្រមព្រៀងចូលរួមបំពេញកាតព្វកិច្ចលើការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យ ដូចមានចែងក្នុងមាត្រានេះ និងមាត្រា២A រហូតដល់មាត្រា២J ស្តីពីលក្ខខណ្ឌនៃកម្រិតគណនាលើការប្រើប្រាស់រួម មិនត្រូវលើសកម្រិតដែលតម្រូវដោយមាត្រានេះ និងមាត្រា២A រហូតដល់មាត្រា២J។ *រាល់កិច្ចព្រមព្រៀងអាចនឹងត្រូវបញ្ចូលបន្ថែមនូវកាតព្វកិច្ច ការប្រើប្រាស់ ឬការផលិតក្រោមមាត្រា២J ផ្តល់ដោយកម្រិតគណនាការប្រើប្រាស់ ឬការផលិតរបស់ភាគីមិនឱ្យលើសពីកម្រិតដែលមានចែងក្នុងមាត្រា២J។*

៨(b)- ភាគីនៃកិច្ចព្រមព្រៀង ត្រូវជូនដំណឹងទៅលេខាធិការដ្ឋានអំពីលក្ខខណ្ឌនៃកិច្ចព្រមព្រៀងឱ្យបានមុនកាលបរិច្ឆេទនៃការកាត់បន្ថយ ការប្រើប្រាស់ដែលទាក់ទងទៅនឹងកិច្ចព្រមព្រៀង។

៨(c)- កិច្ចព្រមព្រៀងនឹងមានប្រសិទ្ធភាព ប្រសិនបើប្រទេសជាសមាជិកអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់និងអង្គការពាក់ព័ន្ធ ដែលជាសមាជិករបស់ពិធីសារជូនព័ត៌មានទៅលេខាធិការដ្ឋាន អំពីការអនុវត្តរបស់គេ។

៩(a)- ផ្អែកទៅតាមការវាយតម្លៃដែលធ្វើឡើងដោយអនុលោមទៅតាមមាត្រា៦ ភាគីអាចធ្វើសេចក្តីសម្រេចៈ

i. ការកែតម្រូវទៅលើសក្តានុពល នៃការបំផ្លាញស្រទាប់អូហ្សូនដែលបានបញ្ជាក់ក្នុងឧបសម្ព័ន្ធA ឧបសម្ព័ន្ធB ឧបសម្ព័ន្ធC និង/ឬ ឧបសម្ព័ន្ធE នឹងត្រូវធ្វើឡើង បើដូច្នោះ តើការកែតម្រូវអ្វីដែលគួរធ្វើ?

ii. ការកែតម្រូវទៅលើសក្តានុពលចម្បងនៃការកើនឡើងកម្តៅផែនដីក្នុងក្រុមឧបសម្ព័ន្ធA ឧបសម្ព័ន្ធC និង ឧបសម្ព័ន្ធF នឹងត្រូវធ្វើឡើង បើដូច្នោះ តើការកែតម្រូវអ្វីដែលគួរធ្វើ?

iii. ការកែតម្រូវនិងការកាត់បន្ថយការផលិតឬការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យ គួរតែត្រូវមានការទទួលខុសត្រូវ បើដូច្នោះ តើការកែតម្រូវនិងការកាត់បន្ថយគួរមានទំហំ ចំនួន និងរយៈពេលប៉ុន្មាន។

៩(b)- សំណើសុំកែតម្រូវ ត្រូវផ្សព្វផ្សាយជាព័ត៌មានទៅភាគីទាំងឡាយតាមរយៈលេខាធិការដ្ឋាន ដែលយ៉ាងហោចណាស់ឱ្យបានរយៈពេល៦ខែ មុនកិច្ចប្រជុំនៃភាគីជាសមាជិក ដើម្បីស្នើសុំការអនុម័ត។

៩(c)- ក្នុងការធ្វើសេចក្តីសម្រេចនេះ ភាគីជាសមាជិកត្រូវប្រឹងប្រែងកំណត់នូវកិច្ចព្រមព្រៀងដោយការស្របមតិគ្នា។ ប្រសិនបើការប្រឹងប្រែងរកការព្រមព្រៀងគ្នាត្រូវធ្វើឡើងដោយអស់សមត្ថភាព ហើយទីបញ្ចប់ពុំមានការឯកភាពគ្នា សេចក្តីសម្រេចនេះនឹងត្រូវដោះស្រាយជាលើកចុងក្រោយ ដោយអនុម័តតាមការបោះឆ្នោតយកសំឡេង២ភាគ៣ នៃវត្តមានភាគីដែលចូលរួមប្រជុំ និងការបោះឆ្នោតតំណាងមតិភាគច្រើនទៅលើការអនុវត្តរបស់ភាគីតាមកថាខណ្ឌ១ នៃមាត្រា៥ និងការបោះឆ្នោតតំណាងមតិភាគច្រើនដែលមិនអនុវត្តតាមកថាខណ្ឌ១ នៃមាត្រា៥ នេះ។

៩(d)- សេចក្តីសម្រេចនេះ នឹងត្រូវចងក្រងសម្រាប់គ្រប់ភាគី បន្ទាប់ពីទំនាក់ទំនងទៅភាគីដោយតម្កល់ទុក។ ម្យ៉ាងវិញទៀត ការផ្តល់សេចក្តីសម្រេចនឹងចូលជាធរមានបន្ទាប់ពី៦ខែចាប់ពីថ្ងៃផ្សព្វផ្សាយ។

១០- ផ្អែកទៅតាមការវាយតម្លៃដែលធ្វើឡើងតាមមាត្រា៦ នៃពិធីសារនេះ និងយោងទៅតាមនីតិវិធីដែលបានចែងក្នុងមាត្រា៩ នៃអនុសញ្ញា ភាគីទាំងឡាយអាចធ្វើសេចក្តីសម្រេចៈ

១0a- តើសារធាតុណាត្រូវបន្ថែមឬដកចេញពីឧបសម្ព័ន្ធ នៃពិធីសារនេះ

១0b- យន្តការ ទំហំនិងពេលវេលា នៃវិធានការត្រួតពិនិត្យ នឹងត្រូវអនុវត្តចំពោះសារធាតុទាំងនោះ

១១- ទោះបីជាលក្ខខណ្ឌមានចែងនៅក្នុងមាត្រានេះ និងមាត្រា២A ដល់២J ក៏ដោយ ភាគីទាំងឡាយ អាចប្រកាន់នូវវិធានការតឹងរ៉ឹងជាងលក្ខខណ្ឌដែលតម្រូវឱ្យអនុវត្តដោយមាត្រាទាំងនេះ។

ការណែនាំពីការកែតម្រូវ

កិច្ចប្រជុំលើកទី២ ទី៤ ទី៧ ទី៩ ទី១១ និង១៩ នៃភាគីពិធីសារម៉ុងរ៉េអាល់ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន លើការវាយតម្លៃមានចែងក្នុងមាត្រា៦ នៃពិធីសារនេះ ការធ្វើវិសោធនកម្ម និងការកាត់បន្ថយនៃការផលិត និងការប្រើប្រាស់លើការត្រួតពិនិត្យសារធាតុក្នុងឧបសម្ព័ន្ធA B C និងE (អត្ថបទនេះបង្ហាញពីបណ្តុំផលប៉ះពាល់នៃគ្រប់ការកែតម្រូវទាំងអស់)

មាត្រា២A CFCs

១- ក្នុងអំឡុងពេល១២ខែដំបូង ចាប់ពីថ្ងៃទី១ ដែលពិធីសារនេះត្រូវចូលជាធរមានរហូតដល់រយៈពេល៧ខែ និងរយៈពេល១២ខែបន្ត ភាគីនីមួយៗត្រូវធានាឱ្យបាននូវកម្រិតគណនាលើការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យ ស្ថិតនៅក្នុងក្រុម១ នៃឧបសម្ព័ន្ធA មិនត្រូវលើសកម្រិតគណនាលើការប្រើប្រាស់នាឆ្នាំ១៩៨៦។ នៅពេលបញ្ចប់រយៈពេលដដែលនេះ សមាជិកនីមួយៗដែលបានផលិតសារធាតុទាំងនេះតិចឬច្រើន ត្រូវធានាឱ្យបាននូវកម្រិតគណនានៃផលិតផល មិនត្រូវលើសពីកម្រិតផលិតផលប៉ាន់ស្មាននាឆ្នាំ១៩៨៦ ឬអាចលើកលែងបាន ចំពោះកម្រិតផលិតផលប៉ាន់ស្មានដែលកើនឡើងតិចជាង១០%។ កំណើននេះត្រូវបានអនុញ្ញាតទៅតាមតម្រូវការជាមូលដ្ឋានរបស់ប្រទេសជាសមាជិកដែលអនុវត្តន៍តាមមាត្រា៥ និងសម្រាប់គោលបំណងនៃការបង្កលក្ខណៈគ្រប់គ្រាន់ និងងាយស្រួលដល់វិស័យឧស្សាហកម្ម។

២- ចាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ១៩៩១ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩២ ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតគណនាលើការប្រើប្រាស់និងការផលិតសារធាតុដែលត្រូវត្រួតពិនិត្យស្ថិតក្នុងក្រុម១ នៃឧបសម្ព័ន្ធA មិនត្រូវលើសពី១៥០% នៃកម្រិតគណនាលើការប្រើប្រាស់ និងការផលិតសារធាតុដែលត្រូវពិនិត្យក្នុងឆ្នាំ១៩៨៦ ហើយប្រការនេះនឹងមានប្រសិទ្ធភាពចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៣ ចំពោះរយៈពេលត្រួតពិនិត្យ នឹងចាប់ផ្តើមពីថ្ងៃទី១ ខែមករា រហូតដល់ថ្ងៃទី៣១ ខែធ្នូ រៀងរាល់ឆ្នាំ។

៣- ក្នុងរយៈពេល១២ខែដំបូង ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៤ និងរយៈពេល១២ខែបន្តបន្ទាប់ ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតគណនាលើការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យប្រចាំឆ្នាំ ស្ថិតក្នុងក្រុម១នៃឧបសម្ព័ន្ធA មិនត្រូវលើសពី២៥% នៃកម្រិតគណនាលើការផលិតក្នុងឆ្នាំ១៩៨៦។ ទោះបីយ៉ាងណាក៏ដោយ ដើម្បីបំពេញនូវតម្រូវការជាមូលដ្ឋាន នៃការអនុវត្តរបស់ភាគីជាសមាជិកតាមកថាខណ្ឌ១ នៃមាត្រា៥ កម្រិតគណនាការផលិតអាចលើសការកំណត់ នៃកម្រិតគណនាការផលិតនាឆ្នាំ១៩៨៦ រហូតដល់១០%។

៤- ក្នុងរយៈពេល១២ខែដំបូងចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៦ និងរយៈពេល១២ខែបន្តបន្ទាប់ ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតគណនាលើការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យក្នុងក្រុម១ នៃឧបសម្ព័ន្ធA មិនត្រូវលើសពីកម្រិតសូន្យ។ ក្នុងរយៈពេលដដែលនេះដែរ ការផលិតសារធាតុទាំងនេះតិចឬច្រើនរបស់ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតគណនាលើការផលិតសារធាតុមិនត្រូវលើសកម្រិតសូន្យ។ ទោះបីយ៉ាងណាក៏ដោយ ដើម្បីបំពេញនូវតម្រូវការជាមូលដ្ឋានក្នុងស្រុក នៃភាគីជាសមាជិកក្រោមកថាខណ្ឌ១ នៃមាត្រា៥ នោះកម្រិតគណនាការផលិតអាចលើសការកំណត់នៃកម្រិតការផលិតបរិមាណដូចគ្នាទៅនឹងការផលិតមធ្យមប្រចាំឆ្នាំនូវសារធាតុត្រូវត្រួតពិនិត្យ ក្នុងក្រុម១ នៃឧបសម្ព័ន្ធA សម្រាប់តម្រូវការជាមូលដ្ឋានក្នុងកំឡុងឆ្នាំ១៩៩៥ ទៅ១៩៩៧។ កថាខណ្ឌនេះ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវចំពោះបរិមាណសម្រាប់ធ្វើជាគោល ដែលភាគីសម្រេចអនុញ្ញាតឱ្យកម្រិតការផលិតឬការប្រើប្រាស់ឱ្យមានលក្ខណៈសមស្របទៅនឹងការប្រើប្រាស់ដែលបានព្រមព្រៀង។

៥- ក្នុងរយៈពេល១២ខែដំបូងចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០០៣ និងរយៈពេល១២ខែបន្តបន្ទាប់ ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតគណនាលើផលិតផលនៃសារធាតុដែលត្រូវត្រួតពិនិត្យក្នុងក្រុម១ នៃឧបសម្ព័ន្ធA ដោយផ្អែកលើតម្រូវការក្នុងស្រុកនៃភាគីនីមួយៗស្ថិតនៅក្នុងកថាខណ្ឌ១ នៃមាត្រា៥ មិនឱ្យលើសពី៨០% ក្នុងមួយឆ្នាំជាមធ្យម នៃផលិតផលសារធាតុទាំងនេះដោយផ្អែកលើតម្រូវការក្នុងស្រុកសម្រាប់ឆ្នាំ១៩៩៥ រហូតដល់ឆ្នាំ១៩៩៧។

៦- ក្នុងរយៈពេល១២ខែដំបូង ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០០៥ និងរយៈពេល១២ខែបន្តបន្ទាប់ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតគណនាលើផលិតផលនៃសារធាតុដែលត្រូវត្រួតពិនិត្យក្នុងក្រុម១នៃឧបសម្ព័ន្ធA ដោយផ្អែកលើតម្រូវការក្នុងស្រុក នៃភាគីដែលស្ថិតនៅក្នុងកថាខណ្ឌ១ នៃមាត្រា៥ មិនឱ្យលើសពី៥០% ក្នុងមួយឆ្នាំជាមធ្យម នៃផលិតផលសារធាតុទាំងនេះដោយផ្អែកលើតម្រូវការក្នុងស្រុកសម្រាប់ឆ្នាំ១៩៩៥ រហូតដល់ឆ្នាំ១៩៩៧។

៧- ក្នុងរយៈពេល១២ខែដំបូង ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០០៧ និងរយៈពេល១២ខែបន្តបន្ទាប់ ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតគណនាលើផលិតផលនៃសារធាតុដែលត្រូវត្រួតពិនិត្យក្នុងក្រុម១ នៃឧបសម្ព័ន្ធA ដោយផ្អែកលើតម្រូវការក្នុងស្រុក នៃភាគីដែលស្ថិតនៅក្នុងកថាខណ្ឌ១ នៃមាត្រា៥ មិនឱ្យលើសពី១៥% ក្នុងមួយឆ្នាំជាមធ្យម នៃផលិតផលសារធាតុទាំងនេះដោយផ្អែកលើតម្រូវការក្នុងស្រុកសម្រាប់ឆ្នាំ១៩៩៥ រហូតដល់ឆ្នាំ១៩៩៧។

៨- ក្នុងរយៈពេល១២ខែដំបូង ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១០ និងរយៈពេល១២ខែបន្តបន្ទាប់ ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតគណនាលើផលិតផលសារធាតុដែលត្រូវត្រួតពិនិត្យក្នុងក្រុម១ នៃឧបសម្ព័ន្ធA ដោយផ្អែកលើតម្រូវការក្នុងស្រុកនៃភាគីដែលស្ថិតនៅក្នុងកថាខណ្ឌ១ នៃមាត្រា៥ មិនឱ្យលើសពីសូន្យ ។

៩- ក្នុងគោលបំណងនៃការគណនាតម្រូវការក្នុងស្រុកក្រោមកថាខណ្ឌ១ នៃមាត្រានេះ។ ការគណនាមធ្យមភាគផលិតផលប្រចាំឆ្នាំដោយភាគីមួយរួមមានសិទ្ធិទទួលការផលិត ដែលបានផ្ទេរអនុលោមទៅតាមកថាខណ្ឌ៥ នៃមាត្រា២ និងលើកលែងសិទ្ធិទទួលការផលិតដោយអនុលោមទៅតាមកថាខណ្ឌ៥ នៃមាត្រា២។

មាត្រា២B ហាឡុង (Halons)

១- ក្នុងរយៈពេល១២ខែដំបូង ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៩២ និងរយៈពេល១២ខែបន្តបន្ទាប់ ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតគណនាលើការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យក្នុងក្រុមទី២ នៃឧបសម្ព័ន្ធA មិនត្រូវលើសពីកម្រិតគណនាលើការប្រើប្រាស់នាឆ្នាំ១៩៨៦។ ការផលិតសារធាតុតិចឬច្រើនក្នុងរយៈពេលដូចគ្នារបស់ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតគណនាលើការផលិតសារធាតុ មិនត្រូវលើសកម្រិតគណនាលើការផលិតនាឆ្នាំ១៩៨៦។ ទោះបីយ៉ាងណាក៏ដោយ ដើម្បីបំពេញនូវតម្រូវការជាមូលដ្ឋានក្នុងស្រុក នៃការអនុវត្តរបស់ភាគីជាសមាជិកដែលអនុវត្តតាមកថាខណ្ឌ១ នៃមាត្រា៥ នោះកម្រិតគណនាលើការផលិតអាចលើសការកំណត់នៃកម្រិតការផលិតឆ្នាំ១៩៨៦ រហូតដល់១០%។

២- ក្នុងរយៈពេល១២ខែដំបូង ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៤ និងរយៈពេល១២ខែបន្តបន្ទាប់ ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតគណនាលើការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យក្នុងក្រុម២ នៃឧបសម្ព័ន្ធA មិនត្រូវលើសពីកម្រិតសូន្យ។ ក្នុងរយៈពេលដដែលនេះដែរ ការផលិតសារធាតុទាំងនេះតិចឬច្រើនរបស់ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតគណនាលើការផលិតសារធាតុ មិនត្រូវលើសកម្រិតសូន្យ។ ទោះបីយ៉ាងណាក៏ដោយដើម្បីបំពេញនូវតម្រូវការជាមូលដ្ឋានក្នុងស្រុកនៃការអនុវត្តរបស់ភាគីជាសមាជិកក្រោមកថាខណ្ឌ១ នៃមាត្រា៥ នោះកម្រិតគណនាលើការផលិតរហូតដល់ ថ្ងៃទី១ ខែមករា ឆ្នាំ២០០២ អាចលើសការកំណត់នៃកម្រិតការផលិតឆ្នាំ១៩៨៦ រហូតដល់១៥% បន្ទាប់មកអាចលើសកម្រិតស្មើ និងកម្រិតមធ្យមប្រចាំឆ្នាំ នៃការផលិតនូវសារធាតុត្រូវត្រួតពិនិត្យក្នុងក្រុម២ នៃឧបសម្ព័ន្ធA ដើម្បីបំពេញនូវតម្រូវការមូលដ្ឋានក្នុងស្រុកសម្រាប់ឆ្នាំ១៩៩៥ រហូតដល់ឆ្នាំ១៩៩៧។ កថាខណ្ឌនេះមានវិសាលភាពចំពោះបរិមាណសម្រាប់ធ្វើជាគោល ដែលភាគីដែលសម្រេចអនុញ្ញាតឱ្យកម្រិតនៃការផលិតឬការប្រើប្រាស់ដែលចាំបាច់សមស្របទៅនឹងការប្រើប្រាស់ដែលបានព្រមព្រៀង។

៣- ក្នុងរយៈពេល១២ខែដំបូង ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០០៥ និងរយៈពេល១២ ខែបន្តបន្ទាប់ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតគណនាលើផលិតកម្មនៃសារធាតុដែលត្រូវត្រួតពិនិត្យក្នុងក្រុម២ នៃឧបសម្ព័ន្ធA ដោយផ្អែកលើតម្រូវការក្នុងស្រុក នៃការប្រតិបត្តិរបស់ភាគីនីមួយៗ នៅក្នុងកថាខណ្ឌ១ នៃមាត្រា៥ មិនឱ្យលើសពី៥០% នៃកម្រិតមធ្យមប្រចាំឆ្នាំនៃផលិតកម្មសារធាតុទាំងនេះដោយផ្អែកលើតម្រូវការក្នុងស្រុកសម្រាប់ឆ្នាំ១៩៩៥ រហូតដល់ឆ្នាំ១៩៩៧។

៤- ក្នុងរយៈពេល១២ខែដំបូង ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១០ និងរយៈពេល១២ ខែបន្តបន្ទាប់ ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតគណនាលើផលិតកម្ម នៃសារធាតុដែលត្រូវត្រួតពិនិត្យក្នុងក្រុម២ នៃឧបសម្ព័ន្ធA ដោយផ្អែកលើតម្រូវការក្នុងស្រុក នៃការប្រតិបត្តិរបស់ភាគីនីមួយៗ នៅក្នុងកថាខណ្ឌ១ នៃមាត្រា៥ មិនឱ្យលើសពីសូន្យ។

មាត្រា២C Halogenated CFCs

១- ក្នុងរយៈពេល១២ខែ ដែលចាប់ផ្តើមពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៣ ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតគណនានៃការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យក្នុងក្រុមទី២ នៃឧបសម្ព័ន្ធB មិនត្រូវលើស៨០% ជាប្រចាំឆ្នាំពីកម្រិតគណនាលើការប្រើប្រាស់នាឆ្នាំ១៩៨៩ទេ។ ក្នុងរយៈពេលដដែលនេះដែរ ការផលិតសារធាតុតិចឬច្រើនរបស់ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតគណនាលើការផលិតមិនត្រូវលើស៨០% នៃកម្រិតគណនាលើការផលិតសារធាតុនាឆ្នាំ១៩៨៩។ ទោះបីយ៉ាងណាក៏ដោយ ដើម្បីបំពេញនូវតម្រូវការមូលដ្ឋានមូលដ្ឋានក្នុងស្រុក នៃភាគីជាសមាជិកដែលអនុវត្តតាមកថាខណ្ឌ១ នៃមាត្រា៥ នោះកម្រិតគណនាលើការផលិតអាចលើសការកំណត់ នៃកម្រិតការផលិតនៅឆ្នាំ១៩៨៩ រហូតដល់១០។

២- ក្នុងរយៈពេល១២ខែដំបូង ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៤ និងរយៈពេល១២ខែបន្តបន្ទាប់ ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតគណនាលើការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យប្រចាំឆ្នាំស្ថិតក្នុងក្រុម១ នៃឧបសម្ព័ន្ធB មិនត្រូវលើសពី២៥ នៃកម្រិតគណនាលើការផលិតក្នុងឆ្នាំ១៩៨៩។ ក្នុងរយៈពេលដដែលនេះដែរការផលិតសារធាតុតិចឬច្រើនរបស់ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតប៉ាន់ស្មានលើការផលិតសារធាតុមិនត្រូវលើសកម្រិត២៥% នៃកម្រិតគណនាលើការផលិតសារធាតុនាឆ្នាំ១៩៨៩។ ទោះបីយ៉ាងណាក៏ដោយ ដើម្បីបំពេញនូវតម្រូវការជាមូលដ្ឋានក្នុងស្រុក នៃភាគីជាសមាជិកក្រោមកថាខណ្ឌ១ នៃមាត្រា៥ កម្រិតគណនាការផលិតអាចលើសការកំណត់នៃកម្រិតគណនាការផលិត នាឆ្នាំ១៩៨៩ រហូតដល់១០%។

៣- ក្នុងរយៈពេល១២ខែដំបូង ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៦ និងរយៈពេល១២ខែបន្តបន្ទាប់ ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតគណនាលើការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យស្ថិតក្នុងក្រុម១ នៃឧបសម្ព័ន្ធB មិនត្រូវលើសពីកម្រិតសូន្យ។ ក្នុងរយៈពេលដដែលនេះដែរ ការផលិតសារធាតុតិចឬច្រើនរបស់ភាគីនីមួយៗ ត្រូវធានាឱ្យបានកម្រិតគណនាលើការផលិតសារធាតុមិនត្រូវលើសកម្រិតសូន្យ។ ទោះបីយ៉ាងណាក៏ដោយ ដើម្បីបំពេញនូវតម្រូវការជាមូលដ្ឋាន នៃការអនុវត្តរបស់ភាគីជាសមាជិកក្រោមកថាខណ្ឌ១ នៃមាត្រា៥ កម្រិតគណនាការផលិតអាចលើសកាកំណត់ នៃកម្រិតគណនាការផលិតហូតដល់ថ្ងៃទី១ ខែមករា ឆ្នាំ២០០៣ កំណត់មិនឱ្យលើសពី១៥% នៃការផលិតនៅឆ្នាំ១៩៨៩។ បន្ទាប់មកការលើសបរិមាណចំនួនកំណត់ស្មើ៨០% នៃកម្រិតមធ្យមប្រចាំឆ្នាំនៃការផលិតសារធាតុដែលត្រូវត្រួតពិនិត្យនៅក្នុងក្រុម១ នៃឧបសម្ព័ន្ធB សម្រាប់តម្រូវការក្នុងស្រុកសម្រាប់ឆ្នាំ១៩៩៨ រហូតដល់ឆ្នាំ២០០០។ កថាខណ្ឌនេះ នឹងធ្វើកាកម្រិតនូវដែនដែលភាគីធ្វើការសម្រេចក្នុងការអនុញ្ញាតកម្រិតផលិតផលឬការប្រើប្រាស់ជាចាំបាច់។

៤- ក្នុងរយៈពេល១២ខែដំបូង ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០០៧ និងរយៈពេល១២ខែបន្តបន្ទាប់ ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតគណនាលើផលិតកម្មនៃសារធាតុដែលត្រូវត្រួតពិនិត្យក្នុងក្រុម១ នៃឧបសម្ព័ន្ធB ដោយផ្អែកលើតម្រូវការក្នុងស្រុក នៃភាគីជាសមាជិកដែលស្ថិតក្រោមកថាខណ្ឌ១ នៃ

18

មាត្រា៥ មិនឱ្យលើសពី១៥% ក្នុងមួយឆ្នាំជាមធ្យមនៃផលិតកម្មសារធាតុទាំងនេះដោយផ្អែកលើតម្រូវការក្នុងស្រុកសម្រាប់ឆ្នាំ១៩៩៨ រហូតដល់ឆ្នាំ២០០០។

៥- ក្នុងរយៈពេល១២ខែដំបូង ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១០ និងរយៈពេល១២ខែបន្តបន្ទាប់ ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតគណនាលើការផលិតកម្ម នៃសារធាតុដែលត្រូវត្រួតពិនិត្យក្នុងក្រុម១ នៃឧបសម្ព័ន្ធB ដោយផ្អែកលើតម្រូវការក្នុងស្រុក នៃភាគីដែលស្ថិតនៅក្នុងកថាខណ្ឌ១ នៃមាត្រា៥ មិនឱ្យលើសពីសូន្យ ។

មាត្រា២D កាបូនតេត្រាក្លរ៉ាយ (Carbon Tetrachloride)

១- ក្នុងរយៈពេល១២ខែ ដែលចាប់ផ្តើមពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៥ ភាគីនីមួយៗ ត្រូវធានាឱ្យបានជាប្រចាំនូវកម្រិតគណនាលើការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យក្នុងក្រុមទី២ នៃឧបសម្ព័ន្ធB មិនត្រូវលើស១៥% ពីកម្រិតគណនាលើការប្រើប្រាស់នាឆ្នាំ១៩៨៩ទេ។ ក្នុងរយៈពេលដដែលនេះដែរ ការផលិតសារធាតុតិចឬច្រើនរបស់ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតគណនាលើការផលិតសារធាតុមិនត្រូវលើស១៥% នៃកម្រិតគណនាលើការផលិតសារធាតុនាឆ្នាំ១៩៨៩។ ទោះបីយ៉ាងណាក៏ដោយ ដើម្បីបំពេញនូវតម្រូវការមូលដ្ឋានក្នុងស្រុក នៃភាគីជាសមាជិកដែលអនុវត្តតាមកថាខណ្ឌ១ នៃមាត្រា៥ នោះកម្រិតគណនាលើការផលិតអាចលើសការកំណត់ នៃកម្រិតការផលិតផលនៅឆ្នាំ១៩៨៩ រហូតដល់១០ភាគរយ។

២- ក្នុងរយៈពេល១២ខែដំបូង ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៦ និងរយៈពេល១២ខែបន្តបន្ទាប់ ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតគណនាលើការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យស្ថិតក្នុងក្រុម១ នៃឧបសម្ព័ន្ធB មិនត្រូវលើសពីកម្រិតសូន្យ។ ក្នុងរយៈពេលដដែលនេះដែរ ការផលិតសារធាតុរបស់ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតគណនាលើការផលិតសារធាតុ មិនត្រូវលើសកម្រិតសូន្យ។ ទោះបីយ៉ាងណាក៏ដោយ ដើម្បីបំពេញនូវតម្រូវការមូលដ្ឋានក្នុងស្រុករបស់ភាគីជាសមាជិកក្រោមកថាខណ្ឌ១ នៃមាត្រា៥ កម្រិតគណនាការផលិតអាចលើសការកំណត់នៃកម្រិតគណនាការផលិតនាឆ្នាំ១៩៨៩ រហូតដល់១៥%។ កថាខណ្ឌនេះ មានវិសាលភាពសម្រាប់ភាគីសម្រេចអនុញ្ញាតកម្រិតនៃការផលិត ឬការប្រើប្រាស់ដែលត្រូវការជាចាំបាច់ដូចដែលបានព្រមព្រៀង។

មាត្រា២E 1,1,1 ទ្រីក្លរ៉ូអេតាន (ម៉េទីលក្លរ៉ូហ្វម)

១- ក្នុងរយៈពេល១២ខែ ដែលចាប់ផ្តើមពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៣ ភាគីនីមួយៗត្រូវធានាឱ្យបាននូវកម្រិតគណនាលើការប្រើប្រាស់សារធាតុប្រចាំឆ្នាំដែលត្រូវត្រួតពិនិត្យក្នុងក្រុមទី៣ នៃឧបសម្ព័ន្ធB មិនត្រូវលើសកម្រិតគណនាលើការប្រើប្រាស់នាឆ្នាំ១៩៨៩ទេ។ ក្នុងរយៈពេលដដែលនេះដែរ ការផលិតសារធាតុតិចឬច្រើនរបស់ភាគីនីមួយៗត្រូវធានាឱ្យបាននូវកម្រិតគណនា លើការផលិតសារធាតុប្រចាំឆ្នាំមិនត្រូវលើសកម្រិតគណនាលើការផលិតសារធាតុនាឆ្នាំ១៩៨៩។ ទោះបីយ៉ាងណាក៏ដោយ ដើម្បី

បំពេញនូវតម្រូវការមូលដ្ឋានក្នុងស្រុករបស់ភាគីជាសមាជិកដែលអនុវត្តតាមកថាខណ្ឌ១ នៃមាត្រា៥ នោះ កម្រិតគណនាលើការផលិតអាចលើសការកំណត់នៃកម្រិតការផលិតនៅឆ្នាំ១៩៨៩ រហូតដល់១០%។

២- ក្នុងរយៈពេល១២ខែដំបូងចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៤ និងរយៈពេល១២ខែបន្តបន្ទាប់ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតគណនាលើការប្រើប្រាស់សារធាតុប្រចាំឆ្នាំដែលត្រូវពិនិត្យស្ថិតក្នុងក្រុម៣នៃឧបសម្ព័ន្ធB មិនត្រូវលើសពី៥០% ពីកម្រិតគណនាលើការប្រើប្រាស់ក្នុងឆ្នាំ១៩៨៩។ ក្នុងរយៈពេលដដែលនេះដែរ ការផលិតសារធាតុរបស់ភាគីនីមួយៗ ត្រូវធានាចំពោះកម្រិតគណនាលើការផលិតសារធាតុប្រចាំឆ្នាំមិនត្រូវលើសកម្រិត៥០% នៃកម្រិតគណនាលើការផលិតសារធាតុនាឆ្នាំ១៩៨៩។ ទោះបីយ៉ាងណាក៏ដោយ ដើម្បីបំពេញនូវតម្រូវការមូលដ្ឋានក្នុងស្រុករបស់ភាគីជាសមាជិកស្ថិតក្រោមកថាខណ្ឌ១ នៃមាត្រា៥ កម្រិតគណនាការផលិតអាចលើសការកំណត់ នៃកម្រិតគណនាការផលិតនាឆ្នាំ១៩៨៩ រហូតដល់១០%។

៣- ក្នុងរយៈពេល១២ខែដំបូង ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៦ និងរយៈពេល១២ខែបន្តបន្ទាប់ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតគណនាលើការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យស្ថិតក្នុងក្រុម៣នៃឧបសម្ព័ន្ធB មិនត្រូវលើសពីកម្រិតសូន្យ។ ក្នុងរយៈពេលដដែលនេះដែរ ការផលិតសារធាតុរបស់ភាគីនីមួយៗ ត្រូវធានាចំពោះកម្រិតគណនាលើការផលិតសារធាតុមិនត្រូវលើសកម្រិតសូន្យ។ ទោះបីយ៉ាងណាក៏ដោយ ដើម្បីបំពេញនូវតម្រូវការមូលដ្ឋានក្នុងស្រុករបស់ភាគីជាសមាជិកស្ថិតក្នុងកថាខណ្ឌ១ នៃមាត្រា៥ កម្រិតគណនាការផលិតអាចលើសការកំណត់នៃកម្រិតគណនាការផលិតនាឆ្នាំ១៩៨៩ រហូតដល់១៥%។ កថាខណ្ឌនេះ មានវិសាលភាពចំពោះភាគីសម្រេចអនុញ្ញាតកម្រិតនៃការផលិត ឬការប្រើប្រាស់ចាំបាច់ដែលបានព្រមព្រៀង។

មាត្រា២F អ៊ីដ្រូក្លរ៉ូហ្លុយអរ៉ូកាបូន (Hydrochloroflurocarbons)

១- ក្នុងរយៈពេល១២ខែដំបូង ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៦ និងរយៈពេល១២ខែ បន្តបន្ទាប់ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតគណនាលើការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យស្ថិតក្នុងក្រុម១ នៃឧបសម្ព័ន្ធC មិនត្រូវលើសពីកម្រិតដូចខាងក្រោម៖

(a) ២.៨% នៃកម្រិតគណនាលើការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យក្នុងក្រុម១ នៃឧបសម្ព័ន្ធA នាឆ្នាំ១៩៨៩។

(b) កម្រិតគណនាលើការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យក្នុងក្រុម១ នៃឧបសម្ព័ន្ធC នាឆ្នាំ ១៩៨៩។

២- ក្នុងរយៈពេល១២ខែដំបូង ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០០៤ និងរយៈពេល១២ខែបន្តបន្ទាប់ ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតគណនាជាប្រចាំលើការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យស្ថិតក្នុងក្រុម១ នៃឧបសម្ព័ន្ធC មិនត្រូវលើសពី៦៥% នៃចំនួនដែលបានចែងក្នុងកថាខណ្ឌ១ នៃមាត្រានេះ។

(a) ផលបូកកម្រិតប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យក្នុងក្រុម១នៃឧបសម្ព័ន្ធC ឆ្នាំ១៩៨៩ និង ២.៨ % នៃកម្រិតប៉ាន់ស្មានការប្រើប្រាស់ឆ្នាំ១៩៨៩ ក្នុងក្រុម១នៃឧបសម្ព័ន្ធA

(b) ផលបូកកម្រិតផលិតសារធាតុដែលត្រូវត្រួតពិនិត្យក្នុងក្រុម១នៃឧបសម្ព័ន្ធC ឆ្នាំ១៩៨៩ និង២.៨% នៃកម្រិតគណនាការផលិតឆ្នាំ១៩៨៩ ក្នុងក្រុម១នៃឧបសម្ព័ន្ធA។ ទោះបីជាយ៉ាងណា ដើម្បីបំពេញតាមតម្រូវក្នុងស្រុក ភាគីដែលអនុវត្តក្រោមកថាខណ្ឌ១ នៃមាត្រា៥ ការប៉ាន់ស្មានកម្រិតផលិតសារធាតុអាចលើសពីការកម្រិតហូតដល់១៥% នៃកម្រិតគណនានៃសារធាតុដែលត្រួតពិនិត្យក្នុងក្រុម១នៃឧបសម្ព័ន្ធC ដែលមានបង្ហាញដូចខាងលើ។

៣- ក្នុងរយៈពេល១២ខែ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០០៤ និងរយៈពេល១២ខែបន្តបន្ទាប់ ភាគីនីមួយៗត្រូវធានាឱ្យបាននូវកម្រិតគណនាលើការប្រើប្រាស់សារធាតុ ដែលត្រូវត្រួតពិនិត្យស្ថិតក្នុងក្រុម១នៃឧបសម្ព័ន្ធC មិនត្រូវលើសពី៦៥% នៃចំនួនដែលបានចែងក្នុងកថាខណ្ឌ១ នៃមាត្រានេះ។

៤- ក្នុងរយៈពេល១២ខែដំបូង ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១០ និងរយៈពេល១២ខែបន្តបន្ទាប់ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតគណនាលើការប្រើប្រាស់សារធាតុប្រចាំឆ្នាំដែលត្រូវត្រួតពិនិត្យស្ថិតក្នុងក្រុម១ នៃឧបសម្ព័ន្ធC មិនត្រូវលើសពី២៥% នៃចំនួនដែលបានចែងក្នុងកថាខណ្ឌ១នៃមាត្រានេះ។ ភាគីដែលផលិតសារធាតុមួយប្រភេទឬច្រើនក្នុងរយៈពេលដដែល ត្រូវធានាឱ្យបាននូវកម្រិតគណនាលើការផលិតសារធាតុត្រូវត្រួតពិនិត្យស្ថិតក្នុងក្រុម១ នៃឧបសម្ព័ន្ធC មិនត្រូវលើសពីកម្រិត២៥% ដែលបានចែងក្នុងកថាខណ្ឌ១នៃមាត្រានេះ។ ទោះបីជាយ៉ាងណា ដើម្បីបំពេញតាមតម្រូវក្នុងស្រុក ភាគីដែលអនុវត្តក្រោមកថាខណ្ឌ១នៃមាត្រា៥ ការគណនាកម្រិតផលិតសារធាតុអាចលើសពីការកម្រិតហូតដល់១០% នៃការប៉ាន់ស្មានកម្រិតនៃសាធាតុដែលត្រួតពិនិត្យក្នុងក្រុម១នៃឧបសម្ព័ន្ធC ដែលមានក្នុងកថាខណ្ឌ២។

៥- ក្នុងរយៈពេល១២ខែដំបូង ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០ និងរយៈពេល១២ខែបន្តបន្ទាប់ ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតគណនាជាប្រចាំលើការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យស្ថិតក្នុងក្រុម១នៃឧបសម្ព័ន្ធC មិនត្រូវលើសពីកម្រិត០.៥% នៃចំនួនដែលបានចែងក្នុងកថាខណ្ឌ១នៃមាត្រានេះ។ ទោះបីជាយ៉ាងណាក៏ដោយ ការប្រើប្រាស់នេះគឺកម្រិតសម្រាប់តែសេវាកម្មម៉ាស៊ីនត្រជាក់ និងឧបករណ៍ត្រជាក់ដែលមានស្រាប់តែប៉ុណ្ណោះ។

៦- ក្នុងរយៈពេល១២ខែដំបូង ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០៣០ និងរយៈពេល១២ខែបន្តបន្ទាប់ ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតគណនាលើការប្រើប្រាស់សារធាតុប្រចាំឆ្នាំដែលត្រូវត្រួតពិនិត្យស្ថិតក្នុងក្រុម១នៃឧបសម្ព័ន្ធC មិនត្រូវលើសពីកម្រិតសូន្យ។

៧- ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៦ ភាគីនីមួយៗត្រូវធានាឱ្យបាននូវៈ

(a) ការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យស្ថិតក្នុងក្រុម១ នៃឧបសម្ព័ន្ធC ត្រូវបានកំណត់ទៅនឹងការអនុវត្តនៅពេលដែលជម្រើសសារធាតុដែលមាននិរន្តភាពសម្រាប់បរិស្ថានឬក៏បច្ចេកវិទ្យាមិនអាចរកបាន។

(b) ការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យស្ថិតក្នុងក្រុម១នៃឧបសម្ព័ន្ធC មិនត្រូវឱ្យប្រាសចាកពីការអនុវត្តបច្ចុប្បន្នទៅលើសារធាតុដែលត្រូវត្រួតពិនិត្យ ស្ថិតក្នុងឧបសម្ព័ន្ធA ឧបសម្ព័ន្ធB និងឧបសម្ព័ន្ធC លើកលែងតែក្នុងករណីចាំបាច់ ដើម្បីការពារជីវិតនិងសុខភាពមនុស្ស។

(c) សារធាតុដែលត្រូវត្រួតពិនិត្យស្ថិតក្នុងក្រុម១ នៃឧបសម្ព័ន្ធC ត្រូវបានជ្រើសរើសសម្រាប់ប្រើប្រាស់ក្នុងលក្ខណៈកាត់បន្ថយការបំផ្លាញស្រទាប់អូហ្សូន រួមទាំងការគិតគូរពីបញ្ហាបរិស្ថាន សុវត្ថិភាព និងសេដ្ឋកិច្ច។

មាត្រា២G អ៊ីដ្រូប្រ៉ូម៉ូភ្លុយអរ៉ូកាបូន (Hydrobromofluorocabons)

ក្នុងរយៈពេល១២ខែដំបូង ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៦ និងរយៈពេល១២ខែបន្តបន្ទាប់ ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតគណនាលើការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យស្ថិតក្នុងក្រុម២ នៃឧបសម្ព័ន្ធC មិនត្រូវលើសពីកម្រិតសូន្យ។ ក្នុងរយៈពេលដដែលនេះដែរ ការផលិតសារធាតុរបស់ភាគីនីមួយៗ ត្រូវធានាចំពោះកម្រិតគណនាលើការផលិតសារធាតុមិនត្រូវលើសកម្រិតសូន្យ។ កថាខណ្ឌនេះ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវសម្រាប់ភាគីសម្រេចអនុញ្ញាតកម្រិត នៃការផលិតឬការប្រើប្រាស់មានលក្ខណៈសមស្របទៅនឹងការប្រើប្រាស់ដែលបានព្រមព្រៀងដោយពួកគេ។

មាត្រា២H ម៉េទីលប្រូម៉ាយ (Methyl bromide)

១- ក្នុងរយៈពេល១២ខែដំបូង ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៥ និងរយៈពេល១២ខែបន្តបន្ទាប់ ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតគណនាលើការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យស្ថិតក្នុងឧបសម្ព័ន្ធE មិនត្រូវលើសពីកម្រិតគណនាលើការប្រើប្រាស់នាឆ្នាំ១៩៩១។ ក្នុងរយៈពេលដដែលនេះ ការផលិតសារធាតុប្រចាំឆ្នាំរបស់ភាគីនីមួយៗ ត្រូវធានាចំពោះកម្រិតគណនាលើការផលិតសារធាតុមិនត្រូវលើសកម្រិតគណនាលើការផលិតសារធាតុក្នុងឆ្នាំ១៩៩១។ ទោះបីយ៉ាងណាក៏ដោយ ដើម្បីបំពេញនូវតម្រូវការជាមូលដ្ឋាននៃការអនុវត្តរបស់ភាគីជាសមាជិកតាមកថាខណ្ឌ១នៃមាត្រា៥ កម្រិតគណនាការផលិតអាចលើសការកំណត់ នៃកម្រិតគណនាការផលិតនាឆ្នាំ១៩៩១ រហូតដល់១០%។

២- ក្នុងរយៈពេល១២ខែដំបូង ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៩ និងរយៈពេល១២ខែបន្តបន្ទាប់ ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតគណនាលើការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យស្ថិតក្នុងឧបសម្ព័ន្ធE មិនត្រូវលើស៧៥% ពីកម្រិតគណនាលើការប្រើប្រាស់នាឆ្នាំ១៩៩១។ ក្នុងរយៈពេលដដែលនេះដែរ ការផលិតសារធាតុប្រចាំឆ្នាំរបស់ភាគីនីមួយៗ ត្រូវធានាចំពោះកម្រិតគណនាលើការផលិតសារធាតុមិនត្រូវលើស៧៥% កម្រិតគណនាលើការផលិតសារធាតុក្នុងឆ្នាំ១៩៩១។ ទោះបីយ៉ាងណាក៏ដោយ ដើម្បីបំពេញនូវតម្រូវការជាមូលដ្ឋាននៃការអនុវត្តរបស់ភាគីជាសមាជិកតាមកថាខណ្ឌ១ នៃមាត្រា៥ កម្រិតគណនាការផលិតអាចលើសការកំណត់នៃកម្រិតគណនាការផលិតនាឆ្នាំ១៩៩១ រហូតដល់១០%។

៣- ក្នុងរយៈពេល១២ខែដំបូង ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០០១ និងរយៈពេល១២ខែបន្តបន្ទាប់ ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតគណនាលើការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យស្ថិតក្នុងឧបសម្ព័ន្ធA មិនត្រូវលើស៥០% ពីកម្រិតគណនាលើការប្រើប្រាស់នាឆ្នាំ១៩៩១។ ក្នុងរយៈពេលដដែលនេះដែរ ការផលិតសារធាតុប្រចាំឆ្នាំរបស់ភាគីនីមួយៗ ត្រូវធានាចំពោះកម្រិតគណនាលើការផលិត

សារធាតុមិនត្រូវលើស៥០% កម្រិតគណនាលើការផលិតសារធាតុក្នុងឆ្នាំ១៩៩១។ ទោះបីយ៉ាងណាក៏ដោយដើម្បីបំពេញនូវតម្រូវការជាមូលដ្ឋាន នៃការអនុវត្តរបស់ភាគីជាសមាជិកតាមកថាខណ្ឌ១ នៃមាត្រា៥ កម្រិតគណនាការផលិតអាចលើសការកំណត់ នៃកម្រិតប៉ាន់ស្មានការផលិតនាឆ្នាំ១៩៩១ ហូតដល់១០%។

៤- ក្នុងរយៈពេល១២ខែដំបូង ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០០៣ និងរយៈពេល១២ខែ បន្តបន្ទាប់ ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតគណនាលើការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធE មិនត្រូវលើស៣០% ពីកម្រិតគណនាលើការប្រើប្រាស់នាឆ្នាំ១៩៩១។ ក្នុងរយៈពេលដដែលនេះ ការផលិតសារធាតុប្រចាំឆ្នាំរបស់ភាគីនីមួយៗ ត្រូវធានាចំពោះកម្រិតគណនាលើការផលិតសារធាតុមិនត្រូវលើស៣០% នៃកម្រិតគណនាលើការផលិតសារធាតុក្នុងឆ្នាំ១៩៩១។ ទោះបីយ៉ាងណាក៏ដោយ ដើម្បីបំពេញនូវតម្រូវការជាមូលដ្ឋាននៃការអនុវត្តរបស់ភាគីជាសមាជិកតាមកថាខណ្ឌ១ នៃមាត្រា៥ កម្រិតគណនាការផលិតអាចលើសការកំណត់នៃកម្រិតគណនាការផលិតនាឆ្នាំ១៩៩១ ហូតដល់១០%។

៥- ក្នុងរយៈពេល១២ខែដំបូង ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០០៥ និងរយៈពេល១២ខែបន្តបន្ទាប់ ភាគីនីមួយៗត្រូវធានាឱ្យបាននូវកម្រិតគណនាលើការប្រើប្រាស់សារធាតុ ដែលត្រូវត្រួតពិនិត្យស្ថិតក្នុងឧបសម្ព័ន្ធE មិនត្រូវលើសសូន្យ។ ក្នុងរយៈពេលដដែលនេះដែរ ការផលិតសារធាតុប្រចាំឆ្នាំរបស់ភាគីនីមួយៗ ត្រូវធានាចំពោះកម្រិតគណនាលើការផលិតសារធាតុមិនត្រូវលើសសូន្យ។ ទោះបីយ៉ាងណាក៏ដោយ ដើម្បីបំពេញនូវតម្រូវការជាមូលដ្ឋាននៃការអនុវត្តរបស់ភាគីជាសមាជិកតាមកថាខណ្ឌ១ នៃមាត្រា៥ កម្រិតគណនាការផលិតហូតដល់ថ្ងៃទី១ ខែមករា ឆ្នាំ២០០២ អាចលើសការកំណត់នៃកម្រិតគណនាការផលិតនាឆ្នាំ១៩៩១ ហូតដល់១៥%។ បន្ទាប់មកទៀតអាចលើសបរិមាណប្រចាំឆ្នាំចំនួន១ដង នៃការផលិតសារធាតុត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធE សម្រាប់តម្រូវការក្នុងស្រុកក្នុងកំឡុងឆ្នាំ១៩៩៥ ដល់ឆ្នាំ១៩៩៨។ ក្នុងកថាខណ្ឌនេះនឹងជួយកាត់បន្ថយដល់ភាគីក្នុងការអនុញ្ញាតការផលិតឬប្រើប្រាស់ដែលជាការចាំបាច់ដែលបានព្រមព្រៀង។

៥ស្ទួន- ក្នុងរយៈពេល១២ខែដំបូង ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០០៥ និងរយៈពេល១២ខែបន្តបន្ទាប់ ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតគណនាលើផលិតផលសារធាតុដែលត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធE ដោយផ្អែកលើតម្រូវការក្នុងស្រុក នៃការប្រតិបត្តិរបស់ភាគីនីមួយៗនៅក្នុងកថាខណ្ឌ១ នៃមាត្រា៥ មិនឱ្យលើសពី៨០% ធៀបទៅកម្រិតមធ្យមប្រចាំឆ្នាំ នៃការផលិតសារធាតុទាំងនេះដោយផ្អែកលើតម្រូវការក្នុងស្រុកសម្រាប់ឆ្នាំ១៩៩៥ ហូតដល់ឆ្នាំ១៩៩៨។

៥ ter- ក្នុងរយៈពេល១២ខែដំបូង ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៥ និងរយៈពេល១២ខែបន្តបន្ទាប់ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតគណនាលើផលិតកម្ម នៃសារធាតុដែលត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធE ដោយផ្អែកលើតម្រូវការក្នុងស្រុក នៃការប្រតិបត្តិរបស់ភាគីនីមួយៗនៅក្នុងកថាខណ្ឌ១ នៃមាត្រា៥ មិនឱ្យលើសពីសូន្យ ។

៦- កម្រិតគណនានៃការប្រើប្រាស់ និងផលិតកម្មក្រោមមាត្រានេះមិនរួមបញ្ចូលបរិមាណប្រើប្រាស់ដោយភាគីសម្រាប់បំបាត់កត្តាចង្រៃ និងក្នុងទម្រង់រៀបចំការដឹកជញ្ជូន។

មាត្រា២I ប្រូម៉ូក្លរ៉ូមេតាន (Bromochloromethane)

ក្នុងរយៈពេល១២ខែដំបូង ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០០២ និងរយៈពេល១២ខែបន្តបន្ទាប់ ភាគីនីមួយៗ ត្រូវធានាឱ្យបាននូវកម្រិតគណនាលើផលិតកម្ម និងការប្រើប្រាស់នៃសារធាតុដែលត្រូវពិនិត្យក្នុងក្រុម៣នៃឧបសម្ព័ន្ធC មិនឱ្យលើសពីសូន្យ។ ក្នុងកថាខណ្ឌនេះ និងជួយដល់ភាគីក្នុងការអនុញ្ញាតផលិត ឬប្រើប្រាស់ដែលជាការចាំបាច់ដែលបានព្រមព្រៀងដោយពួកគេ។

មាត្រា២J អ៊ីដ្រូក្លុយអរូកាបូន (Hydrofluorocarbons)

១- ភាគីត្រូវធានាថា ក្នុងរយៈពេល២៤ខែ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ និងរាល់រយៈពេល១២ខែបន្ទាប់ កម្រិតគណនានៃការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យដែលមានក្នុងឧបសម្ព័ន្ធF ខ្នាតគិតជា CO_2 equivalents នឹងធានាមិនឱ្យលើសភាគរយដែលបានកំណត់តាមឆ្នាំ ដូចមានក្នុងកថាខណ្ឌរងពី (a) ដល់ (e) នៃកម្រិតគណនានៃការប្រើប្រាស់មធ្យមប្រចាំឆ្នាំក្នុងឧបសម្ព័ន្ធF សម្រាប់ឆ្នាំ២០១១ ២០១២ និង២០១៣ រួមនឹង១៥% នៃកម្រិតប្រើប្រាស់ក្នុងឧសម្ព័ន្ធC ក្រុម១ សារធាតុត្រូវត្រួតពិនិត្យដែលបានកំណត់ក្នុងកថាកខណ្ឌ១ មាត្រា ២F ខ្នាតគិតជា CO_2 equivalents:

(a) ២០១៩ ដល់ ២០២៣ : ៩០%
(b) ២០២៤ ដល់ ២០២៨ : ៦០%
(c) ២០២៩ ដល់ ២០៣៣ : ៣០%
(d) ២០៣៤ ដល់ ២០៣៥ : ២០%
(e) ២០៣៦ និងបន្ទាប់មក : ១៥%

២- ទោះបីជាមានកថាខណ្ឌ១នៃមាត្រានេះ ភាគីច្រើនអាចសម្រេចចិត្តថា ភាគីមួយត្រូវធានាថាក្នុងរយៈពេល១២ខែ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០ និងរាល់រយៈពេល១២បន្តបន្ទាប់ កម្រិតគណនានៃការប្រើប្រាស់សារធាតុត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធF គិតជា CO_2 equivalents មិនឱ្យលើសភាគរយដែលបានកំណត់តាមឆ្នាំ ដូចមានក្នុងកថាខណ្ឌរងពី (a) ដល់ (e) នៃកម្រិតគណនានៃការប្រើប្រាស់មធ្យមប្រចាំឆ្នាំក្នុងឧបសម្ព័ន្ធF សម្រាប់ឆ្នាំ២០១១ ២០១២ និង២០១៣ រួមនឹង ២៥%នៃកម្រិតប្រើប្រាស់ក្នុងឧសម្ព័ន្ធC ក្រុម១ សារធាតុត្រូវត្រួតពិនិត្យដែលបានកំណត់ក្នុងកថាកខណ្ឌ១ មាត្រា ២F ខ្នាតគិតជា CO_2 equivalents:

(a) ២០១៩ ដល់ ២០២៣ : ៩០%
(b) ២០២៤ ដល់ ២០២៨ : ៦០%
(c) ២០២៩ ដល់ ២០៣៣ : ៣០%
(d) ២០៣៤ ដល់ ២០៣៥ : ២០%
(e) ២០៣៦ និងបន្ទាប់ : ១៥%

៣- ភាគីនីមួយៗត្រូវធានាថា ក្នុងរយៈពេល២៤ខែ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ និងរាល់រយៈពេល១២ខែបន្តបន្ទាប់ កម្រិតគណនានៃការផលិតសារធាតុដែលត្រូវត្រួតពិនិត្យ ដែលមានក្នុងឧបសម្ព័ន្ធF

ខ្នាតគិតជា CO_2 equivalents មិនត្រូវឱ្យលើសភាគរយដែលបានកំណត់តាមឆ្នាំ ដូចមានក្នុងកថាខណ្ឌរងពី (a) ដល់ (e) នៃកម្រិតគណនានៃការប្រើប្រាស់មធ្យមប្រចាំឆ្នាំក្នុងឧបសម្ព័ន្ធF សម្រាប់ឆ្នាំ២០១១ ២០១២ និង២០១៣ រួមនឹង១៥% កម្រិតផលិតក្នុងឧបសម្ព័ន្ធC ក្រុម១ សារធាតុត្រូវត្រួតពិនិត្យដែលបានកំណត់ក្នុងកថាកខណ្ឌ១ មាត្រា២F ខ្នាតគិតជា CO_2equivalents:

(a) ២០១៩ ដល់ ២០២៣ : ៩០%

(b) ២០២៤ ដល់ ២០២៨ : ៦០%

(c) ២០២៩ ដល់ ២០៣៣ : ៣០%

(d) ២០៣៤ ដល់ ២០៣៥ : ២០%

(e) ២០៣៦ និងបន្ទាប់មក : ១៥%

៤- ទោះបីជាមានកថាខណ្ឌ១ នៃមាត្រានេះ ភាគីច្រើនអាចសម្រេចចិត្តថា ភាគីមួយដែលផលិតសារធាតុដែលត្រូវត្រួតពិនិត្យនៅក្នុងឧបសម្ព័ន្ធF ត្រូវធានាថាក្នុងរយៈពេល១២ខែ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០ ហើយនឹងនៅរាល់១២ខែបន្តបន្ទាប់ កម្រិតគណនានៃការផលិតសារធាតុត្រូវបានពិនិត្យក្នុងឧបសម្ព័ន្ធF គិតជា CO_2 equivalents មិនឱ្យលើសភាគរយ ដែលបានកំណត់តាមឆ្នាំ ដូចមានក្នុងកថាខណ្ឌរងពី (a) ដល់ (e) នៃកម្រិតប៉ាន់ស្មានការផលិតមធ្យមប្រចាំឆ្នាំក្នុងឧបសម្ព័ន្ធF សម្រាប់ឆ្នាំ២០១១ ២០១២ និង២០១៣ រួមនឹង២៥%នៃកម្រិតប្រើប្រាស់ក្នុងឧសម្ព័ន្ធC ក្រុម១ សារធាតុត្រូវត្រួតពិនិត្យដែលបានកំណត់ក្នុងកថាកខណ្ឌ១ មាត្រា២F ខ្នាតគិតជា CO_2 equivalents:

(a) ២០២០ ដល់ ២០២៤ : ៩៥%

(b) ២០២៥ ដល់ ២០២៨ : ៦៥%

(c) ២០២៩ ដល់ ២០៣៣ : ៣០%

(d) ២០៣៤ ដល់ ២០៣៥ : ២០%

(e) ២០៣៦ និងបន្ទាប់មក : ១៥%

៥- កថាខណ្ឌ១ ដល់៤ នៃមាត្រានេះនឹងអនុវត្តសម្រាប់ជួយពន្យាដល់ភាគីក្នុងការសម្រេចដើម្បីអនុញ្ញាតកម្រិតការផលិត ឬប្រើប្រាស់ដែលចាំបាច់ប្រើប្រាស់ដោយទទួលយល់ព្រមពីភាគីទាំងអស់។

៦- ភាគីរោងចក្រផលិតសារធាតុដែលមានក្នុងឧបសម្ព័ន្ធC ក្រុម១ ឬឧបសម្ព័ន្ធF ត្រូវធានាឱ្យបានថាក្នុងរយៈពេល១២ខែ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០ និងរាល់រយៈពេល១២ខែបន្តបន្ទាប់ សារធាតុបញ្ចេញក្នុងឧបសម្ព័ន្ធC ក្រុម២ សារធាតុទាំងនេះបង្កើតក្នុងផលិតដែលរោងចក្រផលិតសារធាតុដែលមានក្នុងឧបសម្ព័ន្ធC ក្រុម១ ឬឧបសម្ព័ន្ធF ត្រូវបានបំផ្លាញចោលក្នុងការប្រើប្រាស់បច្ចេកវិទ្យាដោយភាគីក្នុងអំឡុងពេលដូចគ្នា។

៧- ភាគីនីមួយៗត្រូវធានាថា ការលុបបំបាត់ចោលសាធាតុដែលមានក្នុងឧបសម្ព័ន្ធF ក្រុម២ ត្រូវបានធ្វើឡើងដោយអ្នកពាក់ព័ន្ធដែលមានក្នុងឧបសម្ព័ន្ធC ក្រុម១ ឬឧបសម្ព័ន្ធF នឹងអនុញ្ញាតលុះត្រាតែមានបច្ចេកវិទ្យាណាត្រូវបានអនុញ្ញាតពីភាគី។

មាត្រា៣ ការគណនាកម្រិតត្រួតពិនិត្យ

១- *គោលបំណងនៃមាត្រា២ មាត្រា២A ទៅ២J និងមាត្រា៥ ភាគីនីមួយៗត្រូវកំណត់កម្រិតគណនាចំពោះសារធាតុនៅក្នុងឧបសម្ព័ន្ធA ឧបសម្ព័ន្ធB ឧបសម្ព័ន្ធC ឬឧបសម្ព័ន្ធF ដោយៈ*

(a) ការផលិតអាស្រ័យដោយៈ

i. ធ្វើផលគុណបរិមាណផលិតផលសារធាតុ ដែលត្រូវត្រួតពិនិត្យប្រចាំឆ្នាំទៅនឹងសក្តានុពលនៃការបំផ្លាញស្រទាប់អូហ្សូន ដែលបង្កឡើងដោយសារធាតុដែលត្រូវត្រួតពិនិត្យដូចមានចែងក្នុងឧបសម្ព័ន្ធA ឧបសម្ព័ន្ធB ឧបសម្ព័ន្ធC ឬឧបសម្ព័ន្ធE *លើកលែងតែមានចែងជាក់លាក់ក្នុងកថាខណ្ឌ២។*

ii. បូកបញ្ចូលគ្នានូវបរិមាណសារធាតុតាមតួលេខនៅក្នុងក្រុមសារធាតុ ដែលត្រូវត្រួតពិនិត្យនីមួយៗ រួចបង្ហាញលទ្ធផលជាក្រាហ្វិក

(b) ការនាំចូលនិងនាំចេញ ត្រូវអនុវត្តទៅតាមនីតិវិធីដែលបានកំណត់ក្នុងអនុកថាខណ្ឌរង(a)និង(c) បរិមាណប្រើប្រាស់ដោយបូកបន្ថែមនូវកម្រិតគណនាលើការផលិតសារធាតុ និងការនាំចូល ប៉ុន្តែត្រូវដកចេញនូវកម្រិតគណនាលើសារធាតុនាំចេញដូចបានចែង ដោយផ្អែកទៅតាមអនុកថាខណ្ឌ(a)និង(b)។ ទោះបីយ៉ាងណាក៏ដោយ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៣ ការនាំចេញសារធាតុដែលត្រូវត្រួតពិនិត្យទៅកាន់ភាគីមិនមែនជាសមាជិក មិនត្រូវដកចេញពីការគណនានៃកម្រិតប្រើប្រាស់នៃការនាំចេញរបស់ភាគីឡើយ។

(C) ការបញ្ចេញសារធាតុដែលមានក្នុងឧបសម្ព័ន្ធF ក្រុម២ សារធាតុដែលបានផលិតនៅសង្វាក់ផលិតកម្មនីមួយៗ ដែលមានក្នុងឧបសម្ព័ន្ធC ក្រុម១ ឬក៏នៅក្នុងឧបសម្ព័ន្ធF ដោយរួមបញ្ចូលរបស់របរផ្សេងៗ បរិមាណបញ្ចេញតាមរយៈការលេចធ្លាយរបស់ឧបករណ៍ ការដំណើរការ និងការបំផ្លាញ ចោលគ្រឿងចក្រ ក៏ប៉ុន្តែមិនរាប់បញ្ចូលនូវបរិមាណសម្រាប់ការប្រើប្រាស់ ការបំផ្លាញចោល និងស្តុកទុកឡើយ។

២- *ពេលធ្វើការគណនាកម្រិត(ខ្នាតគិតជា CO_2 equivalents) បរិមាណការផលិត ការប្រើប្រាស់ ការនាំចូល ការនាំចេញ និងការបញ្ចេញឧស្ម័នដែលមានក្នុងឧបសម្ព័ន្ធF និងC ក្រុម១ សារធាតុទាំងនេះដែលមានចែងក្នុងមាត្រា២J ក្នុងកថាខណ្ឌ៥ bis នៃមាត្រា២ និងកថាខណ្ឌ១ (d) នៃមាត្រា៣ភាគីនីមួយៗ ត្រូវប្រើប្រាស់សក្តានុពលការកើនកម្តៅផែនដីនៃសារធាតុទាំងនោះ ដែលមានចែងច្បាស់នៅក្នុងក្រុម១ ក្នុងឧបសម្ព័ន្ធA ឧបសម្ព័ន្ធC និងឧបសម្ព័ន្ធF។*

មាត្រា៤ **ការត្រួតពិនិត្យលើពាណិជ្ជកម្មជាមួយប្រទេសដែលពុំមែនជាភាគីនៃអនុសញ្ញា**

១- ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៩០ ភាគីនីមួយៗនឹងត្រូវហាមឃាត់លើការនាំចូលសារធាតុដែលត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធA ពីប្រទេសដែលពុំមែនជាសមាជិកនៃពិធីសារនេះ។

១bis- ក្នុងរយៈពេលមួយឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចូលជាធរមានរបស់កថាខណ្ឌនេះ ភាគីនីមួយៗ នឹងត្រូវហាមឃាត់ចំពោះការនាំចូលសារធាតុដែលត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធB ពីប្រទេសដែលពុំមែនជាសមាជិកនៃពិធីសារនេះ ។

១ter- ក្នុងរយៈពេលមួយឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចូលជាធរមានរបស់កថាខណ្ឌនេះ ភាគីនីមួយៗ នឹងត្រូវហាមឃាត់ចំពោះការនាំចូលសារធាតុដែលត្រូវត្រួតពិនិត្យក្នុងក្រុម២ នៃឧបសម្ព័ន្ធC ពីប្រទេសដែលពុំមែនជាសមាជិកនៃពិធីសារនេះ។

១qua- ក្នុងរយៈពេលមួយឆ្នាំ គិតចាប់ពីកាលបរិច្ឆេទ នៃការចូលជាធរមានរបស់កថាខណ្ឌនេះ ភាគីនីមួយៗ នឹងត្រូវហាមឃាត់ចំពោះការនាំចូលសារធាតុដែលត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធE ពីប្រទេសដែលពុំមែនជាសមាជិកនៃពិធីសារនេះ ។

១quin- ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០០៤ ភាគីនីមួយៗ នឹងត្រូវហាមឃាត់ ចំពោះការនាំចូលសារធាតុ ដែលត្រូវពិនិត្យក្នុងក្រុម១ នៃឧបសម្ព័ន្ធC ពីប្រទេសដែលពុំមែនជាសមាជិកនៃពិធីសារនេះ។

១sex- ក្នុងរយៈពេលមួយឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចូលជាធរមានរបស់កថាខណ្ឌនេះ ភាគីនីមួយៗ នឹងត្រូវហាមឃាត់ចំពោះការនាំចូលសារធាតុដែលត្រូវត្រួតពិនិត្យក្នុងក្រុម៣នៃឧបសម្ព័ន្ធC ពីប្រទេសដែលពុំមែនជាសមាជិកនៃពិធីសារនេះ។

១sept- ការដាក់ឱ្យអនុវត្តនូវកថាខណ្ឌខាងលើនេះ ភាគីនីមួយៗនឹងត្រូវបានហាមលើការនាំចូលសារធាតុដែលត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធF ពីគ្រប់ប្រទេសដែលពុំមែនជាសមាជិកនៃពិធីសារនេះ។

២- ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៣ ភាគីនីមួយៗ នឹងត្រូវហាមឃាត់លើការនាំចេញសារធាតុដែលត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធA ទៅកាន់ប្រទេសដែលពុំមែនជាសមាជិកនៃពិធីសារនេះ។

២bis- ក្នុងរយៈពេលមួយឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចូលជាធរមានរបស់កថាខណ្ឌនេះ ភាគីនីមួយៗ នឹងត្រូវហាមឃាត់ចំពោះការនាំចេញសារធាតុដែលត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធB ទៅកាន់ប្រទេសដែលពុំមែនជាសមាជិកនៃពិធីសារនេះ។

២ter- ក្នុងរយៈពេលមួយឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចូលជាធរមានរបស់កថាខណ្ឌនេះ ភាគីនីមួយៗ នឹងត្រូវហាមឃាត់ចំពោះការនាំចេញសារធាតុដែលត្រូវត្រួតពិនិត្យក្នុងក្រុម២ នៃឧបសម្ព័ន្ធC ទៅកាន់ប្រទេសដែលពុំមែនជាសមាជិកនៃពិធីសារនេះ។

២qua- ក្នុងរយៈពេលមួយឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចូលជាធរមានរបស់កថាខណ្ឌនេះ ភាគីនីមួយៗ នឹងត្រូវហាមឃាត់ចំពោះការនាំចេញសារធាតុដែលត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធ E ទៅកាន់ប្រទេសដែលពុំមែនជាសមាជិកនៃពិធីសារនេះ។

២quin- ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០០៤ ភាគីនីមួយៗ នឹងត្រូវហាមឃាត់ចំពោះការនាំចេញសារធាតុដែលត្រូវត្រួតពិនិត្យក្នុងក្រុម១នៃឧបសម្ព័ន្ធC ទៅកាន់ប្រទេសដែលពុំមែនជាសមាជិកនៃពិធីសារនេះ។

២sex- ក្នុងរយៈពេលមួយឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចូលជាធរមានរបស់កថាខណ្ឌនេះ ភាគីនីមួយៗ នឹងត្រូវហាមឃាត់ចំពោះការនាំចេញសារធាតុដែលត្រូវត្រួតពិនិត្យក្នុងក្រុម៣នៃឧបសម្ព័ន្ធC ទៅកាន់ប្រទេសដែលពុំមែនជាសមាជិកនៃពិធីសារនេះ។

២sept- ការដាក់ឱ្យអនុវត្តនូវកថាខណ្ឌខាងលើនេះ ភាគីនីមួយៗនឹងត្រូវបានហាមលើការនាំចេញសារធាតុដែលត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធF ទៅគ្រប់ប្រទេសដែលពុំមែនជាសមាជិកនៃពិធីសារនេះ។

៣- ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៩២ ដោយអនុវត្តទៅតាមនីតិវិធីក្នុងមាត្រា១០ នៃអនុសញ្ញាភាគីជាសមាជិកត្រូវរៀបរាប់ឱ្យល្អិតល្អន់នូវបញ្ជី ស្តីពីការផលិតសារធាតុដែលត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធA។ អនុលោមទៅតាមនីតិវិធីនេះ ក្នុងអំឡុងពេលមួយឆ្នាំដែលឧបសម្ព័ន្ធមានប្រសិទ្ធភាព ភាគីដែលពុំជំទាស់ទៅនឹងឧបសម្ព័ន្ធនឹងត្រូវហាមឃាត់ចំពោះការនាំចូលនូវផលិតផលពីប្រទេសដែលពុំមែនភាគីនៃពិធីសារនេះ។

៣bis- អនុលោមទៅតាមនីតិវិធីក្នុងមាត្រា១០ នៃអនុសញ្ញាក្នុងរយៈពេលបីឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចូលជាធរមានរបស់កថាខណ្ឌនេះ ភាគីនីមួយៗត្រូវរៀបរាប់លម្អិតក្នុងតារាងឧបសម្ព័ន្ធនូវផលិតផលសារធាតុដែលត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធB។ អនុលោមទៅតាមនីតិវិធីនេះ ក្នុងអំឡុងពេលមួយឆ្នាំដែលឧបសម្ព័ន្ធមានប្រសិទ្ធភាពភាគីដែលពុំជំទាស់ទៅនឹងឧបសម្ព័ន្ធ នឹងត្រូវហាមឃាត់ចំពោះការនាំចូលនូវផលិតផលពីប្រទេសដែលពុំមែនភាគីនៃពិធីសារនេះ។

៣ter- អនុលោមទៅតាមនីតិវិធីក្នុងមាត្រា១០ នៃអនុសញ្ញាក្នុងរយៈពេលបីឆ្នាំគិតចាប់ពីកាលបរិច្ឆេទ នៃការចូលជាធរមានរបស់កថាខណ្ឌនេះ ភាគីនីមួយៗនឹងត្រូវរៀបរាប់លម្អិតក្នុងតារាងឧបសម្ព័ន្ធនូវផលិតផលសារធាតុដែលត្រូវត្រួតពិនិត្យក្នុងក្រុម២ ឧបសម្ព័ន្ធC។ អនុលោមទៅតាមនីតិវិធីនេះក្នុងអំឡុងពេលមួយឆ្នាំដែលឧបសម្ព័ន្ធមានប្រសិទ្ធភាពភាគីដែលពុំជំទាស់ទៅនឹងឧបសម្ព័ន្ធ នឹងត្រូវហាមឃាត់ចំពោះការនាំចូលនូវផលិតផលពីប្រទេសដែលពុំមែនភាគីនៃពិធីសារនេះ។

៤- ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៤ ភាគីនឹងត្រូវហាមឃាត់តាមករណីដែលអាចធ្វើបានចំពោះការនាំចូលផលិតផលពីប្រទេសដែលពុំមែនជាសមាជិកនៃអនុសញ្ញា ប៉ុន្តែលើកលែងសារធាតុដែលត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធA។ អនុលោមទៅតាមនីតិវិធីក្នុងមាត្រា១០ នៃអនុសញ្ញា បើសិនការកំណត់អាចធ្វើទៅបាន ភាគីនឹងត្រូវរៀបរាប់លម្អិតក្នុងតារាងឧបសម្ព័ន្ធនូវផលិតផលសារធាតុទាំងនេះ។ អនុលោមទៅតាមនីតិវិធីនេះ ក្នុងអំឡុងពេលមួយឆ្នាំដែលឧបសម្ព័ន្ធមានប្រសិទ្ធភាព ភាគីដែលមិនជំទាស់ទៅនឹងឧបសម្ព័ន្ធ នឹងត្រូវហាមឃាត់ចំពោះការនាំចូលនូវផលិតផលពីប្រទេសដែលពុំមែនភាគីនៃពិធីសារនេះ។

៤bis- ក្នុងអំឡុងពេលប្រាំឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចូលជាធរមានរបស់កថាខណ្ឌនេះ ភាគីត្រូវហាមឃាត់តាមករណីដែលអាចធ្វើបាន ចំពោះការនាំចូលផលិតផលពីប្រទេសដែលពុំមែនជាសមាជិកនៃអនុសញ្ញា ប៉ុន្តែលើកលែងសារធាតុដែលត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធB។ អនុលោមទៅតាមនីតិវិធីក្នុងមាត្រា១០ នៃអនុសញ្ញា បើសិនការកំណត់អាចធ្វើទៅបាន ភាគីនឹងត្រូវរៀបរាប់លម្អិតក្នុងតារាងឧបសម្ព័ន្ធនូវផលិតផលសារធាតុទាំងនេះ។ អនុលោមទៅតាមនីតិវិធីនេះ ក្នុងអំឡុងពេលមួយឆ្នាំដែលឧបសម្ព័ន្ធមានប្រសិទ្ធភាព ភាគីដែលមិនជំទាស់ទៅនឹងឧបសម្ព័ន្ធនឹងត្រូវហាមឃាត់ចំពោះការនាំចូលនូវផលិតផលពីប្រទេសដែលពុំមែនភាគីនៃពិធីសារនេះ។

៤ter- ក្នុងអំឡុងពេលប្រាំឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការចូលជាធរមានរបស់កថាខណ្ឌនេះ ភាគីត្រូវហាមឃាត់តាមករណីដែលអាចធ្វើបានចំពោះការនាំចូលផលិតផលពីប្រទេស ដែលពុំមែនជាសមាជិកនៃអនុសញ្ញា ប៉ុន្តែលើកលែងសារធាតុដែលត្រូវត្រួតពិនិត្យក្នុងក្រុម២ នៃឧបសម្ព័ន្ធC។ អនុលោមទៅតាមនីតិវិធីក្នុងមាត្រា១០ នៃអនុសញ្ញា បើសិនការកំណត់អាចធ្វើទៅបាន ភាគីនឹងត្រូវរៀបរាប់លម្អិតក្នុងតារាងឧបសម្ព័ន្ធនូវផលិតផលសារធាតុទាំងនេះ។ អនុលោមទៅតាមនីតិវិធីនេះ ក្នុងអំឡុងពេលមួយឆ្នាំដែលឧបសម្ព័ន្ធមានប្រសិទ្ធភាព ភាគីដែលពុំជំទាស់ទៅនឹងឧបសម្ព័ន្ធនឹងត្រូវហាមឃាត់ចំពោះការនាំចូលនូវផលិតផលពីប្រទេសដែលពុំមែនភាគីនៃពិធីសារនេះ។

៥- ភាគីនីមួយៗ ត្រូវទទួលខុសត្រូវទាំងស្រុងក្នុងការបញ្ឈប់ការផ្តល់បច្ចេកវិទ្យាសម្រាប់ការផលិត និងការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យក្នុង *ឧបសម្ព័ន្ធA B C E និងF* ទៅឱ្យប្រទេសដែលពុំមែនជាសមាជិកនៃពិធីសារនេះ។

៦- ភាគីនីមួយៗ ត្រូវមានការបញ្ឈប់ចំពោះការផ្តល់ទៅឱ្យប្រទេសដែលពុំមែនជាសមាជិកនៃពិធីសារនេះជាថវិកា ជាជំនួយឬជាកម្មវិធីធានារ៉ាប់រងលើការនាំចេញទៅប្រទេសដែលពុំមែនជាភាគី នៃពិធីសារនេះនូវផលិតផល សម្ភារៈ រោងចក្រ និងបច្ចេកវិទ្យា ដែលសម្រួលដល់ការផលិតសារធាតុដែលត្រូវត្រួតពិនិត្យក្នុង *ឧបសម្ព័ន្ធA B C E និងF*។

៧- កថាខណ្ឌ៥ និង ៦ មិនត្រូវបានអនុវត្តចំពោះផលិតផល សម្ភារៈ រោងចក្រ ឬបច្ចេកវិទ្យា ដែលសម្រាប់កែលម្អទៅលើអ្វីដែលមានស្រាប់ទៅលើការរកឃើញជាថ្មី ការកែច្នៃឡើងវិញ ឬការកាត់បន្ថយសារធាតុដែលត្រូវត្រួតពិនិត្យ ប៉ុន្តែមានទិសដៅបង្កើនការអភិវឌ្ឍទៅលើសារធាតុដែលត្រូវបានប្រើប្រាស់ ដើម្បីជំនួស ឬរួមចំណែកក្នុងការកាត់បន្ថយការបញ្ចេញ សារធាតុដែលត្រូវត្រួតពិនិត្យក្នុង *ឧបសម្ព័ន្ធA B C E និងF*។

៨- ទោះបីយ៉ាងណាក៏ដោយ យោងទៅតាមការចែងក្នុងកថាខណ្ឌទី១ រហូតដល់ ៤ter នៃមាត្រានេះ ការនាំចូល ឬនាំចេញនូវសារធាតុដែលត្រូវត្រួតពិនិត្យទៅកាន់ប្រទេសដែលពុំមែនជាសមាជិកនៃពិធីសារនេះនឹងអាចត្រូវបានអនុញ្ញាត ប្រសិនបើប្រទេសនេះត្រូវកំណត់ដោយកិច្ចប្រជុំរវាងភាគីជាសមាជិកនៃពិធីសារនេះ ថាបានធ្វើទៅតាមមាត្រា២ *មាត្រា២A រហូតដល់មាត្រា២J* និងមាត្រានេះ ហើយបានផ្ញើទិន្នន័យដែលមានសុពលភាពដូចបានបញ្ជាក់ក្នុងមាត្រា៧។

៩- សម្រាប់គោលបំណងនៃមាត្រានេះ ចំពោះពាក្យថា «ប្រទេសដែលពុំមែនជាសមាជិកនៃពិធីសារនេះ» គឺសំដៅទៅលើប្រទេសឬអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ដែលពុំយល់ព្រមទៅនឹងការកំណត់នៃវិធានការត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពទៅលើសារធាតុដែលត្រូវត្រួតពិនិត្យនោះ។

១០- ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៦ ភាគីជាសមាជិកនឹងត្រូវគិតពិចារណាធ្វើវិសោធនកម្មទៅលើពិធីសារនេះ ដើម្បីពង្រីកវិធានការក្នុងមាត្រានេះឱ្យមានលក្ខណៈទូលំទូលាយទាក់ទងនឹងការធ្វើពាណិជ្ជកម្មលើសារធាតុដែលត្រូវត្រួតពិនិត្យក្នុងក្រុម១ នៃឧបសម្ព័ន្ធC និងក្នុងឧបសម្ព័ន្ធE ចំពោះប្រទេសដែលពុំមែនជាសមាជិកនៃពិធីសារនេះ។

មាត្រា៤A ការពិនិត្យពាណិជ្ជកម្មជាមួយភាគី

១- ពេលបន្ទាប់ពីថ្ងៃដែលត្រូវអនុវត្តជំហានលុបបំបាត់សារធាតុដែលត្រូវត្រួតពិនិត្យ ភាគីមួយមិនអាចធ្វើការនាំចេញ កែច្នៃឡើងវិញ ព្រមទាំងស្នើសុំបរិមាណនៃសារធាតុទាំងនោះទេក្រៅពីគោលបំណងសម្រាប់បំផ្លាញចោល ទោះបីជាភាគីនេះបានអនុវត្តន៍ជំហានទាំងអស់នៃកាតព្វកិច្ចនៅក្នុងពិធីសារដើម្បីបញ្ឈប់ការផលិតសារធាតុសម្រាប់ប្រើប្រាស់ក្នុងស្រុកលើកលែងសម្រាប់ប្រើប្រាស់ ដោយមានការយល់ព្រមភាគីទាំងអស់ក្នុងករណីចាំបាច់។

២- កថាខណ្ឌ១នៃមាត្រានេះត្រូវអនុវត្តដោយគ្មានភាពលម្អៀង ដើម្បីប្រតិបត្តិមាត្រា១១ នៃអនុសញ្ញា និងជានីតិវិធីនៃការមិនអនុវត្តតាមដែលបានបង្កើតឡើងក្រោមមាត្រា៨នៃពិធីសារ។

មាត្រា៤B អាជ្ញាប័ណ្ណ

១- ភាគីនីមួយៗចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០០០ ឬបីខែបន្ទាប់ពីថ្ងៃចូលជាធរមាននៃមាត្រានេះ ត្រូវបង្កើតនិងអនុវត្តប្រព័ន្ធអាជ្ញាប័ណ្ណក្នុងការនាំចេញនិងនាំចូលនូវសារធាតុថ្មី ប្រើប្រាស់កែច្នៃឡើងវិញ និងការស្នើឡើងវិញនូវបរិមាណសារធាតុនៅក្នុងឧបសម្ព័ន្ធA B C និងE។

២- ទោះបីជាកថាខណ្ឌ១ នៃមាត្រានេះ រាល់ភាគីត្រូវប្រតិបត្តិតាមកថាខណ្ឌ១នៃមាត្រា៥ ដែលមិនទាន់អាចបង្កើត និងអនុវត្តប្រព័ន្ធអាជ្ញាប័ណ្ណសម្រាប់នាំចេញ នាំចូលសារធាតុដែលត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធC អាចធ្វើការពន្យាពេលក្នុងសកម្មភាពនេះរហូតដល់ថ្ងៃទី១ ខែមករា ឆ្នាំ២០០៥ និងសារធាតុក្នុងឧបសម្ព័ន្ធE រហូតដល់ថ្ងៃទី១ ខែមករា ឆ្នាំ២០០២។

២bis- ភាគីនីមួយៗចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ ឬបីខែបន្ទាប់ពីថ្ងៃចូលជាធរមាននៃមាត្រានេះ ត្រូវបង្កើតនិងប្រតិបត្តិប្រព័ន្ធអាជ្ញាប័ណ្ណនាំចូលនិងនាំចេញសារធាតុថ្មី ធ្លាប់ប្រើប្រាស់រួចកែច្នៃឡើងវិញ និងសារធាតុត្រូវត្រួតពិនិត្យដែលមានក្នុងឧបសម្ព័ន្ធF។ ភាគីណាមួយដែលអនុវត្តតាមកថាខណ្ឌ១នៃមាត្រា៥ មិនអាចធ្វើបានឬអនុវត្តបានប្រព័ន្ធផ្តល់អាជ្ញាប័ណ្ណ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ អាចពន្យាការអនុវត្តរហូតដល់ថ្ងៃទី១ ខែមករា ឆ្នាំ២០២១។

៣- គ្រប់ភាគីទាំងអស់ត្រូវតែបង្ហាញ និងធ្វើរបាយការណ៍ទៅលេខាធិការដ្ឋានអំពីការបង្កើតនិងដំណើរការប្រព័ន្ធអាជ្ញាប័ណ្ណក្រោយពេលនៃការបង្កើតបានបីខែ។

៤- លេខាធិការដ្ឋានត្រូវតែរៀបចំតារាងភាគី ដែលបានរាយការណ៍អំពីប្រព័ន្ធផ្តល់អាជ្ញាប័ណ្ណរបស់ពួកគេ រួចផ្ញើបញ្ជូនទៅឱ្យគ្រប់ភាគីទាំងអស់និងត្រូវបញ្ជូនព័ត៌មាននេះទៅគណៈកម្មាប្រតិបត្តិសម្រាប់ធ្វើការពិចារណានិងផ្តល់អនុសាសន៍សមស្របទៅភាគីនីមួយៗ។

មាត្រា៥ ស្ថានភាពពិសេសនៃប្រទេសកំពុងអភិវឌ្ឍន៍

១- ចាប់ពីកាលបរិច្ឆេទនៃការចូលជាធរមានរបស់អនុសញ្ញា ឬគិតរហូតមកទល់ថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៩ ដើម្បីបំពេញនូវតម្រូវការជាមូលដ្ឋានភាគីជាសមាជិកដែលជាប្រទេសកំពុងអភិវឌ្ឍន៍ ដែលមានកម្រិតគណនាលើការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធA តិចជាង០.៣ គីឡូក្រាម សម្រាប់មនុស្សម្នាក់ៗនឹងមានសិទ្ធិពន្យាពេលរហូតដល់រយៈពេលដប់ឆ្នាំទៅលើការអនុវត្ត

តាមវិធានការត្រួតពិនិត្យ ដែលបានកំណត់នៅក្នុងមាត្រា២A រហូតដល់២E ការធ្វើវិសោធនកម្មសំដៅកែតម្រូវឬការធ្វើវិសោធនកម្ម ដើម្បីអនុម័តនៅឯកិច្ចប្រជុំលើកទីពីរក្នុងទីក្រុងឡុងដុង ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៩០ នឹងត្រូវដាក់ស្នើទៅភាគីដែលអនុវត្តតាមកថាខណ្ឌនេះក្រោយពីបានធ្វើការត្រួតពិនិត្យឡើងវិញដូចមានចែងក្នុងកថាខណ្ឌ៨ នៃមាត្រានេះ។

១bis- យោងទៅតាមកថាខណ្ឌ៨ នៃមាត្រានេះ ភាគីត្រូវទទួលខុសត្រូវពិនិត្យសាឡើងវិញចំពោះការវាយតម្លៃដែលបានធ្វើឡើងដោយផ្អែកទៅតាមមាត្រាទី៦ និងផ្អែកទៅតាមព័ត៌មានពាក់ព័ន្ធ ដែលបានសម្រេចឡើងនៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៦ តាមរយៈនីតិវិធីដែលបានកំណត់ក្នុងកថាខណ្ឌ៩ នៃមាត្រា២៖

(a) ចំពោះកថាខណ្ឌ១ ដល់កថាខណ្ឌ៦ នៃមាត្រា២F តើឆ្នាំគោលត្រូវកំណត់នៅពេលណា កម្រិតចាប់ផ្តើម តារាងពេលវេលាត្រួតពិនិត្យ និងកាលបរិច្ឆេទលុបចោលការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យក្នុងក្រុម១ នៃឧបសម្ព័ន្ធC ដែលនឹងអនុវត្តចំពោះភាគីក្រោមកថាខណ្ឌ១ នៃមាត្រានេះ។

(b) ចំពោះមាត្រា២G តើឆ្នាំគោលនៃជំហានកាត់បន្ថយការផលិត និងការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យក្នុងក្រុម២ នៃឧបសម្ព័ន្ធC នឹងត្រូវដាក់ឱ្យអនុវត្តន៍ទៅភាគីដែលស្ថិតនៅក្នុងកថាខណ្ឌ១ នៃមាត្រានេះ។

(c) ចំពោះមាត្រា២H តើឆ្នាំគោល កម្រិតចាប់ផ្តើម និងតារាងពេលវេលាត្រួតពិនិត្យលើការប្រើប្រាស់ និងការផលិតសារធាតុដែលត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធE នឹងត្រូវអនុវត្តចំពោះភាគីក្រោមកថាខណ្ឌ១ នៃមាត្រានេះ។

២- ទោះបីយ៉ាងណាក៏ដោយ គ្រប់ភាគីដែលស្ថិតនៅក្នុងកថាខណ្ឌ១ នៃមាត្រានេះត្រូវកំណត់កម្រិតគណនានៃការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធA មិនត្រូវលើសពី០.៣គីឡូក្រាម សម្រាប់មនុស្សម្នាក់ៗ ឬមិនត្រូវលើសកម្រិតគណនាប្រចាំឆ្នាំលើការប្រើប្រាស់សារធាតុដែលត្រូវពិនិត្យក្នុងឧបសម្ព័ន្ធB ដែលកំណត់ឱ្យត្រឹម០.២គីឡូក្រាម សម្រាប់មនុស្សម្នាក់ៗ។

៣- នៅពេលអនុវត្តវិធានការត្រួតពិនិត្យដែលបានកំណត់ក្នុងមាត្រា២A រហូតដល់២E ការអនុវត្តរបស់ភាគីតាមកថាខណ្ឌ១ នៃមាត្រានេះនឹងត្រូវបានផ្តល់សិទ្ធិប្រើប្រាស់៖

(a) ចំពោះសារធាតុដែលត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធA តម្លៃមធ្យមនៃកម្រិតគណនាប្រចាំឆ្នាំលើការប្រើប្រាស់ក្នុងអំឡុងពេលពីឆ្នាំ១៩៩៥ ដល់ឆ្នាំ១៩៩៧ ឬកម្រិតគណនាលើការប្រើប្រាស់ដែលអនុញ្ញាតឱ្យត្រឹម០.៣គីឡូក្រាម សម្រាប់មនុស្សម្នាក់ៗ ដែលចាត់ទុកជាមូលដ្ឋានសម្រាប់កំណត់វិធានការត្រួតពិនិត្យ។

(b) ចំពោះសារធាតុដែលត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធB តម្លៃមធ្យមនៃកម្រិតគណនាប្រចាំឆ្នាំលើការប្រើប្រាស់ក្នុងអំឡុងពេលពីឆ្នាំ១៩៩៨ ដល់ឆ្នាំ២០០០ ឬកម្រិតគណនាលើការប្រើប្រាស់ដែលអនុញ្ញាតឱ្យត្រឹម០.២គីឡូក្រាម សម្រាប់មនុស្សម្នាក់ៗដែលចាត់ទុកជាមូលដ្ឋានសម្រាប់កំណត់វិធានការត្រួតពិនិត្យ។

(c) ចំពោះសារធាតុដែលត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធA តម្លៃមធ្យម នៃកម្រិតគណនាប្រចាំឆ្នាំ លើការផលិតក្នុងអំឡុងពេលពីឆ្នាំ១៩៩៥ ដល់ឆ្នាំ១៩៩៧ ឬកម្រិតគណនាលើការផលិត ដែលអនុញ្ញាតឱ្យត្រឹម០.៣គីឡូក្រាម សម្រាប់មនុស្សម្នាក់ៗ ដែលចាត់ទុកជាមូលដ្ឋានសម្រាប់ កំណត់វិធានការត្រួតពិនិត្យ។

(d) ចំពោះសារធាតុដែលត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធB តម្លៃមធ្យមនៃកម្រិតគណនាប្រចាំឆ្នាំ លើការផលិតក្នុងអំឡុងពេលពីឆ្នាំ១៩៩៨ ដល់ឆ្នាំ២០០០ ឬកម្រិតគណនាលើការផលិតដែល អនុញ្ញាតឱ្យត្រឹម០.២គីឡូក្រាម សម្រាប់មនុស្សម្នាក់ៗ ដែលចាត់ទុកជាមូលដ្ឋានសម្រាប់កំណត់ វិធានការត្រួតពិនិត្យ។

៤- មុនពេលដែលកាតព្វកិច្ចត្រួតពិនិត្យដូចមានចែងក្នុង *មាត្រា២A រហូតដល់មាត្រា២J* អាចអនុវត្តទៅ បានប្រសិនបើការអនុវត្តរបស់ភាគីតាមកថាខណ្ឌ១ នៃមាត្រានេះ ឃើញថាពុំមានការផ្គត់ផ្គង់គ្រប់គ្រាន់ ចំពោះសារធាតុដែលត្រូវត្រួតពិនិត្យគឺភាគីអាចជូនដំណឹងទៅលេខាធិការដ្ឋាន។ លេខាធិការដ្ឋាន នឹងត្រូវផ្សព្វផ្សាយជាបន្ទាន់ទៅកាន់ភាគីជាសមាជិកនូវឯកសារចម្លងដែលបញ្ជាក់ប្រាប់ជាមុន ពីបញ្ហា ដែលនឹងត្រូវលើកយកមកពិចារណានៅក្នុងកិច្ចប្រជុំលើកក្រោយ និងធ្វើសេចក្តីសម្រេចពីសកម្មភាព សមស្របដែលនឹងត្រូវអនុវត្ត។

៥- បង្កើនសមត្ថភាពបំពេញកាតព្វកិច្ចលើការអនុវត្តរបស់ភាគីតាមកថាខណ្ឌ១នៃមាត្រា៥ ដោយអនុលោម ទៅតាមវិធានការត្រួតពិនិត្យដែលបានកំណត់ក្នុងមាត្រា២A រហូតដល់មាត្រា២E និងមាត្រា *២J* និង អនុលោមទៅតាមវិធានការត្រួតពិនិត្យផ្សេងទៀតក្នុងមាត្រា២F រហូតដល់មាត្រា២H ដែលបានសម្រេច ដោយផ្អែកទៅតាមកថាខណ្ឌ១ber នៃមាត្រានេះ រីឯការអនុវត្តដោយភាគីដដែលនឹងត្រូវពឹងផ្អែកទៅលើ ប្រសិទ្ធភាពនៃការអនុវត្តលើកិច្ចសហប្រតិបត្តិការ ផ្នែកហិរញ្ញវត្ថុ ដូចមានចែងដោយមាត្រា១០ និងមាត្រា១០A ដែលទាក់ទងនឹងបន្លាស់ប្តូរផ្នែកបច្ចេកវិទ្យា។

៦- ការអនុវត្តរបស់ភាគីតាមកថាខណ្ឌ១ នៃមាត្រា៥ ពេលខ្លះត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ លេខាធិការដ្ឋាន ចំពោះករណីដែលមានការលំបាកក្នុងការអនុវត្តទោះបីតិចឬច្រើននូវកាតព្វកិច្ចក្នុង មាត្រា២A រហូតដល់មាត្រា២E និងមាត្រា *២J* និងក្នុងមាត្រា២F រហូតដល់មាត្រា២H ដោយអនុលោម ទៅតាមកថាខណ្ឌ១ber នៃមាត្រានេះ ដោយសារតែការអនុវត្តមាត្រា១០ និងមាត្រា១០A នៅមានការ ខ្វះខាត។ លេខាធិការដ្ឋានត្រូវផ្សព្វផ្សាយជាបន្ទាន់ទៅកាន់ភាគីជាសមាជិកនូវឯកសារចម្លងដែល បញ្ជាក់ប្រាប់ជាមុនពីបញ្ហាដែលនឹងត្រូវលើកយកមកពិចារណានៅក្នុងកិច្ចប្រជុំលើកក្រោយ លើការ ទទួលស្គាល់កថាខណ្ឌ១នៃមាត្រានេះ និងត្រូវធ្វើសេចក្តីសម្រេចពីសកម្មភាពសមស្របដែលនឹងត្រូវ អនុវត្ត។

៧- ចន្លោះពេលនៃការជូនព័ត៌មាននិងការប្រជុំរបស់ភាគី សកម្មភាពសមស្របទៅតាមកថាខណ្ឌ៦ នៃ មាត្រានេះនឹងត្រូវបានដោះស្រាយ ឬក្នុងរយៈពេលក្រោយមកទៀត បើកិច្ចប្រជុំរបស់ភាគីត្រូវបាន ដោះស្រាយនោះនីតិវិធីដែលមិនអនុវត្តទៅតាមមាត្រា៨ នឹងមិនត្រូវបានយកមកប្រើប្រាស់ទេ។

៨- ស្ថានភាពនៃការអនុវត្តរបស់ភាគីទៅតាមកថាខណ្ឌ១ នៃមាត្រានេះ នឹងត្រូវត្រួតពិនិត្យឡើងវិញ ដោយ កិច្ចប្រជុំរបស់ភាគី រួមមានទាំងការអនុវត្តប្រកបដោយប្រសិទ្ធភាពលើកិច្ចសហការផ្នែកហិរញ្ញវត្ថុ

និងការផ្លាស់ប្តូរផ្នែកបច្ចេកវិទ្យាក៏ដូចជាការអនុម័តទៅលើកំណែប្រែ ដែលមានសារៈសំខាន់ចំពោះគម្រោងពេលដែលអាចអនុវត្តដោយភាគីជាសមាជិកទៅលើវិធានការត្រួតពិនិត្យ។

8ber- យោងតាមសេចក្តីបញ្ជាប់ នៃការពិនិត្យឡើងវិញក្នុងកថាខណ្ឌ៨ ខាងលើ៖

(a) ស្រមតាមឧបសម្ព័ន្ធA នៃសារធាតុដែលត្រូវត្រួតពិនិត្យ ដើម្បីឆ្លើយតបទៅនឹងតម្រូវការក្នុងស្រុក ភាគីមួយដែលប្រតិបត្តិតាមកថាខណ្ឌ១នៃមាត្រានេះ មានសិទ្ធិពន្យារពេល១០ឆ្នាំក្នុងការប្តេជ្ញាចិត្តជាមួយនឹងការយល់ព្រមទទួលវិធានការត្រួតពិនិត្យដោយកិច្ចប្រជុំភាគលើកទី២ នៅទីក្រុងឡុងដុង ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៩០ និងយោងតាមពិធីសារម៉ុងរ៉េអាល់ មាត្រា២A និងមាត្រា២B។

(b) ស្របតាមឧបសម្ព័ន្ធB នៃសារធាតុដែលត្រូវត្រួតពិនិត្យ ដើម្បីឆ្លើយតបទៅនឹងតម្រូវការក្នុងស្រុក ភាគីមួយប្រតិបត្តិតាមកថាខណ្ឌ១ នៃមាត្រានេះមានសិទ្ធិពន្យារពេល១០ឆ្នាំ ក្នុងការប្តេជ្ញាចិត្តជាមួយនឹងការយល់ព្រមទទួលវិធានការត្រួតពិនិត្យដោយកិច្ចប្រជុំភាគលើកទី២ នៅទីក្រុងឡុងដុង ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៩០ និងយោងតាមពិធីសារម៉ុងរ៉េអាល់មាត្រា២C និងមាត្រា២E។

8ter- អនុលោមតាមកថាខណ្ឌ១bis ខាងលើ៖

(a) ក្នុងរយៈពេល១២ ខែដំបូង ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣ និងរយៈពេល១២ខែបន្តបន្ទាប់ ភាគីនីមួយៗ ក្រោមកថាខណ្ឌ១នៃមាត្រានេះ ត្រូវធានាឱ្យបាននូវកម្រិតគណនាលើការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យស្ថិតក្នុងក្រុម១ នៃឧបសម្ព័ន្ធC មិនត្រូវលើសកម្រិតគណនាលើការប្រើប្រាស់នាឆ្នាំ២០០៩ និងឆ្នាំ២០១០ឡើយ។ ភាគីនីមួយៗ ដែលប្រតិបត្តិនៅក្នុងកថាខណ្ឌទី១ នៃមាត្រានេះត្រូវប្រាកដថានៅរយៈពេល១២ខែ បន្ទាប់ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៣ និងរាល់រយៈពេល១២ខែបន្តបន្ទាប់ កម្រិតគណនានៃការផលិតសារធាតុដែលត្រូវត្រួតពិនិត្យនៅក្នុងក្រុមI នៃឧបសម្ព័ន្ធC មិនត្រូវលើសពីកម្រិតគណនាមធ្យមប្រចាំឆ្នាំក្នុងឆ្នាំ២០០៩ និងឆ្នាំ២០១០ ឡើយ។

(b) គ្រប់ភាគីដែលអនុវត្តន៍នៅក្រោមកថាខណ្ឌទី១ នៃមាត្រានេះត្រូវប្រាកដថា សម្រាប់រយៈពេល១២ខែ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៥ និងរាល់រយៈពេល១២ខែបន្តបន្ទាប់ កម្រិតគណនានៃការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យនៅក្នុងក្រុមនៃឧបសម្ព័ន្ធC មិនត្រូវលើសពី៩០% នៃមធ្យមប្រចាំឆ្នាំនៃកម្រិតគណនានៃការប្រើប្រាស់ក្នុងឆ្នាំ២០០៩ និងឆ្នាំ២០១០ឡើយ។ នៅក្នុងរយៈពេលដូចគ្នានេះ ភាគីទាំងឡាយដែលផលិតផលិតផលមួយឬច្រើននៃសារធាតុទាំងនេះត្រូវប្រាកដថា កម្រិតគណនានៃការផលិតសារធាតុដែលត្រូវត្រួតពិនិត្យនៅក្នុងក្រុមI នៃឧបសម្ព័ន្ធC មិនត្រូវលើស៩០% ពីកម្រិតគណនាមធ្យមប្រចាំឆ្នាំ ក្នុងឆ្នាំ២០០៩ និងឆ្នាំ២០១០ឡើយ។

(c) គ្រប់ភាគីដែលអនុវត្តន៍នៅក្រោមកថាខណ្ឌទី១នៃមាត្រានេះ ត្រូវប្រាកដថា សម្រាប់រយៈពេល១២ខែ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០ និងរាល់រយៈពេល១២ខែបន្តបន្ទាប់ កម្រិតគណនានៃការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យនៅក្នុងក្រុមI នៃឧបសម្ព័ន្ធC មិនត្រូវលើស

ពី៦៥% នៃមធ្យមប្រចាំឆ្នាំនៃកម្រិតគណនានៃការប្រើប្រាស់ក្នុងឆ្នាំ២០០៩ និងឆ្នាំ២០១០ ឡើយ។ នៅក្នុងរយៈពេលដូចគ្នានេះ ភាគីទាំងឡាយដែលផលិតផលិតផលមួយឬច្រើននៃសារធាតុទាំងនេះត្រូវប្រាកដថា កម្រិតគណនានៃការផលិតសារធាតុដែលត្រូវត្រួតពិនិត្យនៅក្នុងក្រុមនៃឧបសម្ព័ន្ធC មិនត្រូវលើស៦៥% ពីកម្រិតគណនាមធ្យមប្រចាំឆ្នាំក្នុងឆ្នាំ២០០៩ និងឆ្នាំ២០១០ឡើយ។

(d) គ្រប់ភាគីដែលអនុវត្តន៍នៅក្រោមកថាខណ្ឌទី១ នៃមាត្រានេះត្រូវប្រាកដថា សម្រាប់រយៈពេល ១២ខែ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៥ និងរាល់រយៈពេល១២ខែបន្តបន្ទាប់ កម្រិតគណនានៃការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យនៅក្នុងក្រុមI នៃឧបសម្ព័ន្ធC មិនត្រូវលើសពី ៣២,៥% នៃមធ្យមប្រចាំឆ្នាំនៃកម្រិតគណនានៃការប្រើប្រាស់ក្នុងឆ្នាំ២០០៩ និងឆ្នាំ២០១០ ឡើយ។ នៅក្នុងរយៈពេលដូចគ្នានេះ ភាគីទាំងឡាយដែលផលិតផលិតផលមួយឬច្រើននៃសារធាតុទាំងនេះត្រូវប្រាកដថា កម្រិតគណនានៃការផលិតសារធាតុដែលត្រូវត្រួតពិនិត្យនៅក្នុងក្រុមI នៃឧបសម្ព័ន្ធC មិនត្រូវលើស៣២.៥% ពីកម្រិតគណនាមធ្យមប្រចាំឆ្នាំក្នុងឆ្នាំ២០០៩ និងឆ្នាំ២០១០ឡើយ។

(e) គ្រប់ភាគីដែលអនុវត្តន៍នៅក្រោមកថាខណ្ឌទី១ នៃមាត្រានេះត្រូវប្រាកដថា សម្រាប់រយៈពេល១២ខែ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០៣០ និងរាល់រយៈពេល១២ខែបន្តបន្ទាប់ កម្រិតគណនានៃការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យនៅក្នុងក្រុមI នៃឧបសម្ព័ន្ធC មិនត្រូវលើសពីសូន្យ។ នៅក្នុងរយៈពេលដូចគ្នានេះ ភាគីទាំងឡាយដែលផលិតផលិតផលមួយ ឬច្រើននៃសារធាតុទាំងនេះត្រូវប្រាកដថា កម្រិតគណនានៃការផលិតសារធាតុដែលត្រូវត្រួតពិនិត្យនៅក្នុងក្រុមI នៃឧបសម្ព័ន្ធC មិនត្រូវលើសសូន្យ។ ទោះបីយ៉ាងនេះក្ដី៖

i. ភាគីទាំងនេះអាចអនុញ្ញាតឱ្យលើសពីកម្រិតកំណត់លើការប្រើប្រាស់ ក្នុងកំឡុងពេល១២ខែ ដោយធ្វើផលបូកនៃកម្រិតគណនានៃការប្រើប្រាស់រយៈពេល១០ឆ្នាំ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០៣០ ហូតដល់ថ្ងៃទី១ ខែមករា ឆ្នាំ២០៤០ រួចធ្វើផលចែកនឹងដប់ ដោយមិនត្រូវឱ្យលើសពី២,៥% នៃមធ្យមភាគនៃកម្រិតគណនានៃការប្រើប្រាស់ប្រចាំឆ្នាំនាឆ្នាំ២០០៩ និងឆ្នាំ២០១០ឡើយ និងអាចឱ្យប្រើប្រាស់សម្រាប់សេវាកម្មបរិក្ខារត្រជាក់ ម៉ាស៊ីនត្រជាក់ដែលមានចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០៣០។

ii. ភាគីទាំងនេះអាចអនុញ្ញាតឱ្យលើសពីកម្រិតកំណត់លើការផលិតក្នុងកំឡុងពេល១២ខែ ដោយធ្វើផលបូកនៃកម្រិតគណនានៃការប្រើប្រាស់រយៈពេល១០ឆ្នាំ ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០៣០ ហូតដល់ថ្ងៃទី០១ ខែមករា ឆ្នាំ២០៤០ រួចធ្វើផលចែកនឹងដប់ ដោយមិនត្រូវឱ្យលើសពី២.៥% នៃមធ្យមភាពនៃកម្រិតគណនានៃការប្រើប្រាស់ប្រចាំឆ្នាំ នាឆ្នាំ២០០៩ និងឆ្នាំ២០១០ឡើយ និងអាចឱ្យប្រើប្រាស់សម្រាប់សេវាកម្មបរិក្ខាត្រជាក់ម៉ាស៊ីនត្រជាក់ដែលមានចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០៣០។

(f) គ្រប់ភាគីដែលអនុវត្តន៍នៅក្រោមកថាខណ្ឌទី១ នៃមាត្រានេះ ត្រូវប្រតិបត្តិតាមមាត្រា២G

(g) អនុលោមទៅតាមសារធាតុដែលត្រូវត្រួតពិនិត្យមាននៅក្នុងឧបសម្ព័ន្ធE៖

i. ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០០២ ភាគីដែលប្រតិបត្តិតាមកថាខណ្ឌ១ នៃមាត្រានេះត្រូវតែអនុវត្តនូវវិធានការត្រួតពិនិត្យដែលមានចែងក្នុងកថាខណ្ឌ១ នៃមាត្រា២H ដែលជាមូលដ្ឋានសម្រាប់អនុវត្តតាមវិធានការត្រួតពិនិត្យ ដោយប្រើមធ្យមភាគនៃកម្រិតគណនាប្រចាំឆ្នាំនៃការប្រើប្រាស់ក្នុងឆ្នាំ១៩៩៥ និងការផលិតប្រចាំក្នុងឆ្នាំ១៩៩៨។

ii. ក្នុងរយៈពេល១២ខែដំបូង ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០០៥ និងរយៈពេល១២ខែបន្តបន្ទាប់ភាគីនីមួយៗ ក្រោមកថាខណ្ឌ១ នៃមាត្រានេះត្រូវធានាឱ្យបាននូវកម្រិតគណនាលើការប្រើប្រាស់ និងការផលិតសារធាតុដែលត្រូវត្រួតពិនិត្យស្ថិតក្នុងឧបសម្ព័ន្ធE មិនត្រូវលើស ៨0% ពីកម្រិតគណនាលើការប្រើប្រាស់ក្នុងឆ្នាំ១៩៩៥ និងការផលិតប្រចាំឆ្នាំក្នុងឆ្នាំ១៩៩៨។

iii. ក្នុងរយៈពេល១២ខែដំបូង ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៥ និងរយៈពេល១២ខែ បន្តបន្ទាប់ភាគីនីមួយៗក្រោមកថាខណ្ឌ១ នៃមាត្រានេះត្រូវធានាឱ្យបាននូវកម្រិតគណនាលើការប្រើប្រាស់និងការផលិតសារធាតុដែលត្រូវត្រួតពិនិត្យស្ថិតក្នុងឧបសម្ព័ន្ធE មិនត្រូវលើសសូន្យ។ ក្នុងកថាខណ្ឌនេះមានវិសាលភាពចំពោះភាគីក្នុងការអនុញ្ញាតការផលិតឬប្រើប្រាស់ដែលជាការចាំបាច់ក្នុងការប្រើកិច្ចព្រមព្រៀងរបស់ពួកគេ។

iv. កម្រិតគណនានៃការប្រើប្រាស់ និងការផលិតក្រោមកថាខណ្ឌខាងលើនេះ មិនត្រូវរួមបញ្ចូលនូវបរិមាណប្រើប្រាស់សម្រាប់បំបាត់កត្តាចង្រៃនិងរៀបចំដឹកជញ្ជូនរបស់ភាគីទេ។

៨.qua

(a) ការកែប្រែចំពោះវិធានការត្រួតពិនិត្យនៅក្នុងមាត្រា២J ស្របទៅនឹងកថាខណ្ឌ៩ នៃមាត្រា២ ភាគីនីមួយៗដែលប្រតិបត្តិនៅក្រោមកថាខណ្ឌទី១ នៃមាត្រានេះមានសិទ្ធិពន្យារពេលការអនុវត្តរបស់ខ្លួនជាមួយនឹងវិធានត្រួតពិនិត្យដែលមានចែងនៅក្នុងកថាខណ្ឌរង (a)ដល់(e) នៃកថាខណ្ឌ១ នៃមាត្រា២J និងកថាខណ្ឌរង (a)ដល់(e) នៃកថាខណ្ឌ៣ នៃមាត្រា២J និងកែប្រែវិធានការទាំងនោះដូចខាងក្រោម៖

i. ២០២៤ ដល់ ២០២៨ : ១០0%
ii. ២០២៩ ដល់ ២០៣៤ : ៩0%
iii. ២០៣៥ ដល់ ២០៣៩: ៧0%
iv. ២០៤០ ដល់ ២០៤៤ : ៥0%
v. ២០៤៥ និងបន្ទាប់មក : ២0%

(b) ទោះបីជាមានអនុកថាខណ្ឌ(a) ខាងលើ ភាគីអាចសម្រេចថា ភាគីណាមួយដែលអនុវត្តតាមកថាខណ្ឌ១ នៃមាត្រានេះ ការកែប្រែចំពោះវិធានការត្រួតពិនិត្យក្នុងមាត្រា២J ស្របទៅនឹងកថាខណ្ឌ៩ នៃមាត្រា២ នឹងត្រូវបានអនុញ្ញាតឱ្យពន្យារពេលការអនុវត្តរបស់ខ្លួនជាមួយនឹង

វិធានការត្រួតពិនិត្យ ដែលមានចែងក្នុងអនុកថាខណ្ឌ(a) ដល់(e) នៃកថាខណ្ឌ១ មាត្រា២J និងអនុកថាខណ្ឌ (a) ដល់(e) នៃកថាខណ្ឌ៣ មាត្រា២J និងកែប្រែវិធានការទាំងនោះដូចខាងក្រោម៖

i. ២០២៨ ដល់ ២០៣១ : ១០០%
ii. ២០៣២ ដល់ ២០៣៦ : ៩០%
iii. ២០៣៧ ដល់ ២០៤១ : ៨០%
iv. ២០៤២ ដល់ ២០៤៦ : ៧០%
v. ២០៤៧ និងបន្ទាប់មក : ១៥%

(c) ភាគីនីមួយៗដែលអនុវត្តតាមកថាខណ្ឌ១ នៃមាត្រានេះ សម្រាប់គោលបំណងនៃការគណនាការប្រើប្រាស់ជាមូលដ្ឋានក្រោមមាត្រា២J នឹងត្រូវបានអនុញ្ញាតឱ្យប្រើកម្រិតគណនាការប្រើប្រាស់ជាមធ្យមដែលមានក្នុងឧបសម្ព័ន្ធF ស្តីពីសារធាតុត្រូវត្រួតពិនិត្យក្នុងឆ្នាំ២០២០ ឆ្នាំ២០១២ និងឆ្នាំ២០២២ ដែលបូកបន្ថែម៦៥% នៃការប្រើប្រាស់ជាមូលដ្ឋានក្នុងឧបសម្ព័ន្ធC ក្រុម១ នៃសារធាតុត្រូវត្រួតពិនិត្យដែលមានចែងក្នុងកថាខណ្ឌ៨ter នៃមាត្រានេះ។

(d) ទោះបីជាមានអនុកថាខណ្ឌ(C)ខាងលើ ភាគីអាចសម្រេចថា ភាគីណាមួយដែលអនុវត្តតាមកថាខណ្ឌ១នៃមាត្រានេះ សម្រាប់គោលបំណងនៃការគណនាការប្រើប្រាស់ជាមូលដ្ឋានក្រោមមាត្រា២J នឹងត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់មធ្យមភាគនៃកម្រិតគណនាការប្រើប្រាស់មូលដ្ឋាននៃសារធាតុដែលត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធF ទៅតាមបរិមាណឆ្នាំ២០២៤ ឆ្នាំ២០២៥ និងឆ្នាំ២០២៦ និងបូកបន្ថែម៦៥% នៃការប្រើប្រាស់ជាមូលដ្ឋានក្នុងឧបសម្ព័ន្ធC ក្រុម១ សារធាតុត្រូវត្រួតពិនិត្យដែលមានចែងក្នុងកថាខណ្ឌ៨ter នៃមាត្រានេះ។

(e) ភាគីនីមួយៗដែលអនុវត្តតាមកថាខណ្ឌ១ នៃមាត្រានេះ ដែលផលិតនូវសារធាតុដែលត្រូវត្រួតពិនិត្យនៅក្នុងឧបសម្ព័ន្ធF សម្រាប់ការគណនានៃការផលិតជាមូលដ្ឋានរបស់ខ្លួននៅក្រោមមាត្រា២J នឹងត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់មធ្យមភាគនៃកម្រិតគណនា នៃការផលិតនៃសារធាតុដែលត្រូវត្រួតពិនិត្យនៅក្នុងឧបសម្ព័ន្ធF ទៅតាមបរិមាណផលិតនៅឆ្នាំ២០២០ ឆ្នាំ២០២១ និងឆ្នាំ២០២២ និងបូកបន្ថែម៦៥% នៃការផលិតជាមូលដ្ឋានក្នុងឧបសម្ព័ន្ធC ក្រុម១ នៃសារធាតុត្រូវត្រួតពិនិត្យដែលមានចែងក្នុងកថាខណ្ឌ៨ter នៃមាត្រានេះ។

(f) ទោះបីជាមានអនុកថាខណ្ឌ(E)ខាងលើ ភាគីអាចសម្រេចថា ភាគីណាមួយដែលអនុវត្តតាមកថាខណ្ឌ១ នៃមាត្រានេះ និងផលិតសារធាតុដែលត្រូវត្រួតពិនិត្យដែលមានក្នុងឧបសម្ព័ន្ធF សម្រាប់ការគណនាការផលិតជាមូលដ្ឋានរបស់ខ្លួនក្រោមមាត្រា២J នឹងត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់មធ្យមភាគនៃកម្រិតគណនានៃការផលិតសារធាតុដែលត្រូវត្រួតពិនិត្យនៅក្នុងឧបសម្ព័ន្ធF ស្របទៅតាមបរិមាណផលិតក្នុងឆ្នាំ២០២៤ ឆ្នាំ២០២៥ និងឆ្នាំ២០២៦ និងបូក

បន្ថែម៦៥% នៃការផលិតជាមូលដ្ឋានក្នុងឧបសម្ព័ន្ធC ក្រុម១នៃសារធាតុដែលត្រូវត្រួតពិនិត្យ ដែលមានចែងក្នុងកថាខណ្ឌ៨ter នៃមាត្រានេះ។

(g) អនុកថាខណ្ឌ(a) ដល់(f) នៃកថាខណ្ឌនេះនឹងអនុវត្តលើកម្រិតនៃការគណនានៃការផលិត និងការប្រើប្រាស់ដើម្បីរក្សាវិសាលភាពដែលកម្រិតសីតុណ្ហភាពបរិយាកាសខ្ពស់មួយ ត្រូវបានអនុវត្តន៍ផ្អែកលើលក្ខណៈវិនិច្ឆ័យសម្រេចដោយភាគី។

៩- ការសម្រេចចិត្តរបស់ភាគីជាសមាជិក ដោយយោងទៅតាមកថាខណ្ឌ៤ កថាខណ្ឌ៦ និងកថាខណ្ឌ៧ នៃមាត្រានេះ នឹងត្រូវទទួលយកដោយផ្អែកទៅតាមនីតិវិធីដែលបានអនុវត្តចំពោះការធ្វើសេចក្តីសម្រេចចិត្តក្រោមមាត្រា១០ ដូចគ្នា។

មាត្រា៦ ការវាយតម្លៃនិងការពិនិត្យឡើងវិញចំពោះវិធានការត្រួតពិនិត្យ

ចាប់ផ្តើមពីឆ្នាំ១៩៩០ និងយ៉ាងហោចណាស់រៀងរាល់បួនឆ្នាំក្រោយមកទៀត ភាគីជាសមាជិកត្រូវវាយតម្លៃលើវិធានការត្រួតពិនិត្យដែលមាននៅក្នុងមាត្រា២ មាត្រា២A រហូតដល់មាត្រា *២J* ដោយផ្អែកទៅលើមូលដ្ឋានព័ត៌មានវិទ្យាសាស្ត្រ បរិស្ថាន បច្ចេកទេស និងសេដ្ឋកិច្ច។ យ៉ាងហោចណាស់រយៈពេលមួយឆ្នាំមុនការវាយតម្លៃនីមួយៗ ភាគីនឹងត្រូវកោះអញ្ជើញក្រុមអ្នកឯកទេសមកប្រជុំកំណត់នូវការរៀបចំសមាសភាពក្រុមនិងលក្ខខណ្ឌយោង។ ក្នុងអំឡុងពេលមួយឆ្នាំដែលត្រូវបានកោះប្រជុំក្រុមអ្នកឯកទេសត្រូវរាយការណ៍ពីការសន្និដ្ឋានរបស់ខ្លួនទៅឱ្យភាគីជាសមាជិកតាមរយៈលេខាធិការដ្ឋាន។

មាត្រា៧ របាយការណ៍ស្តីពីទិន្នន័យ

១- ក្នុងអំឡុងពេលបីខែបន្ទាប់ពីបានក្លាយទៅជាភាគីនៃពិធីសារនេះ ភាគីនីមួយៗត្រូវផ្តល់ទៅលេខាធិការដ្ឋាននូវស្ថិតិទិន្នន័យដែលទាក់ទងនឹងការផលិត ការនាំចេញនិងការនាំចូលសារធាតុដែលត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធA សម្រាប់ឆ្នាំ១៩៨៦ ឬទិន្នន័យប៉ាន់ស្មានដែលប្រសើរជាងគេក្នុងខណៈដែលពុំមានទិន្នន័យពិតប្រាកដ។

២- ភាគីនីមួយៗត្រូវផ្តល់ទៅលេខាធិការដ្ឋាននូវស្ថិតិទិន្នន័យដែលទាក់ទងនឹងការផលិត ការនាំចេញឬនាំចូលសារធាតុដែលត្រូវត្រួតពិនិត្យនីមួយៗ៖

- ក្នុងឧបសម្ព័ន្ធB និងក្រុម១ និងក្រុម២ នៃឧបសម្ព័ន្ធC សម្រាប់ឆ្នាំ១៩៨៩
- ក្នុងឧបសម្ព័ន្ធE សម្រាប់ឆ្នាំ១៩៩១
- *ក្នុងឧបសម្ព័ន្ធF សម្រាប់ឆ្នាំ២០១១ ដល់ឆ្នាំ២០១៣ លើកលែងតែភាគីដែលអនុវត្តតាមកថាខណ្ឌ១ នៃមាត្រា៥ ត្រូវផ្តល់ទិន្នន័យសម្រាប់ឆ្នាំ២០២០ ដល់ឆ្នាំ២០២២ ប៉ុន្តែភាគីដែលអនុវត្តក្រោមកថាខណ្ឌ១ នៃមាត្រា៥ ដែលមានក្នុងអនុកថាខណ្ឌ (d)និង(f) នៃកថាខណ្ឌ ៨qua នៃមាត្រា៥ ត្រូវផ្តល់នូវទិន្នន័យសម្រាប់ឆ្នាំ២០២៤ ដល់ឆ្នាំ២០២៦។*

ឬទិន្នន័យប៉ាន់ស្មានដែលអាចធ្វើទៅបាន ក្នុងខណៈដែលពុំមានទិន្នន័យពិតប្រាកដបញ្ជូនទៅលេខាធិការដ្ឋាន ដោយមិនត្រូវឱ្យយឺតជាងរយៈពេលបីខែបន្ទាប់ពីកាលបរិច្ឆេទដែលសារធាតុក្នុងឧបសម្ព័ន្ធB ឧបសម្ព័ន្ធ*C E និងF* ត្រូវបានចូលជាធរមាន។

៣- ភាគីនីមួយៗត្រូវផ្តល់នូវស្ថិតិទិន្នន័យដែលទាក់ទងការផលិតប្រចាំឆ្នាំ ដូចបានកំណត់ក្នុងកថាខណ្ឌ១ នៃមាត្រា១ លើសារធាតុដែលត្រូវត្រួតពិនិត្យនីមួយៗ ដែលបានចុះបញ្ជីក្នុងឧបសម្ព័ន្ធA ឧបសម្ព័ន្ធB ឧបសម្ព័ន្ធ*E*និង ឧបសម្ព័ន្ធ*F*និងត្រូវកំណត់ដាច់ដោយឡែកពីគ្នាចំពោះសារធាតុនីមួយៗ៖

- បរិមាណប្រើប្រាស់សម្រាប់ទ្រទ្រង់ដល់ការផលិត
- បរិមាណដែលត្រូវបំផ្លាញចោលដោយបច្ចេកវិទ្យាដែលអនុម័តដោយភាគីជាសមាជិក
- ការនាំចូលឬនាំចេញទៅប្រទេសនីមួយៗដែលជាភាគីឬពុំមែនជាភាគីរបស់ពិធីសារនេះ

សម្រាប់ឆ្នាំដែលសេចក្តីចែងចំពោះឧបសម្ព័ន្ធA ឧបសម្ព័ន្ធB ឧបសម្ព័ន្ធ*E* និងឧបសម្ព័ន្ធ*F* ត្រូវបានចូលជាធរមាននិងសម្រាប់ឆ្នាំក្រោយៗមកទៀត។ ទិន្នន័យនឹងត្រូវបញ្ជូនទៅលេខាធិការដ្ឋានឱ្យបានរយៈពេលប្រាំបួនខែ នៃឆ្នាំបញ្ចប់ការផ្តល់ ព័ត៌មានពាក់ព័ន្ធ។ ភាគីនីមួយៗត្រូវផ្តល់ព័ត៌មានទៅលេខាធិការដ្ឋានស្ថិតិនៃសារធាតុត្រូវត្រួតពិនិត្យដែលមានចែងក្នុងឧបសម្ព័ន្ធE និងបានប្រើប្រាស់សម្រាប់បំបាត់កត្តាចង្រៃនិងរៀបចំដឹកជញ្ជូនរបស់ភាគី ។

៣bis- ភាគីនីមួយៗត្រូវផ្តល់ឱ្យលេខាធិការដ្ឋាននូវទិន្នន័យប្រចាំឆ្នាំដែលធ្វើដាច់ដោយឡែកពីគ្នាចំពោះការនាំចេញនិងនាំចូលសារធាតុដែលត្រូវត្រួតពិនិត្យក្នុងក្រុម២ នៃឧបសម្ព័ន្ធA និងក្រុម១ នៃឧបសម្ព័ន្ធC និង ឧបសម្ព័ន្ធE ដែលត្រូវបានកែច្នៃប្រើប្រាស់ឡើងវិញ។

៣ter- ភាគីនីមួយៗនឹងផ្តល់នូវស្ថិតិទិន្នន័យស្តីពីការបញ្ចេញសារធាតុប្រចាំឆ្នាំ ដែលមានក្នុងឧបសម្ព័ន្ធ F ក្រុម២ សារធាតុត្រូវត្រួតពិនិត្យតាមរោងចក្រដោយផ្អែកតាមកថាខណ្ឌ១(d) នៃមាត្រា៣ នៃពិធីសារនេះ។

៤- សម្រាប់ការអនុវត្តរបស់ភាគីតាមសេចក្តីចែងរបស់កថាខណ្ឌ៨(a) នៃមាត្រា២ តម្រូវការក្នុងកថាខណ្ឌ១ កថាខណ្ឌ២ កថាខណ្ឌ៣ និងកថាខណ្ឌ៣bis នៃមាត្រានេះនឹងត្រូវបានបំពេញនូវទិន្នន័យ ស្តីពី *ការផលិត* ការនាំចេញ និងនាំចូល ប្រសិនបើអង្គការសេមាហរណកម្ម សេដ្ឋកិច្ចតំបន់ផ្តល់នូវទិន្នន័យទាក់ទងស្តីពី*ការផលិត* ការនាំចេញ និងនាំចូលដែលធ្វើឡើងរវាងអង្គការនេះ និងប្រទេសដែលពុំមែនជាសមាជិករបស់អង្គការនេះ។

មាត្រា៨ ការមិនអនុវត្តតាម

នៅឯកិច្ចប្រជុំដំបូង ភាគីជាសមាជិក ត្រូវពិចារណា និងអនុម័តលើនីតិវិធីនិងយន្តការដែលបានបង្កើតឡើង ដើម្បីកំណត់ចំពោះការមិនអនុវត្តតាមសេចក្តីចែងនៃពិធីសារនេះ និងសម្រាប់អនុវត្តទៅលើភាគីទាំងឡាយណាដែលមានភស្តុតាងបញ្ជាក់ថាពុំបានអនុវត្តតាម។

មាត្រា៩ ការស្រាវជ្រាវ ការអភិវឌ្ឍ ការយល់ដឹងជាសាធារណៈ និងផ្លាស់ប្តូរព័ត៌មាន

១- ស្របទៅនឹងច្បាប់ បញ្ញាតិ និងស្របទៅតាមច្បាប់ជាតិ ភាគីជាសមាជិកត្រូវសហការ និងគិតគូរជាពិសេសទៅលើតម្រូវការរបស់ប្រទេសកំពុងអភិវឌ្ឍន៍ ក្នុងគោលដៅជួយឱ្យមានការរីកចម្រើនដោយផ្ទាល់ ឬតាមរយៈអាជ្ញាធរអន្តរជាតិ រួមមានការស្រាវជ្រាវ ការអភិវឌ្ឍ និងការផ្លាស់ប្តូរព័ត៌មានទៅលើ៖

(a) បច្ចេកវិទ្យាសមស្របសម្រាប់កែលម្អនូវអ្វីដែលមានស្រាប់ ការធ្វើឱ្យល្អប្រសើរឡើងវិញ ការកែច្នៃយកមកប្រើប្រាស់ឡើងវិញ ការបំផ្លាញចោលនូវសារធាតុដែលត្រូវត្រួតពិនិត្យ ឬការកាត់បន្ថយ ការបញ្ចេញសារធាតុទៅក្នុងបរិយាកាស ។

(b) ជម្រើសផ្សេងទៀតដែលអនុវត្តន៍ចំពោះសារធាតុដែលត្រូវត្រួតពិនិត្យ ចំពោះផលិតផលផ្ទុកទៅដោយសារធាតុដែលត្រូវត្រួតពិនិត្យនិងផលិតផលដែលបង្កើតឡើងដោយសារធាតុទាំងនេះ។

(c) តម្លៃនិងអត្ថប្រយោជន៍របស់យុទ្ធសាស្ត្រត្រួតពិនិត្យដែលមានការពាក់ព័ន្ធ។

២- ភាគីជាសមាជិក ត្រូវសហការដោយផ្ទាល់ឬតាមរយៈស្ថាប័នអន្តរជាតិ ក្នុងគោលដៅជួយបង្កើនការយល់ដឹងរបស់សាធារណជនទៅលើឥទ្ធិពលបរិស្ថាន ដែលបណ្តាលមកពីការបញ្ចេញទៅក្នុងបរិយាកាសនូវសារធាតុដែលត្រូវត្រួតពិនិត្យឬសារធាតុដទៃផ្សេងទៀតដែលបំផ្លាញស្រទាប់អូហ្សូន។

៣- ក្នុងរយៈពេលពីរឆ្នាំនៃការចូលជាធរមានរបស់អនុសញ្ញានេះ និងរយៈពេលពីរឆ្នាំបន្តបន្ទាប់ភាគីជាសមាជិកត្រូវដាក់ស្នើទៅលេខាធិការដ្ឋាន ដើម្បីពិនិត្យលើសកម្មភាពសង្ខេបដោយអនុលោមទៅតាមមាត្រានេះ។

មាត្រា១០ យន្តការផ្នែកហិរញ្ញវត្ថុ

១- ភាគីជាសមាជិកត្រូវបង្កើតយន្តការដែលមានគោលដៅផ្តល់កិច្ចសហប្រតិបត្តិការផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស រួមទាំងបន្លាស់ប្តូរផ្នែកបច្ចេកទេសទៅឱ្យភាគីដទៃ ដែលស្ថិតនៅក្រោមកថាខណ្ឌ១ មាត្រា៥នៃពិធីសារនេះ ដើម្បីជួយឱ្យការអនុវត្តរបស់គេទៅតាមមាត្រា២A រហូតដល់មាត្រា*២I និងមាត្រា២J* និងវិធានការត្រួតពិនិត្យក្នុងមាត្រា២J រហូតដល់មាត្រា២H ដែលអាចសម្រេចបានឡើងដោយផ្អែកទៅលើកថាខណ្ឌ១bis នៃមាត្រា៥ របស់ពីធីសារនេះ។ យន្តការនិងការផ្តល់ផ្នែកហិរញ្ញវត្ថុនឹងត្រូវបញ្ជូនទៅឱ្យភាគីដែលអនុវត្តតាមកថាខណ្ឌនេះ ត្រូវឆ្លើយតបតម្លៃបន្ថែម ដែលបានព្រមព្រៀងដោយភាគីទាំងនោះ ដើម្បីឱ្យវិធានការត្រួតពិនិត្យរបស់ពិធីសារនេះប្រព្រឹត្តទៅមុខបាន។ តារាងបង្ហាញសន្ទស្សន៍មួយនៃតម្លៃបន្ថែមត្រូវតែសម្រេចដោយការប្រជុំភាគី។

២- យន្តការដែលបានបង្កើតឡើងក្រោមកថាខណ្ឌ១ នឹងត្រូវបន្ថែមមូលនិធិពហុភាគី។ វិធានការនេះក៏អាចបញ្ចូលនូវកិច្ចសហប្រតិបត្តិការជាលក្ខណៈពហុភាគី ជាលក្ខណៈតំបន់ និងជាលក្ខណៈទ្វេភាគី។ *ពេលភាគីអនុវត្តតាមកថាខណ្ឌ១ នៃមាត្រា៥ជ្រើសរើស ដើម្បីទទួលការផ្តល់មូលនិធិដល់ខ្លួនតាមយន្តការហិរញ្ញវត្ថុណាមួយផ្សេងទៀតដែលអាចជាលទ្ធផលក្នុងការបំពេញផ្នែកមួយនៃការចំណាយបន្ថែមត្រូវបានយល់ព្រមបន្ថែមការចំណាយ ដែលផ្អែកនឹងមិនឈានដល់យន្តការហិរញ្ញវត្ថុនៅក្រោមមាត្រា១០ នៃពិធីសារនេះ។*

៣- មូលនិធិពហុភាគីត្រូវ៖

(a) ឆ្លើយតបទៅនឹងមូលដ្ឋានដ៏សមស្រប នៃជំនួយឬសម្បទាន និងអនុលោមទៅតាមលក្ខណៈវិនិច្ឆ័យដែលត្រូវសម្រេចដោយភាគីទៅលើតម្លៃបន្ថែមដែលបានព្រមព្រៀងគ្នា។

(b) មុខងាររបស់ផ្នែកមួយនៃលេខាធិការដ្ឋានដែលទទួលបន្ទុកហិរញ្ញវត្ថុ៖

i. ជួយដល់ការអនុវត្តរបស់ភាគីដែលប្រព្រឹត្តទៅតាមកថាខណ្ឌ១ នៃមាត្រា៥ តាមរយៈការសិក្សាជាក់លាក់ក្នុងប្រទេស និងតាមរយៈកិច្ចសហការផ្នែកបច្ចេកទេសសំដៅបង្ហាញនូវតម្រូវការលើកិច្ចសហការ។

ii. សម្របសម្រួលកិច្ចសហការផ្នែកបច្ចេកទេសដើម្បីឆ្លើយតបទៅនឹងតម្រូវការសហការ។

iii. ចែកចាយព័ត៌មាននិងសម្ភារៈដែលពាក់ព័ន្ធ បើកសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងសកម្មភាពទាក់ទងផ្សេងទៀត ដើម្បីជាផលប្រយោជន៍របស់ប្រទេសកំពុងអភិវឌ្ឍន៍។

iv. សម្របសម្រួល និងត្រួតពិនិត្យទៅលើកិច្ចសហការរវាងពហុភាគី តំបន់និងទ្វេភាគីដែលបង្កលក្ខណៈល្អប្រសើរដល់ភាគីជាសមាជិកដែលជាប្រទេសកំពុងអភិវឌ្ឍន៍។

(c) ការផ្តល់ផ្នែកហិរញ្ញវត្ថុដល់សេវាកម្មរបស់លេខាធិការដ្ឋាននូវមូលនិធិពហុភាគីនិងតម្លៃទ្រទ្រង់ការងារ។

៤- មូលនិធិពហុភាគី ត្រូវប្រតិបត្តិក្រោមសិទ្ធិអំណាចរបស់ភាគី ដែលត្រូវសម្រេចទៅលើនយោបាយរួម។

៥- ភាគីត្រូវបង្កើតគណៈកម្មាធិការប្រតិបត្តិ សំដៅអភិវឌ្ឍន៍ និងត្រួតពិនិត្យទៅលើការអនុវត្តនយោបាយប្រតិបត្តិគោលការណ៍ណែនាំ និងការរៀបចំគ្រប់គ្រងរួមមានការចំណាយធនធានសម្រាប់បំពេញកម្មវត្ថុនៃមូលនិធិពហុភាគី។ គណៈកម្មាធិការប្រតិបត្តិត្រូវបំពេញការងារនិងការទទួលខុសត្រូវ ដូចមានបញ្ជាក់នៅក្នុងលក្ខខណ្ឌយោងដែលបានព្រមព្រៀងដោយភាគីដោយមានការសហការ និងការជួយជ្រោមជ្រែងពីធនាគារអន្តរជាតិដើម្បីការសាងសង់ឡើងវិញនិងការអភិវឌ្ឍ (ធនាគារពិភពលោក) កម្មវិធីបរិស្ថានរបស់សហប្រជាជាតិ កម្មវិធីអភិវឌ្ឍន៍របស់សហប្រជាជាតិ ឬទីភ្នាក់ងារផ្សេងទៀតដែលអាស្រ័យទៅនឹងជំនាញរបស់គេផ្ទាល់។ សមាជិកគណៈកម្មាធិការប្រតិបត្តិ ត្រូវបានជ្រើសរើសតាមការអនុម័តរបស់ភាគីជាសមាជិកដោយផ្អែកទៅតាមគោលការណ៍តុល្យភាពរវាងតំណាងភាគីដែលអនុវត្តតាមកថាខណ្ឌ១ នៃមាត្រា៥ និងតំណាងឱ្យភាគីដែលពុំសូវបានអនុវត្តតាម។

៦- តាមរយៈការរួមចំណែកពីភាគីដែលពុំអនុវត្តតាមកថាខណ្ឌ១នៃមាត្រា៥ មូលនិធិពហុភាគីនឹងត្រូវផ្តល់ជារូបិយវត្ថុអន្តរជាតិឬជារូបិយវត្ថុជាតិ ដោយផ្អែកទៅតាមកម្រិតប៉ាន់ស្មានរបស់សហប្រជាជាតិ។ ការរួមចំណែកដោយភាគីដទៃទៀតនឹងត្រូវបានលើកទឹកចិត្ត។ ក្នុងករណីព្រមព្រៀងដោយសារការសម្រេចពីភាគី កិច្ចសហការជាលក្ខណៈទ្វេភាគី និងជាលក្ខណៈតំបន់អាចកើនឡើង និងស្របជាមួយលក្ខណៈវិនិច្ឆ័យ ដែលបញ្ជាក់ដោយការសម្រេចរបស់ភាគីនឹងត្រូវចាត់ទុកជាការរួមចំណែកចំពោះមូលនិធិពហុភាគីដូចដែលបានចែងចំពោះការសហការក្នុងកម្រិតអប្បបរមា៖

(a) អនុលោមទៅតាមសេចក្តីចែងក្នុងពិធីសារនេះ

(b) ផ្តល់នូវធនធានបន្ថែម

(c) ឆ្លើយតបទៅនឹងតម្លៃបន្ថែមដែលបានព្រមព្រៀង

៧- ភាគីត្រូវសម្រេចដោយផ្អែកទៅលើកម្មវិធីថវិការបស់មូលនិធិពហុភាគី សម្រាប់ឆ្នាំសារពើពន្ធនីមួយៗ និងផ្អែកទៅលើភាគរយនៃការចូលរួមរបស់ភាគីនីមួយៗ។

៨- ធនធានរបស់ពហុភាគី នឹងត្រូវចំណាយដែលស្មើនឹងបរិមាណដែលភាគីត្រូវបានទទួល។

៩- សេចក្តីសម្រេចទៅតាមមាត្រានេះដោយភាគីជាសមាជិក អាចនឹងត្រូវអនុម័តទៅតាមមតិទូទៅ។

ប្រសិនបើកិច្ចប្រឹងប្រែងពុំត្រូវបានឈានទៅរកកិច្ចព្រមព្រៀង នោះសេចក្តីសម្រេចនឹងត្រូវអនុម័តតាមរយៈការបោះឆ្នោតសំឡេងពីរភាគបី នៃវត្តមានភាគីចូលរួមនិងបោះឆ្នោតដែលតំណាងឱ្យសំឡេងភាគច្រើនរបស់ភាគីស្ថិតក្នុងកថាខណ្ឌ១នៃមាត្រា៥ ។

១០- យន្តការផ្នែកហិរញ្ញវត្ថុដែលបានកំណត់ក្នុងមាត្រានេះ មិនបានគិតលើកិច្ចព្រមព្រៀងនាពេលអនាគតដែលអាចវិវត្តទៅតាមបញ្ហាបរិស្ថានផ្សេងទៀតនោះទេ។

មាត្រា១០A បន្លាស់ប្តូរផ្នែកបច្ចេកវិទ្យា

ភាគីនីមួយៗ ត្រូវចាត់វិធានការដែលអាចអនុវត្តបានស្របទៅនឹងកម្មវិធីគាំទ្រដោយយន្តការហិរញ្ញវត្ថុ ដើម្បីធានាថា៖

(a) ការជំនួសដែលមានសុវត្ថិភាពខាងផ្នែកបរិស្ថាននិងបច្ចេកវិទ្យា ត្រូវបានធ្វើការផ្លាស់ប្តូរដល់ភាគីស្ថិតក្នុងកថាខណ្ឌ១ មាត្រា៥ និង

(b) ការផ្លាស់ប្តូរដោយយោងទៅតាមអនុកថាខណ្ឌ(a)ត្រូវបានធ្វើឡើងក្នុងលក្ខខណ្ឌល្អសមស្រប

មាត្រា១១ ការប្រជុំរបស់ភាគី

១- ភាគីត្រូវបើកកិច្ចប្រជុំឱ្យបានទៀងទាត់។ លេខាធិការដ្ឋានត្រូវកោះហៅភាគីជាសមាជិកមកប្រជុំយ៉ាងតិចឱ្យបានមុនមួយឆ្នាំនៃពិធីសារនេះបានចូលជាធរមាន និងក្នុងកិច្ចប្រជុំសន្និបាតភាគីអនុសញ្ញា ប្រសិនបើការប្រជុំចុងក្រោយត្រូវបានកំណត់ពេលក្នុងរយៈពេលនោះ។

២- កិច្ចប្រជុំរបស់ភាគីត្រូវធ្វើឡើង លុះត្រាតែភាគីសម្រេចនៅក្នុងការប្រជុំក្នុងសន្និបាតរបស់ភាគីអនុសញ្ញា។ កិច្ចប្រជុំវិសាមញ្ញរបស់ភាគី នឹងត្រូវធ្វើឡើងនៅពេលណាមួយទៅតាមតម្រូវការចាំបាច់របស់ភាគីជាសមាជិក ឬតាមរយៈសំណើសុំជាលាយលក្ខណ៍អក្សររបស់ភាគី ដូចបង្ហាញថាក្នុងរយៈពេលប្រាំមួយខែ ដែលសេចក្តីស្នើសុំបានដល់ភាគីជាសមាជិកតាមរយៈលេខាធិការដ្ឋាននឹងត្រូវមានការគាំទ្រយ៉ាងហោចណាស់មួយភាគបីនៃភាគីជាសមាជិក។

៣- នៅក្នុងកិច្ចប្រជុំលើកទីមួយ ភាគីជាសមាជិកត្រូវ៖

(a) អនុម័តដោយវិធានឯកភាពនៃដំណើរការសម្រាប់កិច្ចប្រជុំរបស់គេ

(b) អនុម័តដោយវិធានឯកភាពផ្នែកហិរញ្ញវត្ថុ ដោយយោងតាមកថាខណ្ឌ២នៃមាត្រា១៣

(c) បង្កើតក្រុម និងកំណត់លក្ខខណ្ឌ ដោយយោងតាមមាត្រា៦

(d) ពិចារណានិងអនុម័តទៅលើដំណើរការ និងយន្តការរបស់ស្ថាប័ន ដូចបានបញ្ជាក់ក្នុងមាត្រា៨ និង

(e) ចាប់ផ្តើមរៀបចំផែនការ ដោយអនុលោមទៅតាមកថាខណ្ឌ៣ មាត្រា១០

៤- មុខងាររបស់ភាគីជាសមាជិកនៅក្នុងកិច្ចប្រជុំ៖

(a) ពិនិត្យឡើងវិញនូវការអនុវត្តពិធីសារនេះ

(b) ធ្វើសេចក្តីសម្រេចលើការកែតម្រូវ ឬកាត់បន្ថយ ដោយយោងតាមកថាខណ្ឌ៩ មាត្រា២

(c) ធ្វើសេចក្តីសម្រេចលើការបន្ថែម ការដាក់បញ្ចូលឬការដកចេញពីឧបសម្ព័ន្ធនៃសារធាតុឬវិធានការត្រួតពិនិត្យផ្សេងៗដោយយោងតាមកថាខណ្ឌ១០ មាត្រា២

(d) បង្កើតគោលការណ៍ណែនាំ ឬនីតិវិធីសម្រាប់ធ្វើរបាយការណ៍ស្តីពីព័ត៌មានដូចបានចែងក្នុងមាត្រា៧ និងក្នុងកថាខណ្ឌ៣ មាត្រា៩

(e) ពិនិត្យឡើងវិញលើសំណើសុំជំនួយផ្នែកបច្ចេកទេស ដែលបានដាក់ស្នើសុំដោយយោងតាមអនុកថាខណ្ឌ៩ មាត្រា១២

(f) ពិនិត្យឡើងវិញទៅលើរបាយការណ៍ ដែលបានរៀបចំដោយលេខាធិការដ្ឋាន ដោយយោងតាមអនុកថាខណ្ឌ (c) មាត្រា១២

(g) វាយតម្លៃដោយយោងតាមមាត្រា៦ នូវវិធានការត្រួតពិនិត្យ

(h) ពិចារណា និងអនុម័តតាមតម្រូវការនូវសំណើសុំធ្វើវិសោធនកម្មពិធីសារនេះ ឬឧបសម្ព័ន្ធមួយចំនួន ឬបង្កើតឧបសម្ព័ន្ធថ្មី

(i) ពិចារណា និងអនុម័តទៅលើថវិកាសម្រាប់ការអនុវត្តពិធីសារនេះ

(j) ពិចារណា និងអនុវត្តសកម្មភាពបន្ថែមមួយចំនួន ដែលត្រូវការសម្រាប់សម្រេចគោលបំណងនៃពិធីសារនេះ។

៥- សហប្រជាជាតិ ជាភ្នាក់ងារឯកទេស និងទីភ្នាក់ងារថាមពលអាតូមិចអន្តរជាតិ ក៏ដូចជាប្រទេសពុំមែនជាភាគីនៃពិធីសារនេះអាចជាអ្នកអង្កេតការណ៍នៅក្នុងកិច្ចប្រជុំ។ បុគ្គលទាំងឡាយឬទីភ្នាក់ងារដែលតំណាងឱ្យជាតិ ឬតំណាងឱ្យអន្តរជាតិ តំណាងឱ្យរដ្ឋាភិបាល ឬមិនមែនរដ្ឋាភិបាល ដែលទាក់ទងនឹងការងារការពារស្រទាប់អូហ្សូន ដែលបានជូនដំណឹងទៅលេខាធិការដ្ឋានអំពីគោលបំណងដែលគេមានវត្តមានក្នុងនាមជាអ្នកអង្កេតការណ៍ លុះត្រាតែត្រូវបានអនុញ្ញាតដោយភាគីជាសមាជិកមួយភាគបីនៃសមាជិកទាំងអស់។ ការអនុញ្ញាតនិងការចូលរួមរបស់អ្នកអង្កេតការណ៍នឹងត្រូវជាប្រធានបទឬជានីតិវិធីដែលត្រូវអនុម័តដោយភាគី។

មាត្រា១២ លេខាធិការដ្ឋាន

គោលបំណងនៃពិធីសារនេះ លេខាធិការដ្ឋានត្រូវ៖

(a) រៀបចំកិច្ចប្រជុំរបស់ភាគី ដូចមានចែងក្នុងមាត្រា១១

(b) ទទួល និងរៀបចំទិន្នន័យតាមសំណើរបស់ភាគី ដោយអនុលោមតាមមាត្រា៧

(c) រៀបចំនិងផ្តល់របាយការណ៍ឱ្យបានទៀងទាត់ដល់ភាគីជាសមាជិក ដោយផ្អែកទៅតាមព័ត៌មានដែលទទួលបាន ដូចមានចែងក្នុងមាត្រា៧ និងមាត្រា៩ ។

(d) ជូនព័ត៌មានទៅភាគីនូវសំណើសុំជំនួយបច្ចេកទេសដែលបានទទួលដោយអនុលោមតាម មាត្រា១០ ដើម្បីសម្រួលដល់ការផ្តល់ជំនួយ។

(d) ជំរុញលើកទឹកចិត្តឱ្យប្រទេសដែលពុំមែនជាភាគីនៃអនុសញ្ញា ចូលរួមក្នុងកិច្ចប្រជុំរបស់ភាគី ក្នុងឋានៈជាអ្នកអង្កេតការណ៍ និងដើរតួដូចមានចែងក្នុងពិធីសារនេះ។

(e) ផ្តល់ព័ត៌មាននិងសំណើសុំដោយយោងតាមអនុកថាខណ្ឌ៩ (c) និង (d) ដល់អ្នកអង្កេតការណ៍

(f) បង្ហាញពីមុខងារ ដើម្បីសម្រេចគោលបំណងពិធីសារនេះ ដូចដែលអាចត្រូវបានផ្តល់ទៅឱ្យ ដោយភាគី។

មាត្រា១៣ ផ្នែកហិរញ្ញវត្ថុ

១- មូលនិធិសម្រាប់អនុវត្តពិធីសារនេះ រួមមានមូលនិធិសម្រាប់មុខងាររបស់លេខាធិការដ្ឋាន ដែល ពាក់ព័ន្ធនឹងពិធីសារនេះនឹងត្រូវផ្តល់ភារកិច្ចដោយឡែកពីការចូលរួមរបស់ភាគីជាសមាជិក។

២- ក្នុងកិច្ចប្រជុំលើកដំបូង ភាគីត្រូវអនុម័តដោយមតិរួមលើផ្នែកហិរញ្ញវត្ថុសម្រាប់ការអនុវត្តពិធីសារនេះ។

មាត្រា១៤ ទំនាក់ទំនងរវាងពិធីសារនិងអនុសញ្ញា

សេចក្តីដែលមានចែងក្នុងអនុសញ្ញាដែលទាក់ទងពិធីសារនេះ នឹងត្រូវអនុវត្តចំពោះពិធីសារនេះ លើក លែងតែពុំមានចែងក្នុងពិធីសារនេះ។

មាត្រា១៥ ការចុះហត្ថលេខា

ពិធីសារនេះ នឹងបើកឱ្យការចុះហត្ថលេខាដោយរដ្ឋ និងដោយអង្គការសមាហរណកម្មសេដ្ឋកិច្ច ក្នុងតំបន់ក្នុងកិច្ចប្រជុំនៅម៉ុងរ៉េអាល់ នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៨៧ និងនៅអូតាវ៉ា ចាប់ពីថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៨៧ រហូតដល់ថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៨៨ និងនៅទីស្នាក់ការសហប្រជាជាតិ ក្នុងទីក្រុងញូវយ៉ក ចាប់ពីថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៨៨ រហូតដល់ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៨៨។

មាត្រា១៦ ការចូលជាធរមាន

១- ពិធីសារនេះ នឹងចូលជាធរមាននៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៨៩ ដែលចែងថា យ៉ាងហោចណាស់ មានឯកសារច្បាប់ចំនួន១១ សម្រាប់ផ្តល់សច្ចាប័ន ការទទួលយកការអនុម័តលើពិធីសារ ឬចូលជា ធរមានត្រូវតម្កល់ទុកដោយរដ្ឋ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ដែលតំណាងឱ្យយ៉ាងតិច ពីរភាគបី នៃការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យទូទាំងពិភពលោកនាឆ្នាំ១៩៨៦ និងមានចែងក្នុង កថាខណ្ឌ១ មាត្រា១៧ នៃអនុសញ្ញាត្រូវបានបំពេញ។ ក្នុងករណីដែលលក្ខខណ្ឌ ទាំងនេះមិនទាន់ ត្រូវបានបំពេញតាមកាលបរិច្ឆេទកំណត់ នោះពិធីសារនឹងត្រូវចូលជាធរមានក្នុងរយៈពេល៩០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទដែលលក្ខខណ្ឌត្រូវបានបំពេញ ។

២- សម្រាប់គោលបំណងកថាខណ្ឌ១ ឯកសារច្បាប់ទាំងឡាយដែលបានដាក់ស្នើដោយអង្គការសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ មិនត្រូវបានរាប់បញ្ចូលជាមួយនឹងការដាក់ស្នើរបស់រដ្ឋ ឬប្រទេសដែលស្ថិតក្នុងអង្គការនេះឡើយ។

៣- បន្ទាប់ពីពិធីសារនេះចូលជាធរមាន រដ្ឋឬអង្គការសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ នឹងក្លាយជាភាគីរបស់ពិធីសារនេះក្នុងរយៈពេល៩០ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការដាក់ស្នើនូវឯកសារច្បាប់ដើម្បីផ្តល់សច្ចាប័ន ការទទួលយកការអនុម័ត ឬចូលជាធរមាន។

មាត្រា១៧ ការចូលរួមរបស់ភាគីបន្ទាប់ពីពិធីសារចូលជាធរមាន

ផ្អែកតាមមាត្រា៥ បន្ទាប់ពីថ្ងៃដែលពិធីសារនេះបានចូលជាធរមាន រដ្ឋឬអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ដែលនឹងក្លាយជាភាគីនៃពិធីសារនេះ ត្រូវបំពេញជាបន្ទាន់នូវកាតព្វកិច្ចមួយចំនួនដូចមានចែងក្នុងមាត្រា២ ក៏ដូចជាក្នុងមាត្រា២A រហូតដល់មាត្រា២I និងមាត្រា៤ ដែលនឹងត្រូវអនុវត្តនៅថ្ងៃដែលរដ្ឋឬអង្គការសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់បានក្លាយទៅជាភាគីសមាជិករបស់ពិធីសារនេះបានចូលជាធរមាន។

មាត្រា១៨ ការបម្រុងទុក

ពុំមានការបម្រុងទុក ដែលបានធ្វើឡើងសម្រាប់ពិធីសារនេះ ។

មាត្រា១៩ ការដកចេញ

ភាគីទាំងឡាយអាចដកខ្លួនចេញពីពិធីសារនេះ ដោយគ្រាន់តែផ្តល់ដំណឹងជាលាយលក្ខណ៍អក្សរទៅកាន់កន្លែងតម្កល់ឯកសារ លេខាធិការដ្ឋានក្នុងពេលណាក៏បានបន្ទាប់ពីរយៈពេលបួនឆ្នាំនៃការទទួលខុសត្រូវទៅលើកាតព្វកិច្ច ដូចបានបញ្ជាក់ក្នុងកថាខណ្ឌ១ នៃមាត្រា២A។ ការដកខ្លួនចេញនេះនឹងមានប្រសិទ្ធភាពក្រោយពីរយៈពេលមួយឆ្នាំដោយគិតចាប់ពីថ្ងៃដែលលេខាធិការដ្ឋានទទួលនូវពាក្យសុំដកខ្លួនចេញពីពិធីសារនេះ ឬក្រោយថ្ងៃដែលបញ្ជាក់ក្នុងលិខិតសុំដកខ្លួនចេញ។

មាត្រា២០ អត្ថបទយថាភូត

ឯកសារដើមរបស់ពិធីសារនេះ សរសេរជាភាសាអារ៉ាប់ ចិន អង់គ្លេស រុស្ស៊ី និងអេស្ប៉ាញ គឺមានតម្លៃស្មើគ្នាតាមលក្ខណៈច្បាប់នឹងត្រូវតម្កល់នៅអគ្គលេខាធិការដ្ឋានសហប្រជាជាតិ។

ដើម្បីជាសក្ខីភាព ហត្ថលេខីដែលមានឥទ្ធិពលទៅលើពិធីសារហើយទទួលការអនុញ្ញាតត្រឹមត្រូវបានចុះហត្ថលេខាលើពិធីសារនេះ

ធ្វើនៅទីក្រុងម៉ុងរ៉េអាល់ ថ្ងៃទីដប់ប្រាំមួយ ខែកញ្ញា ឆ្នាំមួយពាន់ប្រាំបួនរយប៉ែតសិបប្រាំពីរ

ឧបសម្ព័ន្ធA សារធាតុដែលត្រូវត្រួតពិនិត្យ

ក្រុម	សារធាតុ	សក្តានុពលបំផ្លាញស្រទាប់អូហ្សូន	១០០ឆ្នាំ សក្តានុពលដល់កំណើនកម្តៅផែនដី
ក្រុម១			
$CFCl_3$	(CFC-11)	1.0	4,750
CF_2Cl_2	(CFC-12)	1.0	10,900
$C_2F_3Cl_3$	(CFC-113)	0.8	6,130
$C_2F_4Cl_2$	(CFC-114)	1.0	10,000
C_2F_5Cl	(CFC-115)	0.6	7,370
ក្រុម២			
CF_2BrCl	(halon-1211)	3.0	
CF_3Br	(halon-1301)	10.0	
$C_2F_4Br_2$	(halon-2402)	6.0	

ក្រុមសារធាតុមានសក្តានុពលការបំផ្លាញស្រទាប់អូហ្សូន ត្រូវបានប៉ាន់ស្មានផ្អែកតាមចំណេះដឹងដែលមានស្រាប់ និងអាចត្រួតពិនិត្យឡើងវិញ និងកែតម្រូវទៅតាមដំណាក់កាល។

ឧបសម្ព័ន្ធB សារធាតុដែលត្រូវត្រួតពិនិត្យ

ក្រុម	សារធាតុ	សក្តានុពលបំផ្លាញស្រទាប់អូហ្សូន
ក្រុម១		
CF_3Cl	(CFC-13)	1.0
C_2FCl_5	(CFC-111)	1.0
$C_2F_2Cl_4$	(CFC-112)	1.0
C_3FCl_7	(CFC-211)	1.0
$C_3F_2Cl_6$	(CFC-212)	1.0
$C_3F_3Cl_5$	(CFC-213)	1.0
$C_3F_4Cl_4$	(CFC-214)	1.0
$C_3F_5Cl_3$	(CFC-215)	1.0
$C_3F_6Cl_2$	(CFC-216)	1.0
C_3F_7Cl	(CFC-217)	1.0
ក្រុម២		
CCl_4	carbon tetrachloride	1.1
ក្រុម៣		
$C_2H_3Cl_3$*	1,1,1-trichloroethane* (methyl chloroform)	0.1

*រូបមន្តនេះមិនសំដៅដល់ 1,1,2- trichloroethane.

ឧបសម្ព័ន្ធC សារធាតុដែលត្រូវត្រួតពិនិត្យ

ក្រុម	សារធាតុ	ចំនួនអ៊ីសូម៉ែរ	សក្តានុពលបំផ្លាញស្រទាប់អូហ្សូន	១០០ឆ្នាំ សក្តានុពលកំណើនកម្តៅផែនដី***
ក្រុម១				
$CHFCl_2$	(CFC-21)**	1	0.04	151
CHF_2Cl	(HCF-22)**	1	0.055	1810
CH_2FCl	(HCFC-31)	1	0.02	
C_2HFCl_4	(HCFC-121)	2	0.01-0.04	
C_2HFCl_3	(HCFC-122)	3	0.02-0.08	
$C_2HF_2Cl_2$	(HCFC-123)	3	0.02-0.06	77
$CHCl_2CF_3$	(HCFC-123)**		0.02	
C_2HF_4Cl	(HCFC-124)	2	0.02-0.04	609
$CHFClCF_3$	(HCFC-124)**		0.022	
$C_2H_2FCl_3$	(HCFC-131)	3	0.07-0.05	
$C_2H_2F_2Cl_2$	(HCFC-132)	4	0.08-0.05	
$C_2H_2F_3Cl$	(HCFC-133)	3	0.02-0.06	
$C_2H_3FCl_2$	(HCFC-141)	3	0.05-0.07	
CH_3CFCl_2	(HCFC-141b)**		0.11	725
$C_2H_3F_2Cl$	(HCFC-142)	3	0.08-0.07	
CH_3CF_2Cl	(HCFC-142b)**		0.065	2310
C_2H_4FCl	(HCFC-151)	2	0.003-0.005	
C_3HFCl_6	(HCFC-221)	5	0.015-0.07	
$C_3HF_2Cl_5$	(HCFC-222)	9	0.01-0.09	
$C_3HF_3Cl_4$	(HCFC-223)	12	0.01-0.08	
$C_3HF_4Cl_3$	(HCFC-224)	12	0.01-0.09	
$C_3HF_5Cl_2$	(HCFC-225)	9	0.02-0.07	
$CF_3CF_2CHCl_2$	(HCFC-225ca)**		0.025	122
CF_2ClCF_2CHClF	(HCFC-225cb)**		0.033	595
C_3HF_6Cl	(HCFC-226)	5	0.02-0.10	
$C_3H_2FCl_5$	(HCFC-231)	9	0.05-0.09	
$C_3H_2F_2Cl_4$	(HCFC-232)	16	0.008-0.10	
$C_3H_2F_3Cl_3$	(HCFC-233)	18	0.007-0.23	
$C_3H_2F_4Cl_2$	(HCFC-234)	16	0.01-0.28	
$C_3H_2F_5Cl$	(HCFC-235)	9	0.03-0.52	
$C_3H_3FCl_4$	(HCFC-241)	12	0.004-0.09	
$C_3H_3F_2Cl_3$	(HCFC-242)	18	0.005-0.13	
$C_3H_3F_3Cl_2$	(HCFC-243)	18	0.007-0.12	
$C_3H_3F_4Cl$	(HCFC-244)	12	0.009-0.14	
$C_3H_4FCl_3$	(HCFC-251)	12	0.001-0.01	

$C_3H_4F_2Cl_2$	(HCFC-252)	12	0.005-0.04	
$C_3H_4F_3Cl$	(HCFC-253)	12	0.003-0.03	
$C_3H_5FCl_2$	(HCFC-261)	9	0.002-0.02	
$C_3H_5F_2Cl$	(HCFC-262)	9	0.002-0.02	
C_3H_6FCl	(HCFC-271)	5	0.001-0.03	

ក្រុម	សារធាតុ	ចំនួនអ៊ីសូម៉ែរ	សក្តានុពលបំផ្លាញស្រទាប់អូហ្សូន
ក្រុម២			
$CHFBr_2$		1	1
CHF_2Br	(HBFC-22B1)	1	0.74
CH_2F_2Br		1	0.73
C_2HFBr_4		2	0.3-0.8
$C_2HF_2Br_3$		3	0.5-1.8
$C_2HF_3Br_2$		3	0.4-1.6
C_2HF_4Br		2	0.7-1.2
$C_2H_2FBr_3$		3	0.1-1.1
$C_2H_2F_2Br_2$		4	0.2-1.5
$C_2H_2F_3Br$		3	0.7-1.6
$C_2H_3FBr_2$		3	0.1-1.7
$C_2H_3F_2Br$		3	0.2-1.1
C_2H_4FBr		2	0.07-0.1
C_3HFBr_6		5	0.3-1.5
$C_3HF_2Br_5$		9	0.2-1.9
$C_3HF_3Br_4$		12	0.3-1.8
$C_3HF_4Br_3$		12	0.5-2.2
$C_3HF_5Br_2$		9	0.9-2.0
C_3HF_6Br		5	0.7-3.3
$C_3H_2FBr_5$		9	0.1-1.9
$C_3H_2F_2Br_4$		16	0.2-2.1

$C_3H_2F_3Br_3$		18	0.2-2.6
$C_3H_2F_4Br_2$		16	0.3-7.5
$C_3H_2F_5Br$		8	0.9-1.4
$C_2H_3FBr_2$		3	0.1-1.7
$C_3H_3FBr_4$		12	0.08-1.9
$C_3H_3F_2Br_3$		18	0.1-3.1
$C_3H_3F_3Br_2$		18	0.1-2.5
$C_3H_3F_4Br$		12	0.3-4.4
$C_3H_4FBr_3$		12	0.03-0.3
$C_3H_4F_2Br_2$		16	0.1-1.0
$C_3H_4F_3Br$		12	0.07-0.8
$C_3H_5FBr_2$		9	0.04-0.4
$C_3H_5F_2Br$		9	0.07-0.8
C_3H_6FBr		5	0.02-0.7
ក្រុម៣			
CH_2BrCl	bromochloromethane	1	0.12

**ចន្លោះតម្លៃរបស់សក្តានុពលនៃការបំផ្លាញស្រទាប់អូហ្សូន ត្រូវបានបង្ហាញដែលក្នុងនោះតម្លៃខ្ពស់បំផុតត្រូវបានប្រើសម្រាប់គោលបំណងនៃពិធីសារនេះ។ សក្តានុពលនៃការបំផ្លាញស្រទាប់អូហ្សូន បានចុះបញ្ជីជាតម្លៃទោលត្រូវបានកំណត់តាមការគណនាដោយផ្អែកលើវិធានការរបស់មន្ទីរពិសោធន៍។ តម្លៃដែលបានចុះបញ្ជីដោយស្ថិតនៅចន្លោះតម្លៃកំណត់ គឺផ្អែកទៅតាមតម្លៃប៉ាន់ស្មាននិងពុំសូវជាក់លាក់។ តម្លៃដែលស្ថិតនៅចន្លោះបានកំណត់មានការទាក់ទងទៅនឹងក្រុមអ៊ីសូម៉ែរ។ តម្លៃខ្ពស់ជាការវាយតម្លៃទៅលើសក្តានុពលនៃការបំផ្លាញស្រទាប់អូហ្សូន របស់អ៊ីសូម៉ែរដែលមានសក្តានុពលខ្ពស់បំផុតទៅលើការបំផ្លាញស្រទាប់អូហ្សូន ចំណែកតម្លៃទាប គឺជាការប៉ាន់ប្រមាណលើសក្តានុពលនៃការបំផ្លាញស្រទាប់អូហ្សូនរបស់អ៊ីសូម៉ែរដែលមានតម្លៃសក្តានុពលនៃការបំផ្លាញស្រទាប់អូហ្សូនក្នុងកម្រិតទាបបំផុត។*

***កំណត់ទៅលើសារធាតុដែលអាចធ្វើពាណិជ្ជបានរួមជាមួយនឹងតម្លៃសក្តានុពលនៃការបំផ្លាញស្រទាប់អូហ្សូនដែលបានចុះបញ្ជីប្រើប្រាស់សម្រាប់គោលបំណងរបស់ពិធីសារ។*

****សារធាតុដែលគ្មានសក្តានុពលដល់កំណើនកម្តៅផែនដី ត្រូវបានឱ្យស្មើសូន្យ លុះត្រាតែតម្លៃសក្តានុពលកំណើនកម្តៅផែនដី រួមបញ្ចូលមធ្យោបាយនៃដំណើរការដែលបានព្យាករណ៍ក្នុងកថាខណ្ឌ៩ (a) (ii) នៃមាត្រា២។*

ឧបសម្ព័ន្ធD បញ្ជីឈ្មោះផលិតផលដែលមានផ្ទុកសារធាតុដែលត្រូវត្រួតពិនិត្យដូចមានបញ្ជាក់នៅក្នុងឧបសម្ព័ន្ធA

ផលិតផល	លេខកូតគយ
១- ម៉ាស៊ីនត្រជាក់នៅក្នុងរថយន្តដឹកទំនិញ និងរថយន្តផ្សេងៗ មាននៅក្នុងយានយន្តឬអត់	....
២- សម្ភារៈម៉ាស៊ីនបឺតកម្តៅ ម៉ាស៊ីនត្រជាក់ ទូទឹកកក ដែលប្រើប្រាស់ក្នុងលំនៅដ្ឋាននិងសម្រាប់ប្រកបអាជីវកម្មផ្សេងៗ។ល។	....
ឧទាហរណ៍ - ទូទឹកកក	....
- ទូត្លាស្សេ	....
- ម៉ាស៊ីនសម្ងួត	....
- ម៉ាស៊ីនដើម្បីធ្វើឱ្យទឹកត្រជាក់	....
- ម៉ាស៊ីនផលិតទឹកកក	....
- ឧបករណ៍បឺតកម្តៅនិងឧបករណ៍ម៉ាស៊ីនត្រជាក់	....
៣- ផលិតផល Aerosol លើកលែងតែផលិតផលឱសថមានលក្ខណៈ Aerosols	....
៤- ឧបករណ៍ពន្លត់អគ្គិភ័យចល័ត	....
៥- សារធាតុអ៊ីសូឡង់ដែលប្រើប្រាស់សម្រាប់ការពារបំពង់ទឹក និងសារធាតុផ្សេងៗ	....
៦- សារធាតុមុននឹងក្លាយទៅជាសារធាតុប៉ូលីមែរ	....

*ឧបសម្ព័ន្ធនេះត្រូវបានអនុម័តដោយកិច្ចប្រជុំលើកទីបីរបស់ភាគីជាសមាជិក កាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩១ យោងតាមតម្រូវការរបស់កថាខណ្ឌ៣ នៃមាត្រា៤ របស់ពិធីសារ។

**ពេលផលិតផលដឹកជញ្ជូនដែលតម្រូវទៅតាមសេចក្តីត្រូវការរបស់បុគ្គល និងការប្រើប្រាស់ក្នុងលំនៅដ្ឋាន ឬស្ថិតក្នុងស្ថានភាពក្រៅពីការធ្វើជំនួញដែលជាធម្មតាគឺត្រូវបានស្ថាប័នគយលើកលែងការយកពន្ធ។

*** នៅពេលដែលមានសារធាតុដែលត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធA ដូចជាផលិតផលសារធាតុធ្វើឱ្យត្រជាក់ឬសារធាតុអ៊ីសូឡង់។

ឧបសម្ព័ន្ធE សារធាតុដែលត្រូវត្រួតពិនិត្យ

ក្រុម	សារធាតុ	សក្តានុពលបំផ្លាញស្រទាប់អូហ្សូន
ក្រុម ១		
CH_3Br	methyl bromide	0.6

ឧបសម្ព័ន្ធF សារធាតុដែលត្រូវត្រួតពិនិត្យ

ក្រុម	សារធាតុ	សក្តានុពលកំណើនកម្តៅផែនដីក្នុងរយៈពេល១០០ឆ្នាំ
ក្រុម ១		
CHF_2CHF_2	HFC-134	1,100
CH_2FCF_3	HFC-134a	1,430
CH_2FCHF_2	HFC-143	353
$CHF_2CH_2CF_3$	HFC-245fa	1,030
$CF_3CH_2CF_2CH_3$	HFC-365mfc	794
CF_3CHFCF_3	HFC-227ea	3,220
$CH_2FCF_2CF_3$	HFC-236cb	1,340
CHF_2CHFCF_3	HFC-236ea	1,370
$CF_3CH_2CF_3$	HFC-236fa	9,810
$CH_2FCF_2CHF_2$	HFC-245ca	693
$CF_3CHFCHCF_2CF_3$	HFC-43-10mee	1,640
CH_2F_2	HFC-32	675
CHF_2CF_3	HFC-125	3,500
CH_3CF_3	HFC-143a	4,470
CH_3F	HFC-41	92
CH_2FCH_2F	HFC-152	53
CH_3CHF_2	HFC-152a	124
ក្រុម៣		
CHF_3	HFC-23	14,800

វិសោធនកម្មពិធីសារម៉ុងរ៉េអាល់ ស្តីពីសារធាតុបំផ្លាញស្រទាប់អូហ្សូន

មាត្រា I វិសោធនកម្ម

មាត្រា១ កថាខណ្ឌ៤

នៅក្នុងកថាខណ្ឌ៤ មាត្រា១ នៃពិធីសារសម្រាប់ពាក្យ៖

"ឧបសម្ព័ន្ធC និងឧបសម្ព័ន្ធE"

នឹងត្រូវបានជំនួសដោយ

"ឧបសម្ព័ន្ធC ឧបសម្ព័ន្ធE និងឧបសម្ព័ន្ធF"

មាត្រា២ កថាខណ្ឌ៥

នៅក្នុងកថាខណ្ឌ៥ មាត្រា២ នៃពិធីសារសម្រាប់ពាក្យ៖

"និងឧបសម្ព័ន្ធ2H"

នឹងត្រូវជំនួសដោយ

"ឧបសម្ព័ន្ធ2H និង 2J"

មាត្រា២ កថាខណ្ឌ៨(a) ៩(a) និង១១

នៅក្នុងកថាខណ្ឌ៨(a) និងទី១១ មាត្រា២ នៃពិធីសារសម្រាប់ពាក្យ៖

"មាត្រា2A និង 2I"

នឹងត្រូវជំនួសដោយ៖

"មាត្រា2A និង 2J"

សម្រាប់ឃ្លាខាងក្រោមនេះនឹងត្រូវបានបន្ថែមនៅចុងបញ្ចប់ក្នុងអនុកថាខណ្ឌ(a) នៃកថាខណ្ឌ៨ មាត្រា២ នៃពិធីសារ៖

"កិច្ចព្រមព្រៀងណាមួយអាចនឹងត្រូវបានពន្យាពេលដើម្បីដាក់បញ្ចូលកាតព្វកិច្ច នៃការប្រើប្រាស់ឬការផលិតនៅក្នុងមាត្រា2J ដែលបានចែងថា បរិមាណសរុបនៃកម្រិតការប្រើប្រាស់ ឬការផលិត របស់ភាគីពាក់ព័ន្ធមិនត្រូវលើសពីកម្រិតដែលបានកំណត់ដោយមាត្រា2J"

នៅក្នុងអនុកថាខណ្ឌ(a) (iii) នៃកថាខណ្ឌ៩ មាត្រា២ នៃពិធីសារ បន្ទាប់ពីការប្រើប្រាស់ជាលើកទីពីរនៃពាក្យ

"គួរតែ"

នឹងត្រូវលុបចោល៖

"និង"

អនុកថាខណ្ឌ(a) (ii) នៃកថាខណ្ឌ៩ មាត្រា២ នៃពិធីសារនឹងត្រូវដាក់លេខថ្មីទៅជាអនុកថាខណ្ឌ (a)(iii)

ខាងក្រោមនេះនឹងត្រូវបន្ថែមអនុកថាខណ្ឌ (a)(ii) បន្ទាប់ពីអនុកថាខណ្ឌ (a)(i) នៃកថាខណ្ឌ៩ មាត្រា២ នៃពិធីសារ៖

"កែតម្រូវទៅតាមសក្តានុពលនៃការកើនឡើងកម្តៅផែនដីដែលបានបញ្ជាក់នៅក្នុងក្រុមI នៃឧបសម្ព័ន្ធA ឧបសម្ព័ន្ធC និងឧបសម្ព័ន្ធF គួរតែត្រូវបានបង្កើត ដូច្នេះអ្វីដែលគួរតែកែតម្រូវគឺ; និង"

មាត្រា២J

មាត្រាខាងក្រោមនេះនឹងត្រូវបន្ថែមបន្ទាប់ពីមាត្រា២I នៃពិធីសារៈ

"មាត្រា២J : Hydroflurocabons"

១- ភាគីនីមួយៗត្រូវធានាថាសម្រាប់រយៈពេល១២ខែ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ និងរៀងរាល់១២ខែ ជាបន្តបន្ទាប់ទៀត ការគណនាកម្រិតនៃការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធF ដែលបានបញ្ជាក់នៅក្នុងតារាងសមមូល CO_2 មិនឱ្យលើសភាគរយ (%) ដែលបានកំណត់ចេញនូវបរិមាណនៃឆ្នាំនីមួយៗដូចមានបញ្ជាក់នៅក្នុងអនុកថាខណ្ឌ (a) ដល់ (e) ខាងក្រោម នៃមធ្យមភាគប្រចាំឆ្នាំ នៃការគណនាកម្រិតការប្រើប្រាស់នៃឧបសម្ព័ន្ធF នៃសារធាតុដែលត្រូវត្រួតពិនិត្យសម្រាប់ឆ្នាំ២០១១ ២០១២ និង ២០១៣ និងបន្ថែម ១៥% នៃកម្រិតគណនាការប្រើប្រាស់ក្នុងឧបសម្ព័ន្ធC ក្រុម I សារធាតុដែលត្រូវត្រួតពិនិត្យដែលបានកំណត់នៅក្នុងកថាខណ្ឌ១ នៃមាត្រា2F ដែលបានបញ្ជាក់នៅក្នុងតារាងសមមូល CO_2៖

(a) ២០១៩ ដល់ ២០២៣ : ៩០%

(b) ២០២៤ ដល់ ២០២៨ : ៦០%

(c) ២០២៩ ដល់ ២០៣៣ : ៣០%

(d) ២០៣៤ ដល់ ២០៣៥ : ២០%

(e) ២០៣៦ និងបន្ទាប់មក : ១៥%

២- ទោះបីជាកថាខណ្ឌ១ នៃមាត្រានេះ បណ្តាភាគីអាចសម្រេច ដោយភាគីមួយត្រូវធានាថា សម្រាប់រយៈពេលចាប់ផ្តើម១២ខែ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០ និងរៀងរាល់១២ខែ ជាបន្តបន្ទាប់ទៀត ការគណនាកម្រិតនៃការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យនៅក្នុងឧបសម្ព័ន្ធF ដែលបានបញ្ជាក់នៅក្នុងតារាងសមមូល CO_2 មិនឱ្យលើសចំនួនភាគរយ (%) ដែលបានកំណត់បរិមាណនៃឆ្នាំនីមួយៗ ដូចមានបញ្ជាក់នៅក្នុងអនុកថាខណ្ឌ (a) ដល់ (e) ខាងក្រោម នៃមធ្យមភាគប្រចាំឆ្នាំនៃការគណនាកម្រិតនៃការប្រើប្រាស់ក្នុងឧបសម្ព័ន្ធF សារធាតុដែលត្រូវត្រួតពិនិត្យសម្រាប់ឆ្នាំ២០១១ ២០១២ និង ២០១៣ បន្ថែម ២៥% នៃកកម្រិតគណនានៃការប្រើប្រាស់ក្នុងឧបសម្ព័ន្ធC ក្រុម I សារធាតុដែលត្រូវត្រួតពិនិត្យបានកំណត់នៅក្នុងកថាខណ្ឌ១ នៃមាត្រា2F ដែលបានបញ្ជាក់នៅក្នុងតារាងសមមូល CO_2៖

(a) ២០២០ ដល់ ២០២៤ : ៩៥%

(b) ២០២៥ ដល់ ២០២៨ : ៦៥%

(c) ២០២៩ ដល់ ២០៣៣ : ៣០%

(d) ២០៣៤ ដល់ ២០៣៥ : ២០%

(e) ២០៣៦ និងបន្ទាប់មក : ១៥%

៣- ភាគីនីមួយៗដែលផលិតសារធាតុដែលត្រូវត្រួតពិនិត្យនៅក្នុងឧបសម្ព័ន្ធF នឹងត្រូវធានាថា រយៈពេល ១២ខែ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ និងរៀងរាល់១២ខែជាបន្តបន្ទាប់ទៀត ការគណនាកម្រិតនៃការផលិតសារធាតុដែលត្រូវត្រួតពិនិត្យនៅក្នុងឧបសម្ព័ន្ធF ដែលបានបញ្ជាក់នៅក្នុងតារាង

សមមូល CO_2 មិនឱ្យលើសភាគរយ(%) ដែលបានកំណត់ចេញនូវចំនួននៃឆ្នាំនីមួយៗ ដូចបានកំណត់នៅក្នុងអនុកថាខណ្ឌ(a) ដល់(e) ខាងក្រោម នៃមធ្យមភាគប្រចាំឆ្នាំនៃការគណនាកម្រិតការផលិតនៃឧបសម្ព័ន្ធF សារធាតុដែលត្រូវត្រួតពិនិត្យសម្រាប់ឆ្នាំ២០១១ ២០១២ និង២០១៣ បន្ថែម ១៥% នៃកម្រិតគណនាការផលិតសារធាតុដែលត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធC ក្រុមI ដែលបានកំណត់នៅក្នុងកថាខណ្ឌ២ នៃមាត្រា2F ដែលបានបញ្ជាក់នៅក្នុងតារាងសមមូល CO_2៖

(a) ២០១៩ ដល់ ២០២៣ : ៩០%
(b) ២០២៤ ដល់ ២០២៨ : ៦០%
(c) ២០២៩ ដល់ ២០៣៣ : ៣០%
(d) ២០៣៤ ដល់ ២០៣៥ : ២០%
(e) ២០៣៦ និងបន្ទាប់មក : ១៥%

៤- ទោះបីជាមានកថាខណ្ឌ៣ នៃមាត្រានេះបណ្តាភាគី អាចសម្រេចថា ភាគីដែលផលិតសារធាតុដែលត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធF ត្រូវធានាថា រយៈពេល១២ខែ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០ ហើយនិងរៀងរាល់១២ខែ ជាបន្តបន្ទាប់ទៀត ការគណនាកម្រិតនៃការផលិតសារធាតុដែលត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធF ដែលបានបញ្ជាក់នៅក្នុងតារាងសមមូល CO_2 មិនឱ្យលើសចំនួនភាគរយ (%) ដែលបានកំណត់បរិមាណនៃឆ្នាំនីមួយៗ ដែលបានកំណត់នៅក្នុងអនុកថាខណ្ឌ(a) ដល់(e) ខាងក្រោមនៃមធ្យមភាគប្រចាំឆ្នាំ នៃការគណនាកម្រិតការផលិតសារធាតុដែលត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធF សម្រាប់ឆ្នាំ២០១១ ២០១២ និង២០១៣ បន្ថែម១៥% នៃកម្រិតគណនាការផលិតសារធាតុដែលត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធC ក្រុម I សារធាតុដែលត្រូវត្រួតពិនិត្យដែលបានកំណត់ក្នុងកថាខណ្ឌ២ នៃមាត្រា2F ដែលបានបញ្ជាក់នៅក្នុងតារាងសមមូល CO_2៖

(a) ២០២០ ដល់ ២០២៤ : ៩៥%
(b) ២០២៥ ដល់ ២០២៨ : ៦៥%
(c) ២០២៩ ដល់ ២០៣៣ : ៣០%
(d) ២០៣៤ ដល់ ២០៣៥ : ២០%
(e) ២០៣៦ និងបន្ទាប់មក : ១៥%

៥- កថាខណ្ឌ១ ដល់ ៤ នៃមាត្រានេះនឹងត្រូវពន្យាពេល ដោយយោងទៅតាមការសម្រេចពីបណ្តាភាគីក្នុងការអនុញ្ញាតឱ្យកម្រិតនៃការផលិត ឬការប្រើប្រាស់ចាំបាច់ដើម្បីបំពេញសេចក្តីត្រូវការ ដែលយល់ព្រមដោយភាគីចំពោះករណីលើកលែងពិសេសក្នុងការប្រើប្រាស់។

៦- បណ្តាភាគីដែលផលិតសារធាតុក្នុងឧបសម្ព័ន្ធC ក្រុមI ឬសារធាតុក្នុងឧបសម្ព័ន្ធF ត្រូវធានាថា សម្រាប់រយៈពេល១២ខែ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០ ហើយនិងរៀងរាល់១២ខែជាបន្តបន្ទាប់ទៀត ការបញ្ចេញសារធាតុក្នុងឧបសម្ព័ន្ធF ក្រុម២ សារធាតុមាននៅក្នុងផលិតកម្មផលិតសារធាតុក្នុងឧបសម្ព័ន្ធC ក្រុមI ឬឧបសម្ព័ន្ធF សារធាតុត្រូវបានបំផ្លាញ នឹងត្រូវបានលើកលែងជាពិសេស ចំពោះការប្រើប្រាស់បច្ចេកវិទ្យា ដែលបានអនុម័តដោយភាគីនៅក្នុងរយៈពេល១២ខែដូចគ្នា។

៧- ភាគីនីមួយៗនឹងត្រូវធានាថា រាល់ការបំផ្លាញចោលណាមួយ នៃសារធាតុក្នុងឧបសម្ព័ន្ធF ក្រុម2 សារធាតុដែលបង្កើតដោយរោងចក្រ ដែលផលិតសារធាតុ ក្នុងឧបសម្ព័ន្ធC ក្រុម២ ឬឧបសម្ព័ន្ធF នឹងត្រូវអនុញ្ញាតដោយការប្រើប្រាស់បច្ចេកវិទ្យាដែលអនុម័តដោយភាគី។

មាត្រា៣

សេចក្តីផ្តើមមាត្រា៣ នៃពិធីសារគួរតែជំនួសដូចខាងក្រោម៖

១- "សម្រាប់គោលបំណងនៃមាត្រា២ 2A ដល់2J និង៥ ភាគីនីមួយៗសម្រាប់ក្រុមសារធាតុនីមួយៗ នៅក្នុងឧបសម្ព័ន្ធA ឧបសម្ព័ន្ធB ឧបសម្ព័ន្ធC ឧបសម្ព័ន្ធE ឬ ឧបសម្ព័ន្ធF កំណត់កម្រិតគណនានៃ៖"
សម្រាប់សញ្ញា (;) ចុងក្រោយនៃអនុកថាខណ្ឌ (a)(i) នៃមាត្រា ៣ នៃពិធីសារ នឹងត្រូវជំនួសដោយ៖
",លើកលែង លុះត្រាតែបានបញ្ជាក់នៅក្នុងកថាខណ្ឌទី២;"
ពាក្យខាងក្រោមនេះនិងត្រូវបន្ថែមនៅចុងបញ្ចប់នៃមាត្រា៣ នៃពិធីសារ៖
";និង
(d) ការបញ្ចេញសារធាតុនៃឧបសម្ព័ន្ធF ក្រុមII សារធាតុផលិតនៅក្នុងរោងចក្រនីមួយៗដែលផលិតសារធាតុក្នុងឧបសម្ព័ន្ធC ក្រុមI ឬសារធាតុ ក្នុងឧបសម្ព័ន្ធF ដែលរួមបញ្ចូលក្នុងចំណោមសារធាតុទាំងនោះ បរិមាណសារធាតុដែលបំភាយចេញពីឧបករណ៍ដែលលេចធ្លាយ ដំណើរការបញ្ចេញ និងឧបករណ៍បំផ្លាញចោល ប៉ុន្តែមិនរាប់បញ្ចូលបរិមាណដែលប្រមូលបានយកមកប្រើប្រាស់ការបំផ្លាញឬរក្សាទុក។

២- នៅពេលគណនាកម្រិតនៃការផលិត ការប្រើប្រាស់ ការនាំចូល ការនាំចេញ ដែលបង្ហាញសមមូល CO_2 ការបញ្ចេញសារធាតុនៅក្នុងឧបសម្ព័ន្ធF និងឧបសម្ព័ន្ធC ក្រុមI សារធាតុសម្រាប់គោលបំណងនៃមាត្រា2J កថាខណ្ឌទី៥bis នៃមាត្រា២ និងកថាខណ្ឌ១(d) នៃមាត្រា៣ ភាគីនីមួយៗនឹងប្រើប្រាស់សក្តានុពលនៃការកើនកម្តៅផែនដី នៃសារធាតុទាំងនោះដូចបានកំណត់នៅក្នុងក្រុមI នៃឧបសម្ព័ន្ធA ឧបសម្ព័ន្ធC និង ឧបសម្ព័ន្ធF។

មាត្រា៤ កថាខណ្ឌ១ sept

កថាខណ្ឌខាងក្រោមនេះនឹងត្រូវដាក់បញ្ចូលបន្ទាប់ពីកថាខណ្ឌ១*sex*នៃមាត្រា៤ នៃពិធីសារ៖
"១ *Sept* នៅពេលចូលជាធរមាននៃកថាខណ្ឌនេះ ភាគីនីមួយៗនឹងត្រូវហាមឃាត់ការនាំចូលនៃសារធាតុដែលត្រូវត្រួតពិនិត្យក្នុងឧបសម្ព័ន្ធF ពីរដ្ឋដែលមិនមែនជាភាគីនៃពិធីសារនេះ។

មាត្រា៤ កថាខណ្ឌ២ sept

កថាខណ្ឌខាងក្រោមនេះនឹងត្រូវដាក់បញ្ចូលបន្ទាប់ពីកថាខណ្ឌ២sex នៃមាត្រា៤ នៃពិធីសារ៖
"២ Sept នៅពេលធរមាននៃកថាខណ្ឌនេះ ភាគីនីមួយៗនឹងត្រូវហាមឃាត់ការនាំចេញនៃសារធាតុដែលត្រូវត្រួតពិនិត្យនៅក្នុងឧបសម្ព័ន្ធF ពីរដ្ឋដែលមិនមែនជាភាគីនៃពិធីសារនេះ។

មាត្រា៤ កថាខណ្ឌ៥ ៦ និង៧

នៅក្នុងកថាខណ្ឌ៥ ៦ និង៧ មាត្រា៤ នៃពិធីសារនេះសម្រាប់ពាក្យ៖
"ឧបសម្ព័ន្ធA B C និងE"
នឹងត្រូវបានជំនួសដោយ៖
"ឧបសម្ព័ន្ធA B C E និងF"

មាត្រា៤ កថាខណ្ឌ៨

នៅក្នុងកថាខណ្ឌ៨ មាត្រា៤ នៃពិធីសារនេះសម្រាប់ពាក្យ៖
"ឧបសម្ព័ន្ធ2A ដល់2I"
នឹងត្រូវបានជំនួសដោយ៖
"ឧបសម្ព័ន្ធ2A ដល់2J"

មាត្រា4B

កថាខណ្ឌខាងក្រោមនេះនឹងត្រូវបន្ថែមបន្ទាប់ពីកថាខណ្ឌ2 មាត្រា4B នៃពិធីសារ៖
"២ bis. ភាគីនីមួយៗនឹងត្រូវបង្កើត និងអនុវត្តន៍ប្រព័ន្ធផ្តល់អាជ្ញាប័ណ្ណ នាំចូលនិងនាំចេញនៃសារធាតុថ្មី ប្រើប្រាស់រួច កែច្នៃឡើងវិញ នៃសារធាតុដែលត្រូវត្រួតពិនិត្យ ក្នុងឧបសម្ព័ន្ធF ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ ២០១៩ ឬក្នុងរយៈពេល៣ខែក្រោយពេលចូលជាធរមាននៃកថាខណ្ឌនេះ។ ភាគីណាមួយប្រតិបត្តិក្រោមកថាខណ្ឌ១នៃមាត្រា៥ ដែលសម្រេចថា មិនពាក់ព័ន្ធក្នុងការបង្កើត និងអនុវត្តន៍ប្រព័ន្ធផ្តល់លិខិតអនុញ្ញាតចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ អាចពន្យាការអនុវត្តរហូតដល់ថ្ងៃទី១ ខែមករា ឆ្នាំ២០២១។"

មាត្រា៥

នៅក្នុងកថាខណ្ឌ៤ នៃមាត្រា៥ នៃពិធីសារសម្រាប់ពាក្យ៖
"2I"
នឹងត្រូវជំនួសដោយ៖
"2J"
នៅក្នុងកថាខណ្ឌ៥ នឹង៦ មាត្រា៥ នៃពិធីសារសម្រាប់ពាក្យ៖
"មាត្រា2I"
នឹងត្រូវាបានជំនួសដោយ៖
"មាត្រា2I និង2J"
នៅក្នុងកថាខណ្ឌ៥ មាត្រា៥ នៃពិធីសារនៅខាងមុខពាក្យ៖
"វិធានការត្រួតពិនិត្យណាមួយ"
នឹងត្រូវបន្ថែមពាក្យ៖
"ជាមួយ"

កថាខណ្ឌខាងក្រោមនឹងត្រូវបន្ថែមបន្ទាប់ពីកថាខណ្ឌ 8 *ter* នៃមាត្រា៥ នៃពិធីសារ៖
"8 qua"

(a) ភាគីនីមួយៗប្រតិបត្តិក្រោមកថាខណ្ឌ១ នៃមាត្រានេះ អាស្រ័យលើការកែតម្រូវណាមួយបានបង្កើតវិធានការត្រួតពិនិត្យនៅក្នុងមាត្រា2J ដោយយោងតាមកថាខណ្ឌ៩ នៃមាត្រា២ នឹងត្រូវពន្យាពេលការអនុលោមតាមច្បាប់ជាមួយនឹងវិធានការត្រួតពិនិត្យដែលបានកំណត់នៅក្នុងអនុកថាខណ្ឌ (a) ដល់ (e) នៃកថាខណ្ឌ១ មាត្រា2J និងអនុកថាខណ្ឌ (a) ដល់ (e) នៃកថាខណ្ឌ3 មាត្រា2J និងកែប្រែវិធានការទាំងនោះដូចខាងក្រោម៖

(i) ២០២៤ ដល់ ២០២៨ : ១00%

(ii) ២០២៩ ដល់ ២០៣៤ : ៩0%

(iii) ២០៣៥ ដល់ ២០៣៩ : ៧0%

(iv) ២០៤០ ដល់ ២០៤៤ : ៥០%

(v) ២០៤៥ និងបន្ទាប់មក : ២០%

(b) ទោះបីជាមានអនុកថាខណ្ឌ(a) ខាងលើបណ្តាភាគីអាចនឹងសម្រេចថា ភាគីមួយអាចប្រតិបត្តិក្រោមកថាខណ្ឌ១ នៃមាត្រានេះ អាស្រ័យលើរាល់ការកែតម្រូវក្នុងការបង្កើតវិធានការត្រួតពិនិត្យនៅក្នុងមាត្រា2J ដោយគោរពតាមកថាខណ្ឌ៩ នៃមាត្រា២ នឹងមានសិទ្ធិពន្យាពេលអនុលោមតាមច្បាប់ជាមួយនឹងវិធានការត្រួតពិនិត្យដែលបានកំណត់ក្នុងអនុកថាខណ្ឌ(a) ដល់(e) នៃកថាខណ្ឌ១ មាត្រា2J និងអនុកថាខណ្ឌ(a) ដល់(e) នៃកថាខណ្ឌ3 មាត្រា2J និងកែប្រែវិធានការទាំងនោះដូចខាងក្រោម៖

(i) ២០២៨ ដល់ ២០៣១ : ១០០%

(ii) ២០៣២ ដល់ ២០៣៦ : ៩០%

(iii) ២០៣៧ ដល់ ២០៤១ : ៨០%

(iv) ២០៤២ ដល់ ២០៤៦ : ៧០%

(V) ២០៤៧ និងបន្ទាប់មក : ១៥%

(c) ភាគីនីមួយៗប្រតិបត្តិនៅក្រោមកថាខណ្ឌ១ នៃមាត្រានេះ សម្រាប់គោលបំណងនៃការគណនាកម្រិតមូលដ្ឋាននៃការប្រើប្រាស់ក្រោមមាត្រា2J នឹងមានសិទ្ធិប្រើប្រាស់កម្រិតមធ្យមនៃកម្រិតគណនានៃការប្រើប្រាស់នៃឧបសម្ព័ន្ធF សារធាតុដែលត្រូវត្រួតពិនិត្យសម្រាប់ឆ្នាំ២០២០ ២០២១ និង ២០២២ ដោយបូកបន្ថែម65% នៃកម្រិតមូលដ្ឋាននៃការប្រើប្រាស់សារធាតុក្នុងឧសម្ព័ន្ធC ក្រុម១ សារធាតុដែលត្រូវត្រួតពិនិត្យ ដែលកំណត់ក្នុងកថាខណ្ឌ8 ter នៃមាត្រានេះ។

(d) ទោះបីជាមានអនុកថាខណ្ឌ(c) ខាងលើ បណ្តាភាគីអាចសម្រេចថា ភាគីមួយដែលប្រតិបត្តិនៅក្រោមកថាខណ្ឌ១ នៃមាត្រានេះ នឹងត្រូវមានសិទ្ធិក្នុងការប្រើប្រាស់ជាមធ្យមនៃកម្រិតគណនានៃការប្រើប្រាស់សារធាតុដែលត្រូវត្រួតពិនិត្យនៃឧបសម្ព័ន្ធF សម្រាប់ឆ្នាំ២០២៤ ២០២៥ ហើយនិង ២០២៦ បូកបន្ថែម 65% នៃកម្រិតមូលដ្ឋាននៃការប្រើប្រាស់ នៃឧសម្ព័ន្ធC ក្រុម១ សារធាតុដែលត្រូវត្រួតពិនិត្យ ដូចបានកំណត់ក្នុងកថាខណ្ឌ8 ter នៃមាត្រានេះ។

(e) ភាគីនីមួយៗដែលប្រតិបត្តិ នៅក្រោមកថាខណ្ឌ១ នៃមាត្រានេះ និងកំពុងផលិតសារធាតុដែលត្រូវត្រួតពិនិត្យនៅក្នុងឧបសម្ព័ន្ធF ដែលមានបំណងដើម្បីគណនាកម្រិតមូលដ្ឋាននៃការផលិតសារធាតុដែលត្រូវត្រួតពិនិត្យក្រោមមាត្រា២J អាចមានសិទ្ធិ ដើម្បីប្រើប្រាស់ការគណនាការប្រើប្រាស់កម្រិតមធ្យមនៃសារធាតុដែលត្រូវត្រួតពិនិត្យសម្រាប់ឆ្នាំ២០២០ ២០២១ និងឆ្នាំ២០២២ បូកបន្ថែម65% នៃកម្រិតមូលដ្ឋាននៃការផលិត នៃឧសម្ព័ន្ធC ក្រុម១ សារធាតុដែលត្រូវត្រួតពិនិត្យ ដូចកំណត់ក្នុងកថាខណ្ឌ8ter នៃមាត្រានេះ ។

(f) ទោះបីជាមានអនុកថាខណ្ឌ(e) ខាងលើ ភាគីអាចនឹងសម្រេចថា ភាគីមួយប្រតិបត្តិនៅក្រោមកថាខណ្ឌ១ នៃមាត្រានេះ និងការផលិតសារធាតុដែលត្រូវត្រួតពិនិត្យនៅក្នុងឧបសម្ព័ន្ធF ត្រូវមានសិទ្ធិប្រើប្រាស់ជាមធ្យមនៃកម្រិតគណនានៃការផលិតសារធាតុដែលត្រូវត្រួតពិនិត្យ នៃឧបសម្ព័ន្ធF សម្រាប់ឆ្នាំ២០២៤ ២០២៥ និង២០២៦ បូកបន្ថែម65% នៃកម្រិតមូលដ្ឋាននៃការផលិត នៃឧសម្ព័ន្ធC ក្រុម១ សារធាតុដែលត្រូវត្រួតពិនិត្យ ដូចកំណត់នៅក្នុងកថាខណ្ឌ8 ter នៃមាត្រានេះ។

(g) អនុកថាខណ្ឌ(a) ដល់(f) នៃកថាខណ្ឌនេះ នឹងត្រូវអនុវត្តសម្រាប់គណនាកម្រិតនៃការផលិត និង ការប្រើប្រាស់ ដើម្បីរក្សាសិទ្ធិក្នុងការលើកលែងចំពោះការប្រើប្រាស់សម្រាប់ប្រទេសដែលមាន ស៊ីតុណ្ហភាពបរិយាកាសខ្ពស់ផ្អែកលើលក្ខណៈវិនិច្ឆ័យដែលបានសម្រេចដោយភាគី។

មាត្រា៦

នៅក្នុងមាត្រា៦ នៃពិធីសារសម្រាប់ពាក្យ៖
"មាត្រា2A ដល់2I"
នឹងត្រូវបានជំនួសដោយ៖
"មាត្រា2A ដល់2J"

មាត្រា៧ កថាខណ្ឌ២ ៣ ហើយនិង ៣ter

ពាក្យខាងក្រោមនឹងត្រូវបន្ថែមបន្ទាប់ពីសញ្ញា "- នៅក្នុងឧបសម្ព័ន្ធE សម្រាប់ឆ្នាំ១៩៩១," នៅក្នុងកថាខណ្ឌ២ មាត្រា៧ នៃពិធីសារ៖

"-នៅក្នុងឧបសម្ព័ន្ធF សម្រាប់ឆ្នាំ២០១១ ដល់ ២០១៣ លើកលែងភាគីដែលប្រតិបត្តិ នៅក្រោមកថាខណ្ឌ១ នៃមាត្រា៥ នឹងត្រូវផ្តល់ទិន្នន័យសម្រាប់ឆ្នាំ២០២០ ដល់២០២២ ប៉ុន្តែភាគីដែលប្រតិបត្តិនៅក្រោមកថាខណ្ឌ១ នៃមាត្រា៥ ចំពោះអនុកថាខណ្ឌ(d) និង(f) នៃកថាខណ្ឌ8qua មាត្រា៥ នឹងត្រូវផ្តល់ទិន្នន័យសម្រាប់ឆ្នាំ២០២៤ ដល់២០២៦"

នៅក្នុងកថាខណ្ឌ២ និង៣ នៃមាត្រា៧ នៃពិធីសារសម្រាប់ពាក្យ៖
"C និងE"
នឹងត្រូវជំនួសដោយ៖
"C, E និងF"

កថាខណ្ឌខាងក្រោមនឹងត្រូវបន្ថែមលើមាត្រា៧ នៃពិធីសារបន្ទាប់ពីកថាខណ្ឌ3bis:

"3ter. ភាគីនីមួយៗ នឹងត្រូវផ្តល់ទៅលេខាធិការដ្ឋាននូវទិន្នន័យស្តីពីការបញ្ចេញប្រចាំឆ្នាំនៃសារធាតុក្នុងឧបសម្ព័ន្ធF ក្រុមII សារធាតុដែលត្រូវត្រួតពិនិត្យនៅក្នុងផលិតកម្មនីមួយៗ ស្របតាមកថាខណ្ឌ១ (d) មាត្រា៣ នៃពិធីសារ"

មាត្រា៧ កថាខណ្ឌ៤

នៅក្នុងកថាខណ្ឌ៤ មាត្រា៧ បន្ទាប់ពីពាក្យ៖
"ទិន្នន័យស្ថិតិ" ហើយនិង "ផ្តល់ទិន្នន័យ"
នឹងត្រូវបានជំនួសបន្ថែមពាក្យ៖
"ការផលិត"

មាត្រា១០ កថាខណ្ឌ១

នៅក្នុងកថាខណ្ឌ១ មាត្រា១០ នៃពិធីសារសម្រាប់ពាក្យ៖
"និងមាត្រា2I"
នឹងត្រូវបានជំនួសដោយ៖
",មាត្រា2I និងមាត្រា2J"
ខាងក្រោមនេះត្រូវបានបន្ថែមនៅចុងបញ្ចប់នៃកថាខណ្ឌ១ មាត្រា១០ នៃពិធីសារ៖

"ភាគីប្រតិបត្តិ នៅក្រោមកថាខណ្ឌ១ នៃមាត្រា៥ ដែលជ្រើសរើសដោយខ្លួនឯង ក្នុងការទទួលមូលនិធិពីយន្តការហិរញ្ញវត្ថុណាមួយផ្សេងទៀត ដែលអាចជាលទ្ធផលនៅក្នុងកិច្ចប្រជុំ ដែលជាផ្នែកមួយនៃការយល់ព្រមលើការចំណាយបន្ថែម ដែលផ្នែកនោះមិនត្រូវបានឆ្លើយតបក្រោមយន្តការហិរញ្ញវត្ថុនៅក្រោមមាត្រា១០ នៃពិធីសារ"

មាត្រា១៧

នៅក្នុងមាត្រា១៧ នៃពិធីសារសម្រាប់ពាក្យ៖

"មាត្រា2A ដល់2I"

នឹងត្រូវបានជំនួសដោយ៖

"មាត្រា2A ដល់2J"

ឧបសម្ព័ន្ធA

តារាងខាងក្រោមនឹងត្រូវបានជំនួសដោយតារាងសម្រាប់ក្រុម I នៅក្នុងឧបសម្ព័ន្ធA នៃពិធីសារៈ

ក្រុម	សារធាតុ	សក្តានុពលបំផ្លាញស្រទាប់អូហ្សូន*	សក្តានុពលរយៈពេល១០០ ឆ្នាំនៃការកើនឡើងកម្តៅផែនដី
Group 1			
$CFCl_3$	(CFC-11)	1.0	4,750
CF_2Cl_2	(CFC-12)	1.0	10,900
$C_2F_3Cl_3$	(CFC-113)	0.8	6,130
$C_2F_4Cl_2$	(CFC-114)	1.0	10,000
C_2F_5Cl	(CFC-115)	0.6	7,370

ឧបសម្ព័ន្ធC និងឧបសម្ព័ន្ធF

តារាងខាងក្រោមនឹងត្រូវបានជំនួសដោយតារាងសម្រាប់ក្រុម I នៅក្នុងឧបសម្ព័ន្ធC នៃពិធីសារ

ក្រុម	សារធាតុ	ចំនួននៃ Isomers	សក្តានុពលបំផ្លាញស្រទាប់អូហ្សូន*	សក្តានុពលរយៈពេល១០០ឆ្នាំនៃការកើនឡើងកម្តៅផែនដី
Group 1				
$CHFCl_2$	(HCFC-21)**	1	0.04	151
CHF_2Cl	(HCFC-22)**	1	0.055	1810
CH_2FCl	(HCFC-31)	1	0.02	
C_2HFCl_4	(HCFC-121)	2	0.01 – 0.04	
$C_2HF_2Cl_3$	(HCFC-122)	3	0.02 – 0.08	
$C_2HF_3Cl_2$	(HCFC-123)	3	0.02 – 0.06	77
$CHCl_2CF_3$	(HCFC-123)**	-	0.02	
C_2HF_4Cl	(HCFC-124)	2	0.02 – 0.04	609
$CHFClCF_3$	(HCFC-124)**	-	0.022	
$C_2H_2FCl_3$	(HCFC-131)	3	0.007 – 0.05	
$C_2H_2F_2Cl_2$	(HCFC-132)	4	0.008 – 0.05	
$C_2H_2F_3Cl$	(HCFC-133)	3	0.02 – 0.06	
$C_2H_3FCl_2$	(HCFC-141)	3	0.005 – 0.07	
CH_3CFCl_2	(HCFC-141b)**	-	0.11	725
$C_2H_3F_2Cl$	(HCFC-142)	3	0.008 – 0.07	
CH_3CF_2Cl	(HCFC-142b)**	-	0.065	2310
C_2H_4FCl	(HCFC-151)	2	0.003 – 0.005	
C_3HFCl_6	(HCFC-221)	5	0.015 – 0.07	
$C_3HF_2Cl_5$	(HCFC-222)	9	0.01 – 0.09	
$C_3HF_3Cl_4$	(HCFC-223)	12	0.01 – 0.08	
$C_3HF_4Cl_3$	(HCFC-224)	12	0.01 – 0.09	
$C_3HF_5Cl_2$	(HCFC-225)	9	0.02 – 0.07	
$CF_3CF_2CHCl_2$	(HCFC-225ca)**	-	0.025	122
CF_2ClCF_2CHClF	(HCFC-225cb)**	-	0.033	595
C_3HF_6Cl	(HCFC-226)	5	0.02 – 0.10	
$C_3H_2FCl_5$	(HCFC-231)	9	0.05 – 0.09	

$C_3H_2F_2Cl_4$	(HCFC-232)	16	0.008 – 0.10	
$C_3H_2F_3Cl_3$	(HCFC-233)	18	0.007 – 0.23	
$C_3H_2F_4Cl_2$	(HCFC-234)	16	0.01 – 0.28	
$C_3H_2F_5Cl$	(HCFC-235)	9	0.03 – 0.52	
$C_3H_3FCl_4$	(HCFC-241)	12	0.004 – 0.09	
$C_3H_3F_2Cl_3$	(HCFC-242)	18	0.005 – 0.13	
$C_3H_3F_3Cl_2$	(HCFC-243)	18	0.007 – 0.12	
$C_3H_3F_4Cl$	(HCFC-244)	12	0.009 – 0.14	
$C_3H_4FCl_3$	(HCFC-251)	12	0.001 – 0.01	
$C_3H_4F_2Cl_2$	(HCFC-252)	16	0.005 – 0.04	
$C_3H_4F_3Cl$	(HCFC-253)	12	0.003 – 0.03	
$C_3H_5FCl_2$	(HCFC-261)	9	0.002 – 0.02	
$C_3H_5F_2Cl$	(HCFC-262)	9	0.002 – 0.02	
C_3H_6FCl	(HCFC-271)	5	0.001 – 0.03	

* ចន្លោះតម្លៃរបស់សក្តានុពលនៃការបំផ្លាញស្រទាប់អូហ្សូន ត្រូវបានបង្ហាញ ដែលក្នុងនោះតម្លៃខ្ពស់បំផុតត្រូវបានប្រើសម្រាប់គោលបំណងនៃពិធីសារនេះ។ សក្តានុពលនៃការបំផ្លាញស្រទាប់អូហ្សូន បានចុះបញ្ជីជាតម្លៃទោលត្រូវបានកំណត់តាមការគណនាដោយផ្អែកលើវិធានការរបស់មន្ទីរពិសោធន៍។ តម្លៃដែលបានចុះបញ្ជីដោយស្ថិតនៅចន្លោះតម្លៃកំណត់ គឺផ្អែកទៅតាមតម្លៃប៉ាន់ស្មាននិងពុំសូវជាក់លាក់។ តម្លៃដែលស្ថិតនៅចន្លោះបានកំណត់មានការទាក់ទងទៅនឹងក្រុមអ៊ីសូម៉ែរ។ តម្លៃខ្ពស់ជាការវាយតម្លៃទៅលើសក្តានុពលនៃការបំផ្លាញស្រទាប់អូហ្សូន របស់អ៊ីសូម៉ែរដែលមានសក្តានុពលខ្ពស់បំផុតទៅលើការបំផ្លាញស្រទាប់អូហ្សូន ចំណែកតម្លៃទាប គឺជាការប៉ាន់ប្រមាណលើសក្តានុពលនៃការបំផ្លាញស្រទាប់អូហ្សូនរបស់អ៊ីសូម៉ែរដែលមានតម្លៃសក្តានុពលនៃការបំផ្លាញស្រទាប់អូហ្សូនក្នុងកម្រិតទាបបំផុត។

**កំណត់ទៅលើសារធាតុដែលអាចធ្វើពាណិជ្ជបានរួមជាមួយ នឹងតម្លៃសក្តានុពលនៃការបំផ្លាញស្រទាប់អូហ្សូនដែលបានចុះបញ្ជីប្រើប្រាស់សម្រាប់គោលបំណងរបស់ពិធីសារ។

***សារធាតុដែលគ្មានសក្តានុពលដល់កំណើនកម្តៅផែនដី ត្រូវបានឱ្យស្មើសូន្យ លុះត្រាតែតម្លៃសក្តានុពលកំណើនកម្តៅផែនដី រួមបញ្ចូលមធ្យោបាយនៃដំណើរការដែលបានព្យាករណ៍ក្នុងកថាខណ្ឌ៩ (a) (ii) នៃមាត្រា២។

ឧបសម្ព័ន្ធខាងក្រោមនឹងត្រូវបានបន្ថែមក្នុងពិធីសារបន្ទាប់ពីឧបសម្ព័ន្ធE៖

ℓ

"ឧបសម្ព័ន្ធF : សារធាតុដែលត្រូវត្រួតពិនិត្យ"

ក្រុម	សារធាតុ	សក្តានុពលរយៈពេល១០០ឆ្នាំនៃការកើនឡើងកម្តៅផែនដី
ក្រុម I		
CHF_2CHF_2	HFC – 134	1,100
CH_2FCF_3	HFC – 134a	1,430
CH_2FCHF_2	HFC – 143	353
$CHF_2CH_2CF_3$	HFC – 245fa	1,030
$CF_3CH_2CF_2CH_3$	HFC – 365mfc	794
CF_3CHFCF_2	HFC – 227ea	3,220
$CH_2FCF_2CHF_2CF_3$	HFC – 236cb	1,340
